# "ទន្លេប្រាំពីរនៃព្រះគុណ"

*រឿងទាំងមូលនៅក្នុងព្រះគម្ពីរ*

*ជារឿងប្រាំពីរដែលវេញបញ្ចូលគ្នា*

*រៀបចំជាផែនទីនៅក្នុងតារាងគំនូររូបភាព*

ដោយ

អិនឌ្រូ ជេ អូស៊ិន

*នេះគឺជាសៀវភៅ*

*សម្រាប់ផ្ទាំងធំនៃ ទបនគ នៅគេហទំព័រ*

www.SevenStreamsofGrace.com

សៀវភៅនេះអាចទិញបានតាមរយៈគេហទំព័រ www.CondeoPress.com
ឬតាមរយៈគេហទំព័រ www.SevenStreamsofGrace.com

បោះពុម្ពដោយរោងពុម្ព Snowfall, Monument. Colorado

# ផ្ទាំងធំសម្រាប់"ទន្លេប្រាំពីរនៃព្រះគុណ"



## ផ្ទាំងធំសម្រាប់"ទន្លេប្រាំពីរនៃព្រះគុណ"



# ផ្ទាំងធំសម្រាប់"ទន្លេប្រាំពីរនៃព្រះគុណ"



# ផ្ទាំងធំសម្រាប់"ទន្លេទ្រាំពីរនៃព្រះគុណ"



# ផ្ទាំងធំសម្រាប់"ទន្លេប្រាំពីរនៃព្រះគុណ"



# ផ្ទាំងធំសម្រាប់"ទន្លេទ្រាំពីរនៃព្រះគុណ"



រក្សាសិទ្ធិ © ២០១១ ដោយ អ៊ិនខ្រេ ចន អូហ្សិន

រក្សាសិទ្ធិគ្រប់បែបយ៉ាង។ មេរៀនទាំងអស់នៅក្នុងសៀវភៅនេះអាចថតចម្លងសម្រាប់
ការសិក្សាផ្ទាល់ខ្លួន ប្រើនៅក្នុងសាលា ឯកសារសម្រាប់ថ្នាក់សិក្សាថ្ងៃអាទិត្យ
ឬថ្នាក់សិក្សានៅតាមផ្ទះ ដរាបណាមិនមានការគិតកម្រៃ ឬពាក់ព័ន្ធជាមួយកម្រៃ។
មេរៀននៅក្នុងសៀវភៅនេះមិនអនុញ្ញាតឱ្យផលិតសាជាថ្មីតាមរូបភាពណាមួយ
ដើម្បីទៅធ្វើអាជីវកម្ម ឬយកទៅលក់ទេ បើពុំមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធ
តាមរយៈគេហទំព័រ www.sevenstreamsofgrace.com លើកលែងតែការដាក់បញ្ចូល
សេចក្តីដកស្រង់ដោយសង្ខេបនៅក្នុងការរំឭកឡើងវិញ។

កំពុងរង់ចាំលេខ ISBN

គំនូរតុក្កតាដោយ ខូរេ ប៊ុស្កូ

ក្រាហ្វិចផ្ទាំងធំ ដោយ យ៉ាសូ វ៉ៃកយ័រ

រចនាសៀវភៅដោយ ចេន ឃរី

រចនាគម្របដោយភីលីព បារីរ៉ា

លក់ និងផ្សព្វផ្សាយទីផ្សារដោយ ខុនឌីអូ ប្រេស

បោះពុម្ពនៅ Monument, Colorado by Snowfall Press

# មាតិកា


*បំណែកផ្ទាំងធំរបស់«ទន្លេប្រាំពីរនៃព្រះគុណ»*-------------------------------------------------------------i

សេចក្តីសង្ខេប និងសេចក្តីផ្តើមអំពី«ទេវសាស្ត្រនៅក្នុងព្រះគម្ពីរ» ---------------------------------------- ១

តើប្រព្រឹត្តទៅយ៉ាងដូចម្ដេច? ------------------------------------------------------------------------ ៣

ប្រធានបទ-ទន្លេ និងសម័យកាលពេលវេលា ------------------------------------------------------------ ៤

ព្រះគម្ពីរនៅក្នុងមួយទំព័រ! លំហូរនៃបទគម្ពីរ ------------------------------------------------------------ ៦

សម័យកាលនៅផ្នែកខាងលើ / ព្រឹត្តិការណ៍ដែលជាបង្គោលផ្តល់ព័ត៌មាន ២៤ --------------------------- ៧

ទន្លេទី ១: ជីវិត- -------- ---------------------------------------------------------------------------៣២

ទន្លេទី ២: ការសម្រាក-- -----------------------------------------------------------------------------៤៣

ទន្លេទី ៣: ការគ្រប់គ្រង- ---------------------------------------------------------------------------- ៥៤

ទន្លេទី ៤: ព្រះពរ-------- ---------------------------------------------------------------------------- ៦៥

ទន្លេទី ៥: ភាពបរិសុទ្ធ-- ---------------------------------------------------------------------------៧៦

ទន្លេទី ៦: មិត្តភាព------ ----------------------------------------------------------------------------៨៧

ទន្លេទី ៧: ? ទន្លេអាថ៌កំបាំង ------------------------------------------------------------------------ ៩៨

សំណួរឆ្លុះបញ្ចាំង ------ -------- ----------------------------------------------------------------------១០៩


មេរៀនទាំងអស់នេះមានច្រើនភាសា ដែលអាចទទួលយកបានដោយឥតគិតថ្លៃតាមរយៈគេហទំព័រ

**www.SevenStreamsOfGrace.com**

អរគុណថែមទៀតដល់

វិចិត្រករគំនូតុក្កតា
ខូរេ ប៊ីស្កូ ម៉ារិក
និងវិចិត្រករផ្នែកខាងក្រាហ្វិច
យ៉ូស្វេ វ៉ែកឃ័រ
ដែលបានស្ម័ក្រចិត្តលះបង់ពេលវេលា
ក្នុងការគូរគំនូររបស់ពួកគេ
ហើយក៏សូមអរគុណដល់
អេរីន ប៊ី, ជេន ស៊ី និងភីលីព ប៊ី
ដែលព្រមលះបង់ពេលវេលា និងទេពកោសល្យ
ព្រមទាំងអរគុណដល់មិត្តភក្តិទាំងអស់ ជាអ្នកជឿព្រះ ដែលបាន
បកប្រែ បានធ្វើដំណើរទៅកន្លែងផ្សេងៗបង្រៀនមេរៀនទាំងអស់នេះ
អរគុណដល់ ខេត លីន បន និងគ្រួសារ
និងអរគុណដល់អ្នកទាំងអស់ដែលស្រឡាញ់ព្រះជាម្ចាស់
ដែលបានឧបត្ថម្ភគ្រួសារយើង
នៅក្នុងព័ន្ធកិច្ចនេះ និងព័ន្ធកិច្ចដទៃទៀត
យើងទុកចិត្តព្រះជាម្ចាស់កាន់តែខ្លាំង ដោយព្រោះអ្នករាល់គ្នា។

# សូមស្វាគមន៍មកកាន់ទន្លេប្រាំពីរនៃព្រះគុណ

*ទន្លេប្រាំពីរនៃព្រះគុណ* (ទបនគ) ចាប់ផ្ដើមឡើងជាផ្ទាំងរូបភាពដ៏ធំមួយដែលមានពណ៌ ផ្គុំឡើងពីគំនូរជិតមួយរយ ជាខ្សែរូបភាពតុក្កតាប្រាំពីរខ្សែ។ ទន្លេប្រាំពីរនៃព្រះគុណបង្ហាញប្រាប់អំពីព្រះគម្ពីរជាស្នាដៃប្រវត្តិសាស្ត្រដែលវេញបញ្ចូលគ្នាយ៉ាងល្អ ដែលបើកសម្ដែងឱ្យឃើញព្រះយេហូវ៉ា ដ៏ជាព្រះផ្ទាល់។ ព្រះគម្ពីរអាចពិបាកយល់ខ្លាំងណាស់ ប៉ុន្តែគំនូរនីមួយៗនៅក្នុង ទបនគ បង្ហាញរបៀបដែលផ្នែកនីមួយៗរបស់ព្រះគម្ពីរត្រូវទៅក្នុងផ្ទាំងរៀបរូបភាពធំមួយ។ ព្រះគម្ពីរគឺជារឿងធំមួយដែលពាក់ព័ន្ធគ្នា ហើយគ្រប់ទំព័រទាំងអស់មានន័យនៅក្នុងរូបភាពធំ។

ផ្ទាំងធំនេះត្រូវបានបង្ហាញជាចំណែកៗនៅទំព័រ ii-vii នៅក្នុងសៀវភៅនេះ។ គេអាចមើលផ្ទាំងរូបភាពនេះ «ពង្រីកពង្រួម» និងបោះពុម្ពទំហំណាក៏បានដោយឥតគិតថ្លៃ តាមគេហទំព័រ www.SevenStreamsofGrace.cm។ទបនគ ក៏ជាសិក្ខាសាលា វីដេអូបង្ហោះនៅលើគេហទំព័រ កម្មវិធីសម្រាប់ការសិក្សានៅផ្ទះ កម្មវិធីថ្នាក់សិក្សាថ្ងៃអាទិត្យ/ក្រុមជួបជុំគ្នានៅតាមផ្ទះ និងការថ្វាយបង្គំផ្ទាល់ខ្លួន។ អ្វីៗដែលលោកអ្នកត្រូវការ មាននៅក្នុងសៀវភៅនេះ។

សៀវភៅនេះពន្យល់ការធ្វើដំណើរទាំងមូល និងដាក់បញ្ចូលការណែនាំ ព្រមទាំងឯកសារទាំងអស់សម្រាប់ការសិក្សា ការបង្រៀន សិក្ខាសាលា ការថ្វាយបង្គំផ្ទាល់ខ្លួន និងកម្មវិធីផ្សេងទៀត។ *សៀវភៅនេះត្រូវបានរៀបចំឡើង ដើម្បីនាំលោកអ្នកចូលទៅក្នុងព្រះគម្ពីរ មិនមែនអានព្រះគម្ពីរសម្រាប់ខ្លួនលោកអ្នកទេ* ក៏មិនមែនជាអត្ថបទអានប្រចាំថ្ងៃជំនួសព្រះគម្ពីរដែរ។ សៀវភៅនេះគឺជាផែនទី ដែលមានសម្មតិកម្ម និងកំណត់ត្រាសិក្សាសម្រាប់ការធ្វើដំណើររបស់លោកអ្នក មិនមែនទឹកដីដែលលោកអ្នកត្រូវទៅលេងទេ។ ការអានព្រះគម្ពីរផ្ទាល់ពន្យល់អំពីកំណត់ត្រានៅក្នុង ទបនគ ដែលបានបង្រួមយ៉ាងខ្លីនេះ!

## ទេវសាស្ត្រនៅក្នុងព្រះគម្ពីរតាមសណ្ឋានរូបភាព

តើមានអ្វីកើតឡើង ប្រសិនបើមនុស្សធម្មតាបានបើកសៀវភៅមួយដោយចៃដន្យ ដែលមានអត្ថបទទាំងអស់របស់លោក សេកស្ពៀ ហើយព្យាយាមយល់តែមួយបន្ទាត់ ឬតែមួយប្រយោគ? ពួកគេនឹងមានគំនិតដែលផ្ដេសផ្ដាសខ្លាំងណាស់។តើមានអ្វីកើតឡើង នៅពេលដែលយើងអានព្រះគម្ពីរ ដោយមិនមានសណ្ដាប់ធ្នាប់ពាក់ព័ន្ធគ្នា ដែលជាទិដ្ឋភាពរឿងទាំងមូលនោះ? យើងមានគំនិតផ្ដេសផ្ដាសដូចគ្នា។ ដោយពុំមានសេចក្ដីសង្ខេបទេ យើងព្យាយាមដកស្រង់យក«មេរៀនសីលធម៌»និង«គោលការណ៍សម្រាប់ជីវិតរស់នៅ» សម្រាប់ជីវិតរស់នៅរបស់យើង។ តើលោកសេកស្ពៀមានអារម្មណ៍យ៉ាងដូចម្ដេចចំពោះវិធីសាស្ត្រដ៏លេលាក្នុងការបកស្រាយកំណាព្យរបស់លោក? តើព្រះជាម្ចាស់ប្រាកដជាមានព្រះហឫទ័យយ៉ាងដូចម្ដេច នៅពេលដែលយើងបកស្រាយលេលាចំពោះរឿងដ៏ជាស្នាដៃឯកយ៉ាងល្អរបស់ព្រះអង្គ?«មេរៀន» ខុសទាំងអស់។

ទន្លេប្រាំពីរនៃព្រះគុណ (ទបនគ) បង្ហាញរបៀបដែលរឿងរ៉ាវរយនៅក្នុងព្រះគម្ពីរគឺជាឈុតនៅក្នុងរឿង–ប្រធានបទធំប្រាំពីរ ដែលហូរកាត់ព្រះគម្ពីរទាំងមូល។ លោកអ្នកនឹងមើលឃើញរបៀបដែល *រឿងទាំងអស់ត្រូវគ្នា*។ ទន្លេប្រាំពីរនៃព្រះគុណបង្រៀនទេវសាស្ត្រតាមរបៀបដែលព្រះគម្ពីរបង្រៀន មិនមែនតាមបែបទេវសាស្ត្រលក្ខណៈជាប្រព័ន្ធទេ តែតាមរយៈរឿងដែលប្រទាក់គ្នា ដែលលាតត្រដាងពីមួយទៅមួយ ពីបុព្វបុរសទៅនិក្ខមនំ ពីលោកម៉ូសេទៅស្ដេចដាវីឌពីអ្នកសរសេរទំនុកតម្កើងទៅពួកហោរា ពីការនិរទេសទៅប្រជារាស្ត្រដែលនៅសល់ រហូតទៅដល់រឿងទាំងអស់រួមគ្នានៅក្នុងព្រះយេស៊ូវ បន្ទាប់មក ហូរទៅដល់ក្រុមជំនុំរបស់ព្រះអង្គ និងទីបញ្ចប់ទៅដល់ផ្ទះវិញ!

ទេវសាស្ត្រមានលក្ខណៈត្រឹមត្រូវទាំងស្រុង ជាប្រវត្តិសាស្ត្រ ត្រូវតាមព្រះគម្ពីរ និងត្រូវតាមគោលលទ្ធិពីមុនទាំងអស់។ដូច្នេះហើយអ្នកចូលរួមសិក្សា ទបនគ ស្ទើរតែគ្រប់គ្នា ឃើញថា ទស្សនៈនេះគួរឱ្យភ្ញាក់ផ្អើល និងរីករាយខ្លាំងណាស់។ ហេតុអ្វី? ដូចជាស្នាដៃកាលពីមុនទាំងនោះ *ទបនគ ផ្តោតលើព្រះយេហូវ៉ា ដ៏ជាព្រះផ្ទាល់*។ គ្រិស្តបរិស័ទ នៅពេលបច្ចុប្បន្នកំរផ្តោតលើព្រះជាម្ចាស់ណាស់។ យើងចាប់អារម្មណ៍តាមវប្បធម៌ជាមួយអំណាចរបស់វិទ្យាសាស្ត្រ និងគំនិតស្រមៃស្រមៃចង់គ្រប់គ្រង ដូច្នេះហើយយើងអានព្រះគម្ពីរដើម្បី«ប្រមូលគោលការណ៍» និង«ដកស្រង់ការអនុវត្តន៍ជាក់ស្តែង»សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់យើង។ សេចក្តីសង្គ្រោះ និងការញែកចេញជាបរិសុទ្ធ ត្រលប់ជានិទានកថាអំពីខ្លួនយើង និងការស្វែងរកសម្រាប់ខ្លួនយើង ជាជាងជាល្ខោនអំពីចក្រវាឡរបស់ព្រះជាម្ចាស់។ យើងធ្វើឱ្យព្រះគម្ពីរទៅជា«ជំនួយ» និង «មានប្រយោជន៍»ប៉ុន្តែគួរឱ្យធុញទ្រាន់។ យើងធ្វើឱ្យខ្លួនយើងទៅជាចំណុចកណ្តាល និងដាក់ព្រះគម្ពីរឱ្យ(ក្លាយជាកម្មបទ) បម្រើយើង។ ផ្ទុយទៅវិញ ព្រះគម្ពីរពេលដែលអាន និងបង្រៀនបានត្រឹមត្រូវ នោះជម្រុញឱ្យគេស្រែកឡើង «ល្អណាស់» មិនមែនគ្រាន់តែ «ពាក់ព័ន្ធ»ប៉ុណ្ណោះទេ។ *អ្នកនិពន្ធព្រះគម្ពីរចង់ឱ្យអ្នកអានភ្លេចខ្លួនគេ នៅពេលដែលពួកគេរកឃើញ និងស្គាល់ព្រះជាម្ចាស់នៅក្នុងពេលអាន*។ ទបនគ បើកព្រះគម្ពីរជារឿងវីរកថាអំពីព្រះជាម្ចាស់ និងប្រជារាស្ត្ររបស់ព្រះអង្គ មិនមែនក្បួនយុទ្ធសាស្ត្រសម្រាប់របៀបធ្វើឱ្យព្រះជាម្ចាស់រីករាយ ឬជាសៀវភៅណែនាំសម្រាប់ធ្វើឱ្យជីវិតរបស់យើងជោគជ័យទេ (ដែលមិនធ្វើឱ្យជោគជ័យឡើយ! សូមមើល ១ កូរិនថូស ១៥:១៩!)។

ដូច្នេះហើយ ទបនគ តាមមើលព្រះវត្តមាន និងការធ្វើការរបស់ព្រះយេហូវ៉ា ដ៏ជាព្រះនៅក្នុងគ្រប់ទាំងអត្ថបទរបស់ព្រះគម្ពីរ។ នៅពេលដែលមនុស្សមើលឃើញបន្តិចម្តងៗថា ព្រះគម្ពីរគឺជាប្រលោមលោកប្រវត្តិសាស្ត្រដ៏ជាស្នាដៃឯកអំពីព្រះជាម្ចាស់ សរសេរដោយព្រះជាម្ចាស់ ពួកគេចាប់ផ្តើមញញឹម។ នៅក្នុងសិក្ខាសាលា ទបនគ ខ្ញុំសម្លឹងមើលទឹកមុខមនុស្សផ្លាស់ប្តូរនៅពេលដែលពួកគេមើលឃើញរឿងទាំងអស់វេញចូលគ្នាបន្តិចម្តងៗ ហើយមើលឃើញព្រះអង្គ។

` ពួកគេរកឃើញថា:

- យើងគ្រាន់តែជាតួរង ដែលមកយឺតនៅក្នុងរឿងមនោសញ្ចេតនាដ៏អស្ចារ្យនៅក្នុងចក្រវាឡ ដែលជួនជាបានទទួលមរតក។
- ព្រះជាម្ចាស់ធំឧត្តម ធ្វើការ សប្បុរស ព្រះអង្គជាព្រះដ៏អស្ចារ្យដែលមានសេចក្តីស្រឡាញ់ មានសមត្ថភាព និងបានកំចាយឈាមនៅពីលើ ពីក្រោម ពីក្រោយ និងនៅជុំវិញទាំងអស់។
- ព្រះគម្ពីរគឺជាវីរកថា មិនមែនជាគម្ពីរសាសនា ដូចជាគូ៉ានានោះទេ។
- សេចក្តីសង្គ្រោះ និងការញែកចេញជាបរិសុទ្ធ ព្រះរាជសារ រឿងមិនមែននិយាយអំពីខ្ញុំទេ ហើយចុងបញ្ចប់ក៏មិនមកដល់ខ្ញុំដែរ។ ព្រះមហាក្សត្រនឹងយាងមក។

នៅពេលដែលមនុស្សទទួលស្គាល់ភាពសំខាន់ ភាពអស្ចារ្យ និងសោភ័ណភាពរបស់ព្រះជាម្ចាស់ ពួកគេអនុវត្តអត្ថបទគម្ពីរចូលមកក្នុងជីវិតរបស់ពួកគេ ដោយចិត្តរីករាយ និងមានបំណងចូលរួមនៅក្នុងពិធីរាំនៃសេចក្តីស្រឡាញ់របស់ព្រះត្រីឯក។ប្រាកដណាស់ យើងត្រូវបានបំផ្លាស់បំប្រែមិនមែនដោយការប្តេជ្ញាចិត្ត និងវិន័យរបស់យើងទេ ប៉ុន្តែនៅពេលដែលយើងសម្លឹងមើលព្រះយេស៊ូវ ហើយមើលឃើញព្រះហឫទ័យ និងប្រវត្តិសាស្ត្ររបស់ព្រះអង្គ (២ កូរិនថូស ៣:១៨)។

## តើសិក្ខាសាលា ថ្នាក់សិក្សា ឬការថ្វាយបង្គំប្រចាំថ្ងៃរបស់ ទបនគ ប្រព្រឹត្តទៅយ៉ាងដូចម្ដេច?

ចូរមើលផ្ទាំងធំពីខាងឆ្វេងទៅខាងស្ដាំ ម្ដងមួយជួរដេក របៀបដែលលោកអ្នកអានសៀវភៅ។ ចូរគិតដល់ផ្ទាំងធំនោះជារឿងតុក្កតាវីរកថាប្រាំបី ដែលរឿងនីមួយៗបន្តរហូតដល់ចប់ ជួរដេកនីមួយៗនៅពីក្រោយប្រធានបទមួយផ្សេង ជួរដេកនីមួយៗមានរយៈពេលរាប់ពាន់ឆ្នាំ ប៉ុន្តែជួរដេកនីមួយមានតួអង្គតែមួយ បរិបទតែមួយ និងសម័យកាលតែមួយចុះក្រោមតាមជួរបញ្ឈរ។

- ជួរដេកផ្នែកខាងលើប្រាប់រឿងទាំងមូលរបស់ព្រះគម្ពីរជា ២៤ ដុំធំៗ។ ជួរដេកផ្នែកខាងលើនេះផ្ដល់ឱ្យមនុស្សមានទំពក់-សម័យកាល សម្រាប់ព្យួររឿង កំណាព្យ សំបុត្រ និងសេចក្ដីបង្រៀនដែលកើតឡើងនៅលើទំព័រនីមួយៗនៅក្នុងព្រះគម្ពីរ។
- ជួរដេកផ្សេងៗដទៃទៀតប្រាប់រឿងប្រធានបទ–ទន្លេមួយ ដែលព្រះយេហូវ៉ាដ៏ជាព្រះ បានវេញចូលក្នុងរឿងធំធ្វើឱ្យរឿងនោះកើតឡើង ម្ដងហើយម្ដងទៀត កាន់តែប្រសើរឡើងៗ។

ទបនគ អាចធ្វើជាសិក្ខាសាលាមួយថ្ងៃដែលមានរយៈពេល ~៨ ម៉ោង ឬ ៨-១០ សប្ដាហ៍ (~មួយជួរដេកមួយសប្ដាហ៍) ឬច្រើនជាង ~១០០ ថ្ងៃ ឬ សប្ដាហ៍ ប្រសិនបើលោកអ្នកសិក្សាលម្អិតខ្លាំងលើគំនូរនីមួយៗ មិនមែនគ្រាន់តែមើលគំនូរទាំងនោះយ៉ាងលឿនទេ។ សម្រាប់ថ្នាក់សិក្សានៅផ្ទះ ឬការថ្វាយបង្គំប្រចាំថ្ងៃ លោកអ្នកអាចសិក្សាបានមួយថ្ងៃមួយទំព័រចេញពីសៀវភៅនេះ (ទោះបីជាជួរដេកផ្នែកខាងលើ សិក្សាទាំងអស់ក្នុងពេលតែម្ដង នោះប្រសើរជាង និងពីរបីដងថែមទៀត)។គំនូរនីមួយៗមានទំហរយៈពេល ~១០-២០ នាទី។ ប្រឡោះដែលនៅទំនេរសម្រាប់ការឆ្លុះបញ្ចាំងរបស់លោកអ្នក កំណត់ត្រាសិក្សា និងការអធិស្ឋានរបស់លោកអ្នក។

មនុស្សរៀនបានលឿនបំផុត និងជ្រាលជ្រៅបំផុតតាមរយៈការត្រូវបង្រៀន។ នៅឯសិក្ខាសាលា អ្នកសម្របសម្រួលចែកគំនូរទាំង ២៤ របស់ជួរដេកខាងលើ (ទំព័រ ៧-៣០) នៅក្នុងចំណោមសិក្ខាកាមដែលចូលរួម ដោយសុំឱ្យម្នាក់ៗ/មួយគូរៗ/មួយក្រុមៗ សិក្សាគំនូររបស់ពួកគេរយៈពេល ៥ នាទី បន្ទាប់មកនិយាយអំពីគំនូរនោះប្រាប់មនុស្សគ្រប់គ្នា។ (ជាក្រុមតូចជាង ឬជាគូរ ចែករូប២៤ ទៅតាមនោះ)។ បន្ទាប់មក អ្នកសម្របសម្រួលនិយាយអំពីទន្លេ«ជីវិត» (ទំព័រ ៣១-៤១) រយៈពេល~ ៤០ នាទី ដើម្បីបង្ហាញរបៀបសិក្សាទន្លេនីមួយៗ។ បន្ទាប់មក សិក្ខាកាមត្រូវបានចែកឱ្យគំនូរ*ទាំងអស់*ដែលនៅសល់ (ទំព័រ ៤៤+) មួយទន្លេម្ដង ដោយម្ដងៗអនុញ្ញាតឱ្យមានការរៀបចំ ១០ នាទី បន្ទាប់មក ឡើងនិយាយគំនូរនីមួយៗ ៥ នាទី។សិក្ខាសាលាត្រូវការអ្នកចូលរួម ៨-១៦ នាក់ ដើម្បីឱ្យដំណើរការទៅបានប្រសើរ (សម្រាប់គំនូរ ៨ក្នុងជួរដេកនីមួយៗ) ហើយនៅក្នុងក្រុមធំជាងនេះ នោះអស្ចារ្យដើម្បីឱ្យអាចសិក្សាគំនូរ/ទំព័រនីមួយៗ ជាពីរៗនាក់ ឬជាក្រុម។ (បើកាន់តែច្រើន គេអាចបំបែកដូចដែលបានបង្ហាញនៅលើទំព័រដែលពាក់ព័ន្ធ)។ ជួរដេកនីមួយៗត្រូវបានសិក្សាជាខ្សែរឿងតែមួយ ដោយអ្នកសម្របសម្រួល«ដេរភ្ជាប់»រឿងនោះចូលគ្នា។

នៅក្នុងអំឡុងពេលសិក្ខាសាលា អ្នកសម្របសម្រួលណែនាំគំនូរនីមួយៗ ដោយនិយាយថា «ឥឡូវនេះពេលមកដល់សម័យ [បង្គោលផ្ដល់ព័ត៌មាននៅពីលើគំនូរដែលពាក់ព័ន្ធ] .នោះព្រះយេហូវ៉ា ដ៏ជាព្រះ បានធ្វើឱ្យប្រធានបទ–ទន្លេ [ប្រធានបទដែលនៅខាងឆ្វេងដៃលើផ្ទាំងធំ] សម្រេចឡើងតាមរបៀបដូចតទៅ...»។ សិក្ខាកាម–អ្នកឡើងនិយាយប្រាប់រឿងនៅក្នុងគំនូរ អានបទគម្ពីរមួយចំនួនដែលពាក់ព័ន្ធ និងពន្យល់កិច្ចការរបស់ព្រះយេ-ហូវ៉ានៅក្នុងទន្លេមួយនោះ។ អ្នកសម្របសម្រួលបញ្ចប់ដោយនិយាយថា «...ដូច្នេះហើយ នោះគឺជារបៀបមួយ/មួយចំនួន ដែលព្រះយេហូវ៉ាបានសម្រេចប្រធានបទ–ទន្លេ [ប្រធានបទ] នៅក្នុងសម័យកាល [បង្គោលផ្ដល់ព័ត៌មានសម័យកាល]»។

នៅឯសិក្ខាសាលា ចូរប្រាប់មនុស្សកុំឱ្យព្រួយ នៅពេលដែលពួកគេទទួលបានព័ត៌មានយ៉ាងច្រើនលើសលប់។ មានព័ត៌មានថ្មីច្រើនជាងដែលយើងដឹង។ក៏សុំសិក្ខាកាមកុំឱ្យអធិប្បាយ គ្រាន់តែនិយាយរឿងនៅក្នុងសន្លឹកក្រដាសរបស់ពួកគេ។សន្លឹកក្រដាសនីមួយៗមានពណ៌ មានអត្ថន័យ និងសោភ័ណភាពសម្រាប់នឹងអធិប្បាយត្រឹមនោះ។ គ្រូអធិប្បាយ និងអ្នកសីលធម៌និយមជាច្រើនពិបាកយ៉ាងខ្លាំងជាមួយនឹងការធ្វើបែបនេះ ប៉ុន្តែការបូកបន្ថែមជាញឹកញាប់ដកចេញវិញ។

អ្នកសម្របសម្រួល ទបនគ គឺឱ្យសិស្សនិយាយកម្មវិធីទាំងមូល និងធ្វើការផ្សាភ្ជាប់ «អាំហា!» ដោយខ្លួនពួកគេ។ ទោះបីយ៉ាងណាក៏ដោយ អ្នកសម្របសម្រួលគួរតែអាចសង្ខេបរូបភាពនីមួយៗ ដើម្បីឱ្យពួកគេអាចជួយសិក្ខាកាមដែលវង្វេង រៀបចំលើកទឹកចិត្តសិក្ខាកាម ប្រសិនបើពួកគេវង្វេង ឬនិយាយមិនចេញ បន្ថែមទៅលើការឡើងនិយាយដែលមិនគ្រប់គ្រាន់ និងកែកំហុសឆ្គង! ប្រសិនបើមិនមានមនុស្ស ឬពេលវេលាមិនគ្រប់គ្រាន់ អ្នកសម្របសម្រួលអាចបង្រៀនរូបភាព ឬជួរដេកលឿនជាងមុន។ ចូរទុកពេលវេលាយ៉ាងហោចណាស់ម្ភៃនាទីនៅចុងបញ្ចប់សម្រាប់សំណួរឆ្លុះបញ្ចាំងចុងក្រោយ (ទំព័រ ១០៩)។

## ក្រឡាចត្រង្គ ទបនគ - តើក្រឡានាំងអស់ត្រូវគ្នាយ៉ាងដូចម្តេច?

លោកអ្នកអាចមើលឃើញចេញពីផ្ទាំងធំថា នោះជាក្រឡាចត្រង្គដ៏ធំមួយដែលមានរាងចតុកោណកែង។ ជួរដេកតំណាងឱ្យ«ទន្លេ» ហើយជួរបញ្ឈរតំណាងឱ្យ «សម័យកាល»។ សម័យកាលគឺជាបង្គោលផ្តល់ព័ត៌មាននៅក្នុងប្រវត្តិសាស្ត្រព្រះគម្ពីរ ហើយទន្លេប្រាំពីរគឺជាប្រធានបទរឿងធំដែលហូរកាត់ព្រះគម្ពីរទាំងមូល។ (ដូច្នេះ *សម័យកាល* រត់កាត់ផ្នែកខាងលើ ហើយ *ប្រធានបទ* ប្រាំពីរនៅក្នុងព្រះគម្ពីររត់ពីលើចុះក្រោមនៅផ្នែកខាងឆ្វេង)។ គំនូរនៅត្រង់ចំណុចប្រសព្វនីមួយៗ បង្ហាញរបៀបដែលប្រធានបទនីមួយៗ(ជួរដេក)ត្រូវបានអភិវឌ្ឍន៍ និងសម្រេចនៅក្នុងសម័យនីមួយៗនៅក្នុងព្រះគម្ពីរ(ជួរបញ្ឈរ)។ ប្រសិនបើលោកអ្នកគិតដល់ «**ស៦**» លោកអ្នកនឹងនិយាយយ៉ាងដូចនេះ «នៅសម័យ **ស** ក្នុងប្រវត្តិសាស្ត្រ តើព្រះជាម្ចាស់បានសម្រេចប្រធានបទ ៦ យ៉ាងដូចម្តេច?»។

លទ្ធផលចុងក្រោយគឺជាការធ្វើដំណើរមើលឃើញផ្ទាល់នឹងភ្នែកឆ្លងកាត់ប្រវត្តិសាស្ត្រនៅក្នុងព្រះគម្ពីរ រកឃើញថា *នៅលើគ្រប់ទំព័រទាំងអស់របស់ព្រះគម្ពីរ* ព្រះយេហូវ៉ា ដ៏ជាព្រះ កំពុងស្អាងឡើងវិញបន្តិចម្តងៗនូវព្រះពរទាំងអស់ដែលបានបាត់បង់នៅក្នុងសួនច្បារអេដែន និងកំពុងបំផ្លាស់បំប្រែពួកគេឱ្យទៅជាអ្វីដែលអស្ចារ្យលើសជាងអ័ដាម និងនាងអេវ៉ាអាចនឹកគិតដល់ទៅទៀត។

## ប្រធានបទ—ទន្លេ និងសម័យកាលពេលវេលា

ប្រធានបទ–ជួរដេកនីមួយៗក្នុងចំណោមប្រធានបទ–ជួរដេកប្រាំមួយដំបូងតំណាងឱ្យអំណោយទានដែលមានមុនពេលដែលមនុស្សធ្លាក់ចុះ បានបាត់បង់នៅពេលមនុស្សធ្លាក់ចុះ ប៉ុន្តែដោយសារព្រះគុណរបស់ព្រះជាម្ចាស់ចេញពីលោកុប្បត្តិ៣:១៥ ត្រូវបានចាប់ផ្តើមស្អាងឡើងវិញបន្តិចម្តងៗតាមរយៈប្រវត្តិសាស្ត្រនៃសេចក្តីសង្គ្រោះ។ ប្រធានបទទីប្រាំពីរមិនត្រូវបានស្គាល់នៅក្នុងសួនច្បារអេដែនទេ សូម្បីតែទេវតាក៏មិនដឹងផង ហើយអាចបើកសម្តែងឱ្យឃើញតែនៅក្រោយពេលដែលមនុស្សធ្លាក់ចុះ...និងក្រោយយូរមកទៀត!

ទន្លេប្រាំពីរត្រូវបានប្រាប់ឈ្មោះនៅជួរបញ្ឈរដែលនៅខាងឆ្វេងបំផុតនៅលើផ្ទាំងធំ និងនៅខាងក្រោមនេះ ហើយសម័យកាលទាំង ២៤ ត្រូវបានប្រាប់ឈ្មោះជាអក្សរឆ្លាក់នៅទំព័រ ៦។ ទំព័រ ៦ បង្ហាញ និងសង្ខេបក្រឡាចត្រង្គពេញចូលគ្នាដែលហូរកាត់ជួរដេកនីមួយៗពីខាងឆ្វេងទៅខាងស្តាំ។ នេះគឺជាការសង្ខេបកម្រិតខ្ពស់សម្រាប់ធ្វើ

ការបង្ហាញបង្គោលផ្ដល់ព័ត៌មាននៅស្របតាមបណ្ដោយជួរដេកផ្នែកខាងលើ (ប ១-ប ២៤) ដែលត្រូវបានពណ៌នាពីទំព័រ ៧ -៣០។ វាជាការឈ្លាសវៃក្នុងការអានទំព័រ ៦ មុនពេលសិក្សា ក្នុងអំឡុងពេលសិក្សា និងក្រោយពេលសិក្សាទំព័រ ៧-៣០!

*ទន្លេប្រាំពីរនៃព្រះគុណមាន:*

ទន្លេទី ១ **ជីវិត:** អ័ដាម និងនាងអេវ៉ាត្រូវបានផ្លុំខ្យល់ដង្ហើមចូលទៅ ហើយត្រលប់ជាមានជីវិតឡើង ដោយចំនឹងរូបអង្គរបស់ព្រះយេហូវ៉ា។

ទន្លេទី ២ **ការសម្រាក:** រួមជាមួយកិច្ចការល្អដែលពួកគេត្រូវបានប្រទានឱ្យធ្វើ មានសេចក្ដីសុខសាន្ត និងការសម្រាកនៅក្នុងសួនច្បារ ដោយអ័ដាម និងនាងអេវ៉ាដើរលេងនៅក្នុងសួនសប្បាយរបស់ព្រះយេហូវ៉ានៅពេលរសៀល។

ទន្លេទី ៣ **ការគ្រប់គ្រង:** អ័ដាម និងនាងអេវ៉ាត្រូវបានប្រទានឱ្យមានអំណាចលើស្នាព្រះហស្ដទាំងអស់ក្នុងនាមជាអ្នកតំណាងរបស់ព្រះជាម្ចាស់ ដើម្បីដាក់ឈ្មោះឱ្យ ប្រើ មានអំណរជាមួយ និងគ្រប់គ្រង។

ទន្លេទី ៤ **ព្រះពរ:** អ័ដាម និងនាងអេវ៉ាមានព្រះពរគ្រប់យ៉ាង។ អត្ថបទជាភាសាហេព្រើរសង្កត់ធ្ងន់អំពីលក្ខណៈនៃការប្រកាស និងការអញ្ជើញរបស់ព្រះជាម្ចាស់សម្រាប់ពួកគេ ។

ទន្លេទី ៥ **ភាពបរិសុទ្ធ:** គ្មានអំពើបាបទេ មានតែភាពស្អាត និងភាពគ្មានកំហុសដោយនៅអាក្រាតនៅក្នុងសួនច្បារមុនពេលមានការវាយប្រហាររបស់សត្វពស់។

ទន្លេទី ៦ **មិត្តភាព:** អ័ដាម និងនាងអេវ៉ាមានការប្រកបគ្នាយ៉ាងជិតស្និទ្ធជាមួយព្រះយេហូវ៉ា ជាឪពុករបស់ពួកគេនៅក្នុងសួនសប្បាយរបស់ព្រះអង្គ។

ទន្លេទី ៧ **?** អំណោយទានប្រកបដោយព្រះគុណរបស់ព្រះយេហូវ៉ា ដ៏ជាព្រះ (...រង់ចាំ...!)

*សម័យកាល ឬព្រឹត្តិការណ៍ផ្ដល់ព័ត៌មាននៅក្នុងព្រះគម្ពីរមាន:*

**ការបង្កើតលោក** ***ការធ្លាក់ចុះ*** **សេចក្ដីសន្យា** ***ទឹកជំនន់*** **បុព្វបុរស** ***ទាសភាព*** **និក្ខមនំ និងការវាយដណ្ដើមបាន** ***អនាធិបតេយ្យ*** **ស្ដេច** ***ការថ្វាយបង្គំរូបព្រះ*** **ព្យាការី** ***ភាពលេលា*** **ពួកហោរា** ***ការនិរទេស*** **ប្រជារាស្ត្រដែលនៅសល់** ***ភាពស្ងប់ស្ងាត់*** **ព្រះយេស៊ូវ** ***ឈើឆ្កាង*** **ការមានព្រះជន្មរស់ឡើងវិញ** **ក្រុមជំនុំ** ***ថ្ងៃចុងក្រោយ*** **ដំណឹងល្អទៅដល់ជនជាតិនានា** ***ការជំនុំជម្រះ*** **ការបង្កើតថ្មីៗ**

សម័យកាលត្រូវបានបង្ហាញតាមលក្ខណៈជាគូ ឡើង–និង-ចុះ ដើម្បីឆ្លុះបញ្ចាំងពីវាសនាដែលតែងតែផ្លាស់ប្ដូរជានិច្ចរបស់ប្រជារាស្ត្ររើសតាំង។ នេះគឺជាចង្វាក់ល្បោននៃរឿងទាំងមូលនៅក្នុងព្រះគម្ពីរ។ ព្រះយេហូវ៉ា ដ៏ជាព្រះ និងជាអ្នកនិពន្ធដែលបានចូលរួមសម្ដែងជាមួយយ៉ាងស្និទ្ធស្នាល (សូមមើលបង្គោលផ្ដល់ព័ត៌មានជាអក្សរឆ្លាក់) បានសរសេរការវាយឈ្នះរបស់អារក្សសាតាំង (*អក្សរទ្រេត*)។ ចង្វាក់ទៀងទាត់នេះត្រូវបានកាត់ផ្ដាច់ នៅពេលដែល**ក្រុមជំនុំ**នៅខាងក្រោយបន្ទាប់ពី**ការមានព្រះជន្មរស់ឡើងវិញ** ដោយមិនមានការធ្លាក់ចុះនៅកណ្ដាលទេ។ នេះបង្ហាញថា សមត្ថភាពរបស់អារក្សសាតាំងក្នុងការត្រលប់មកវាយបកការល្អវិញ ត្រូវបានបំផ្លាញដោយសារឈើឆ្កាង និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ។ អារក្សសាតាំងដេញតាមមកមិនទាន់ម្ដងទៀតទេ។

# ព្រះគម្ពីរ ១០១: ទន្លេហូរឡើងចុះឆ្លងកាត់សម័យកាល

**ការបង្កើតលោក** គឺជាបទភ្លេងចាប់ផ្ដើមរបស់ព្រះយេហូវ៉ា ដ៏ជាព្រះ សម្បូរបែប មានសណ្ដាប់ធ្នាប់ មានភាពស្មុគស្មាញមានភាពរស់រវើក និងមានសោភ័ណភាព។ ព្រះអង្គបានប្រទានទាំងអស់នេះឱ្យកូនរបស់ព្រះអង្គ!

*ប៉ុន្តែអ័ដាម និងនាងអេវ៉ា* ***ធ្លាក់ចុះ*** *ដោយសារទុកចិត្តលើអារក្សសាតាំង ក្បត់ព្រះយេហូវ៉ា និងបោះបង់ចោលទន្លេនៃព្រះពរទាំងអស់របស់ព្រះយេហូវ៉ាសម្រាប់យើងទាំងអស់គ្នា។* សម្រាប់ហេតុផលដែលត្រូវបានលាក់កំបាំងនៅក្នុងព្រះអង្គទ្រង់ ព្រះយេហូវ៉ាតាំងព្រះហឫទ័យស្ដាងអ្វីៗទាំងអស់ដែលបានបាត់បង់ ប្រោសអ្វីដែលបែកបាក់ឱ្យជាឡើងវិញ និងសម្រេចអ្វីៗទាំងអស់ដែលបានយល់សប្ដិឃើញនៅស្ថានសួគ៌...ដូច្នេះព្រះអង្គមានបន្ទូលជា**សេចក្ដីសន្យា** ទីមួយប្រកបដោយព្រះគុណ!

ប៉ុន្តែអំពើបាបកាន់តែរីកសាយភាយឡើង *រហូតដល់* ***ទឹកជំនន់*** *សម្អាតផែនដី។* ប៉ុន្តែ ព្រះយេហូវ៉ាមានបន្ទូលសេចក្ដីសន្យាដ៏ប្រសើរជាច្រើនថែមទៀតទៅកាន់លោកណូអេ លោកអ័ប្រាហាំ និងលោកយ៉ាកុប។ បន្ទាប់មកព្រះអង្គប្រទានប្រធានបទ–ទន្លេនីមួយៗដល់មនុស្សតែម្នាក់ប៉ុណ្ណោះ គឺលោកអ័ប្រាហាំ បន្ទាប់មកដល់កូនរបស់គាត់ ចៅរបស់គាត់ និងចៅទួតរបស់គាត់ គឺ **បុព្វបុរស** (នៅក្នុងកណ្ឌគម្ពីរលោកុប្បត្តិ)។

*ប៉ុន្តែ អំណោយទាន–ទន្លេទាំងនេះបានបាត់បង់ទាំងអស់នៅក្នុង* ***ទាសភាព*** *នៅរាជ្យស្ដេចផារ៉ោន* រហូតដល់ព្រះយេហូវ៉ាសម្រេចអំណោយទាន–ទន្លេនីមួយៗសម្រាប់មនុស្សមួយក្រុមនៅក្នុង **និក្ខមនំ និងការវាយដណ្ដើមបាន** នៅក្រោមការដឹកនាំរបស់លោកម៉ូសេ និងលោកយ៉ូស្វេ។

ប៉ុន្តែទន្លេព្រះពរបានបាត់បង់ម្ដងទៀតនៅក្នុងសម័យ***អនាធិបតេយ្យ*** *ស្របជាមួយពួកចៅហ្វាយ* រហូតដល់ព្រះយេហូវ៉ាសម្រេចគ្រប់ទន្លេទាំងអស់នៅលើផែនដីក្រោមរាជ្យ **ស្ដេច** ដ៏អស្ចារ្យរបស់អ៊ីស្រាអែល(ចៅហ្វាយ–សាំយូអែល–១ ពង្សាវតារក្សត្រ ១០ និង១ របាក្សត្រ - ២ របាក្សត្រ ៩)។

*ប៉ុន្តែទន្លេត្រូវបានបាត់បង់ទៅក្នុង* ***ការថ្វាយបង្គំរូបព្រះ*** *របស់អ៊ីស្រាអែល (១ ពង្សាវតារក្សត្រ ១១+/ ២ របាក្សត្រ ១០+)* ទោះបីជាព្រះអង្គបានបើកសម្ដែងឱ្យឃើញទន្លេនីមួយៗនៅក្នុងកណ្ឌគម្ពីរ **ប្រាជ្ញា** ក៏ដោយ (ទំនុកដំកើង សុភាសិត ។ល។)។

*ប៉ុន្តែទន្លេទាំងនេះបានបាត់បង់ម្ដងទៀតដោយសារ* ***ភាពលេលា*** *របស់អ៊ីស្រាអែល*រហូតដល់ព្រះយេហូវ៉ាគូរគំនូរ និងច្រៀងអំពីទន្លេនីមួយៗតាមរយៈ **ពួកហោរា** (អេសាយ យេរេមា អេសេគាល ។ល។)។

*ប៉ុន្តែទាំងអស់នេះបានបាត់បង់ទៅម្ដងទៀតនៅក្នុងភាពងងឹតនៃ* ***ការនិរទេស*** *ទៅក្រុងបាប៊ីឡូន* រហូតដល់ព្រះយេហូវ៉ានាំយកទន្លេនីមួយៗត្រលប់មកឱ្យសហគមន៍ **ប្រជារាស្ត្រដែលនៅសល់** (អែសរ៉ា នេហេមា ហាកាយ ។ល។)។

*ប៉ុន្តែទាំងអស់នេះរលាយបាត់ទៅនៅក្នុងរយៈពេល* ***ភាពស្ងប់ស្ងាត់*** *៤០០ ឆ្នាំ* រហូតដល់ព្រះយេហូវ៉ាសម្រេចទន្លេទាំងអស់នេះ និងមានរូបរាង បរិសុទ្ធ និង??? នៅក្នុង **ព្រះយេស៊ូវ** ជាព្រះមួយរយភាគរយ–ជាមនុស្សមួយរយភាគរយ (ម៉ាថាយ–យ៉ូហាន)!

*ប៉ុន្តែអារក្សសាតាំង និងមនុស្សសម្លាប់អ្នកដែលទន្លេទាំងប្រាំពីរនៃព្រះគុណ គឺព្រះយេស៊ូវ នៅលើ* ***ឈើឆ្កាង*** ប៉ុន្តែព្រះយេហូវ៉ាបង្ហាញថាព្រះយេស៊ូវសុចរិតតាមរយៈ **ការមានព្រះជន្មរស់ឡើងវិញ** របស់ព្រះអង្គ ហើយតាមរយៈជ័យជម្នះរបស់ព្រះអង្គលើគ្រប់ទាំង «ប៉ុន្តែ» មកពីអារក្សសាតាំងព្រះយេហូវ៉ាបង្ហូរទន្លេទាំងអស់ចូលក្នុងចិត្តប្រជារាស្ត្ររបស់ព្រះអង្គ គឺ **ក្រុមជំនុំ** តាមរយៈព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ (កិច្ចការ+)។

*ប៉ុន្តែអារក្សសាតាំងនៅតែវាយប្រហារទន្លេទាំងអស់នៅ* ***ថ្ងៃចុងក្រោយ*** *របស់វា រហូតដល់*ព្រះយេហូវ៉ាបើកទន្លេទាំងអស់ដល់ **ជនជាតិនានា** ទាំងអស់។

*ប៉ុន្តែ* ***ការជំនុំជម្រះ*** នឹងធ្លាក់មកលើខ្មាំងសត្រូវទាំងអស់របស់ព្រះជាម្ចាស់...រហូតដល់ព្រះយេហូវ៉ាបំផ្លាញទន្លេទាំងអស់នៅក្នុង **ការបង្កើតថ្មី** របស់ព្រះអង្គ!




## ម ១ ការបង្កើតលោក

***ទ្រង់ពីរថ្ងៃដែលមានភាពឆ្លាតវៃ និងសេចក្តីមេត្តាករុណារបស់ព្រះយេហូវ៉ា ដ៏ជាព្រះ***

<u>លោកុប្បត្តិ ១-២:</u>

ព្រះយេហូវ៉ា ដែលជាព្រះជាម្ចាស់បានបង្កើតសាកលលោកនិងរបស់សព្វសារពើនៅក្នុងរបៀបមួយដែលមានសណ្តាប់ធ្នាប់ និងសោភ័ណភាព សម្បូរបែប និងមានសត្វមានជីវិតគ្រប់បែបយ៉ាង។ ព្រះអង្គបានប្រទានពរ និងប្រទានអំណោយទានដល់មនុស្សដែលមានរូបរាងរបស់ព្រះអង្គដើម្បីគ្រប់គ្រង បានប្រទានសួនច្បារដ៏ស្រស់ស្អាត បានយកនាងអេវ៉ាចេញពីលោកអ័ដាម និងសម្រាប់លោកអ័ដាម ឱ្យស្មើភាពគ្នា និងគ្មានភាពអៀនខ្មាសឡើយ។

*<u>ចូរប្រាកដឱ្យមើលឃើញថា:</u>*

*ព្រះយេហូវ៉ាមិនបានបង្កើត ដោយសារត្រូវការមានគ្នា ឬត្រូវការអ្នកថ្វាយបង្គំទេ។ ព្រះអង្គរីករាយដោយគ្មាន ទីបញ្ចប់រួចទៅហើយ និងមិនឯកោឡើយនៅក្នុងព្រះត្រីឯក សូម្បីមុនពេលបង្កើតទេវតាផង កុំថាទៅដល់ឡើយមនុស្ស។ ការបង្កើតគឺជាសេចក្តីសប្បុរសតែប៉ុណ្ណោះរបស់ព្រះអង្គ។ អ្នកទាំងនេះគឺជាកូនរបស់ព្រះអង្គ(លោកុ ១:២៦,លោកុ ៥:១-២,លូកា៣:៣៨)។ ព្រះអង្គកំពុងប្រទានឱ្យពួកគេមានមរតកទាំងអស់។ ព្រះអង្គមានបំណងព្រះហឫទ័យចង់មានគ្រួសារចង់ប្រទានឱ្យពួកគេមានអំណរដែលនឹកស្មានមិនដល់ ចង់មើលឃើញពួកគេរីករាយ និងនៅថ្ងៃមួយបង្កើតបានកូនក្រមុំសម្រាប់ព្រះរាជបុត្រារបស់ព្រះអង្គ។ យើងជាមនុស្សមានបាបមិនអាចយល់អំពីព្រះហឫទ័យដ៏សប្បុរសហូរហៀរ ដោយគ្មានលក្ខខណ្ឌនេះបានទេ។*



ការធ្លាក់ចុះ

## ប ២ ការធ្លាក់ចុះ

***យើងទុកចិត្តសត្វពស់ បោះបង់ព្រះយេហូវ៉ា និងទន្លេនៃព្រះពរ***

<u>លោកុប្បត្តិ ៣+:</u>

សត្វពស់ដែលជាអារក្សសាតាំងបានបោកបញ្ឆោតកូនរបស់ព្រះយេ-ហូវ៉ា ឱ្យជឿថា ព្រះយេហូវ៉ាដែលជាឪពុករបស់ពួកគេ អាក្រក់ រារាំងពួកគេយកចិត្តទុកដាក់ជាមួយដើមឈើដឹងខុសត្រូវខ្លាំងជាងដើមឈើនៃជីវិត។ កំហុសរបស់មនុស្ស ភាពអាម៉ាស់ ការលាក់បាំង ការបន្ទោស និងការសម្លាប់ ជីវិតបានកើតមក ដោយដាក់ពូជនៃសេចក្តីអាក្រក់ និងសេចក្តីស្លាប់នៅក្នុងអ្វីៗសព្វសារពើទាំងអស់។

*<u>ចូរប្រាកដឱ្យមើលឃើញថា:</u>*

*នៅពេលដែលយើងបានយល់ព្រមជាមួយសត្វពស់ បានផឹកពិសពស់ និងបានចាក់បញ្ចូលមេរោគបាបនិស្ស័យសាច់ឈាមបានដាក់ជីឱ្យភាពបែកបាក់របស់ខ្លួន។ យើងត្រលប់ទៅជាមិនមែនមនុស្ស ទៅជាសត្វដែលងាយផ្លាស់ប្តូរ ត្រេកត្រអាល មិនដឹងខុសត្រូវ ភ័យខ្លាច និងសាហាវ ល្ងីល្ងើ និងពុករលួយ។ ហេតុផល ការវិនិច្ឆ័យ បំណងប្រាថ្នា និងការគិតស្មានរបស់យើងសុទ្ធតែបានរងឥទ្ធិពល ត្រូវបានមួលបង្កាច់ រីករាលដាល និងងងឹតអាប់អួរ។ក្រោយពេលដែលសម្លេងខ្សឹបឱ្យសង្ស័យរបស់អារក្សសាតាំងបានចូលមកហើយ យើងលែងអាចគិតអំពីព្រះជាម្ចាស់ថាមិនមានលក្ខណៈមួយចំនួនរបស់អារក្សសាតាំងនៅក្នុងព្រះអង្គនោះបានទៀតហើយ។ ឥឡូវនេះ យើងតែងតែគិតថា អំពើបាបផ្តល់ជីវិត ហើយការទុកចិត្តព្រះជាម្ចាស់មានន័យថា យើងនឹងបាត់ជីវិតនោះជារៀងរហូត (លោកុ ៣:៥)។ ឥឡូវនេះ យើងគិតថាព្រះហឫទ័យរបស់ព្រះជាម្ចាស់មានល្អផង អាក្រក់ផង មិនមែនមានតែសេចក្តីស្រឡាញ់សម្រាប់គ្រួសារ និងជីវិតទេ (តើលោកុ ២:៩ នៅឯណានៅក្នុងអេវ៉ា ៣:៣?!)។ យើងទុកចិត្តសត្វពស់ និងខ្លួនយើង ដូច្នេះឃើញថា យើងមិនអាចទុកចិត្តព្រះជាម្ចាស់ដែលជាឪពុករបស់យើងបានទេ។ អារក្សសាតាំង ជាអ្នកធ្វើបាបកូនព្រះ បានអូសទាញ និងយកទ្រព្យសម្បត្តិដ៏មានតម្លៃជាងគេបំផុតរបស់ព្រះជាម្ចាស់ ដោយបំពុលសមត្ថភាពរបស់ពួកគេមិនឱ្យអាចឈ្វេងយល់អំពីសេចក្តីស្រឡាញ់របស់ព្រះអង្គដែលធ្វើឱ្យព្រះអង្គខូចព្រះហឫទ័យយ៉ាងខ្លាំង។*




## ច ៣ សេចក្តីសន្យា

***ព្រះយេហូវ៉ាចាប់ផ្តើមការផ្ទោសលោះរបស់ព្រះអង្គ***

__លោកុប្បត្តិ ៣+:__

ព្រះយេហូវ៉ាប្រកាសសង្គ្រាមរវាងព្រះអង្គ (តាមរយៈពូជនៃពូជពង្សកូនដែលមានជំនឿរបស់នាងអេវ៉ា គឺសេត) និងពូជពង្សរបស់សត្វពស់ (តាមរយៈពូជពង្សរបស់កាអ៊ីន)។ ព្រះអង្គសន្យាថា ទោះបីជាសត្វពស់នឹងចឹកកែងជើងរបស់ពូជនោះក៏ដោយ (ការវាយប្រហារមិនចេះចប់មកលើពូជពង្សរបស់សេតនិងជាពិសេសព្រះមែស៊ី) ពូជពង្សរបស់សេត (ជាពិសេស ព្រះមែស៊ី) នឹងជាន់ក្បាលរបស់សត្វពស់។ព្រះយេហូវ៉ាសម្លាប់សត្វយកស្បែក ដើម្បីគ្របបាំងភាពអាម៉ាស់ដែលកូនរបស់ព្រះអង្គមាន ដោយសារតែអំពើបាប ជានិមិត្តរូបអំពីយញ្ញបូជាជំនួសជាច្រើនទៀតដែលនឹងមាន។

__*ចូរប្រាកដឱ្យមើលឃើញថា:*__

*ព្រះអម្ចាស់ខូចព្រះហឫទ័យយ៉ាងខ្លាំង (លោកុ ៣:៨-១៥) ប៉ុន្តែទោះបីជាព្រះអង្គមានបន្ទូលថា «ដ្បិតនៅថ្ងៃណាដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន»ក៏ដោយ ព្រះអង្គបានពន្យាការស្លាប់របស់ពួកគេ បានដាក់វិន័យពួកគេ និងបានស្បថសងសឹកជាមួយអារក្សសាតាំង តាមរយៈកូនដែលវាបានបំពាន (ខ១៥)។នៅក្នុងប្រយោគដែលមិនទាន់ចប់បង្ហាញពីការយល់យ៉ាងគួរឱ្យខ្លាច (លោកុ ៣:២២) ព្រះអង្គរហ័សនឹងការពារពួកគេមិនឱ្យបរិភោគដើមឈើជីវិត ក្រែងលោពួកគេជាប់នៅក្នុងស្ថានភាពអាក្រក់របស់ពួកគេជារៀងរហូត។ ព្រះអង្គប្រទានឱ្យទាំងអ្នកជឿ និងអ្នកមិនជឿមានកូនជារហូត។ ព្រះជាម្ចាស់ថែមទាំងចេញទៅក្នុងពិភពលោកដែលបានធ្លាក់ចុះដើម្បីជួប និងការពារចៅដ៏គ្រោះថ្នាក់របស់ព្រះអង្គ (លោកុ ៤:៦-៧,៩-១៦, ៥:១-២)។*




## ច ៤ ទឹកជំនន់

***មនុស្សអាក្រក់ទាំងអស់ត្រូវបានដាក់ទោស ព្រះយេហូវ៉ាយំ***

**<u>លោកុប្បត្តិ ៣ ដល់ ១១</u>**

អ្នកសម្លាប់ជីវិតមនុស្សប្រាំពីរជំនាន់មាននៅពាសពេញផែនដីរហូតដល់«អស់ទាំងគំនិតក្នុងចិត្តគេក៏សុទ្ធតែអាក្រក់ជានិច្ចដូច្នោះ»។ ព្រះហឫទ័យរបស់ព្រះយេហូវ៉ាពោរពេញទៅដោយការឈឺចាប់អំពីសេចក្តីងងឹតរបស់យើងដែលមិនអាចព្យាបាលជា ដូច្នេះព្រះអង្គបានសំអាតសង្គមអាក្រក់របស់ពួកគេជាមួយមហាទឹកជំនន់។ ព្រះអង្គបានសង្គ្រោះលោកណូអេ និងគ្រួសាររបស់លោក ដែលជាពូជពង្សរបស់សេតជាមនុស្សស្មោះត្រង់។ បង្កើតផែនដីសារជាថ្មី។ពួកគេមានចំនួនច្រើនពាសពេញផែនដីម្តងទៀត ប៉ុន្តែពូជពង្សរបស់ពូជនេះអារ (លោកុ ១១:៣០)!

*<u>ចូរប្រាកដឱ្យមើលឃើញថា:</u>*

*តាមរយៈភ្នែកដែលត្រូវបានអំពើបាបមួលបង្កាច់ យើងតែងតែគិតថាទឹកជំនន់ជាសេចក្តីក្រោធរបស់ព្រះជាម្ចាស់។ ប្រាកដណាស់ ព្រះអង្គក្រោធត្រូវ ប៉ុន្តែបទគម្ពីរប្រាប់ដល់ទៅបីដងថា ទឹកជំនន់មកពីការខូចព្រះហឫទ័យរបស់ព្រះវរបិតា (លោកុ៦:៦-៧)។ ប៉ុន្តែដោយប្រៀបធៀបលោកុប្បត្តិ ៦:៥ ជាមួយនឹងលោកុប្បត្តិ ៨:២១ ហេតុអ្វីព្រួយព្រះហឫទ័យ? ព្រះអង្គព្រួយព្រះហឫទ័យ ពីព្រោះសម្រាប់ព្រះអង្គ ក្លិនឈ្ងុយនៅលើអាសនានោះគឺជាសេចក្តីសន្យាអំពីយញ្ញបូជានៃព្រះរាជបុត្រារបស់ព្រះអង្គនៅលើឈើឆ្កាងដែលនឹងសម្រេចសេចក្តីសន្យាដែលព្រះអង្គបានមានបន្ទូលនៅក្នុងលោកុប្បត្តិ ៣:១៥ ដូច្នេះព្រះអង្គប្រទានពរឱ្យយើងមានការបង្កើតថ្មី (លោកុ ៩:១-១៧) ហើយបង្កើតតំណវង្សពូជដែលបានសន្យាតាមរយៈ សេត (លោកុ ១០:២១, ១១:១០) រហូតមកដល់អាប៉្រាម ដែលតំណវង្សហាក់បីដូចជាឈប់។*




## ប ៥ បុព្វបុរស

***គ្រួសារមួយស្គាល់រស់ជាតិនទ្លេ***

<u>លោកុប្បត្តិ ១១ ដល់ ៥០:</u>

ព្រះយេហូវ៉ា បានជ្រើសរើសពូជមួយរបស់សេត គឺលោកអ័ប្រាហាំ ដើម្បីធ្វើជាកម្មសិទ្ធិរបស់ព្រះអង្គ ដើម្បីប្រទានពរឱ្យលោកមានជីវិតការសម្រាក ការគ្រប់គ្រង ព្រះពរ ភាពបរិសុទ្ធ និងមិត្តភាព ហើយតាមរយៈលោក ព្រះមែសី ដែលជាពូជ និងដែលជាព្រះអង្គសង្គ្រោះនឹងយាងមក។ កូនប្រុសរបស់លោក អីសាក បន្ទាប់មកយ៉ាកុប បន្ទាប់មកយ៉ូសែប បានធ្វើជាអ្នកស្នងការទុកចិត្តនេះទុកជាមរតក។ ជីវិតរបស់ពួកគេបង្ហាញប្រាប់ជាមុនអំពីអនាគតនៃជនជាតិរបស់ពួកគេ ដោយបានឈានដល់ចំណុចកំពូលនៅក្នុងយ៉ូសែប ដែលបានក្លាយទៅជាអ្នកគ្រប់គ្រងស្រុកអេស៊ីព្ទ បន្ទាប់មកជាអ្នកសង្គ្រោះជនជាតិនានាពីគ្រោះទុរ្ភិក្ស។

<u>*ចូរប្រាកដឱ្យមើលឃើញថា:*</u>

*ព្រះជាម្ចាស់ធ្វើគ្រប់ការទាំងអស់សម្រាប់ជាសេចក្តីល្អនៅក្នុងរឿងអំពីគ្រួសារបាក់បែកនេះ។ ព្រះអង្គបានសន្យាយ៉ាងច្រើន ដោយឯកតោភាគីដល់ពូជពង្សរបស់ពួកគេ និងប្រទានឱ្យពួកគេភ្លក់រសជាតិបន្តិចបន្តួចអំពីការសម្រេចសេចក្តីសន្យាទាំងនោះ។ នៅពេលដែលព្រះយេហូវ៉ាបាត់លែងឃើញនឹងភ្នែកបន្តិចម្តងៗ (លោកអ័ប្រាហាំសន្ទនាផ្ទាល់និងព្រះអង្គមកលេង រីឯលោកយ៉ូសែបគ្រាន់តែមាននិមិត្តស្រពិចស្រពិល)ទោះបីយ៉ាងណាក៏ដោយ ព្រះអង្គរៀបចំគ្រប់ការទាំងអស់ សូម្បីតែសេចក្តីសង្គ្រោះដល់ប្រជាជាតិនានាតាមរយៈលោកយ៉ូសែប ដែលរស់នៅដោយសារសេចក្តីជំនឿ មិនមែនដោយសារមើលឃើញទេ។ តើការផ្លាស់ប្តូរបែបនេះសម្រាប់យើងដែរឬ? លោកយ៉ូសែបទុកចិត្តលើសេចក្តីសន្យារបស់ព្រះជាម្ចាស់ ដូច្នេះហើយទទួចកុំឱ្យគេបញ្ចុះសពគាត់ ប៉ុន្តែឱ្យគេនាំយកឆ្អឹងរបស់គាត់ត្រលប់ទៅទឹកដីសន្យាជាមួយប្រជាជនរបស់គាត់វិញនៅថ្ងៃមួយ។ ទោះបីជាគាត់ដូចព្រះយេស៊ូវតាមរបៀបជាច្រើនក៏ដោយ តំណវង្សរបស់ព្រះមែស៊ីនៅក្នុងយូដា។*



ទាសភាព

## ប ៦ ទាសភាព

***សេចក្តីអាក្រក់វាយប្រហារគ្រួសារដែលនឹងបង្កើតព្រះអង្គសង្គ្រោះ-៤០០ឆ្នាំ***

<u>១៨០០-១៤០០ ម.គ.ស.:</u>
ពូជពង្សរបស់លោកអ័ប្រាហាំបានរីកចម្រើនឡើងយ៉ាងខ្លាំងនៅក្នុងស្រុកអេស៊ីព្ទ រហូតដល់ស្តេចអាក្រក់នៅស្រុកអេស៊ីព្ទបានប្រឆាំងនឹងពួកគេ ដោយព្យាយាមសម្លាប់មនុស្សប្រុសទាំងអស់នៅក្នុងពូជពង្សរបស់សេត-ព្រះមែស៊ីដោយបង្កើនភាពព្រៃផ្សៃ និងការធ្វើទារុណកម្មមកលើពួកគេទាំងអស់គ្នា។ ជនជាតិអ៊ីស្រាអែលទាំងអស់ស្រែកអំពាវនាវរកព្រះយេហូវ៉ាឱ្យជួយសង្គ្រោះ។

*<u>ចូរប្រាកដឱ្យមើលឃើញថា:</u>*

*អ៊ីស្រាអែលក្លាយទៅជាទាសករ បន្ទាប់មកទៀតមានអំពើប្រល័យពូជសាសន៍នៅក្រោមរាជ្យស្តេចផារោនដែលពាក់មកុដលើក្បាលរូបសត្វពស់។ ប្រាកដណាស់ នេះគឺជាស្ថានភាពអស់សង្ឃឹមរបស់មនុស្សនៅក្រោមអារក្សសាតាំង និងអំពើបាប។ ជាមួយនឹងការសើចចំអក ព្រះយេហូវ៉ាប្រើស្ត្រីប្រាំនាក់ដែលគ្មានអំណាច (នាងស៊ីប្រា នាងពូអា ម្តាយរបស់លោកម៉ូសេ គឺនាងយ៉ូកិបិត និងនាងម៉ារាម) ដើម្បីរៀបចំសេចក្តីសង្គ្រោះសម្រាប់កូនទាំងអស់របស់ព្រះអង្គផង និងការបំផ្លាញសម្រាប់ខ្មាំងសត្រូវទាំងអស់របស់ព្រះអង្គផង។ ជីវិតកាលពីក្មេងរបស់លោកម៉ូសេស្រដៀងគ្នានឹងជីវិតកាលពីក្មេងរបស់ព្រះយេស៊ូវ គឺទាំងពីរនាក់បង្ហាញប្រាប់ជាមុនអំពីសេចក្តីសង្គ្រោះរបស់មនុស្សទាំងអស់។*



## ប ៧ និក្ខមនំ និងការវាយដណ្តើមបាន

***មនុស្សនាំងអស់ស្គាល់រស់ជាតិនន្លេ***

<u>**និក្ខមនំ-យ៉ូស្វេ:**</u>

ជាមួយនឹងគ្រោះកាចដប់ ព្រះយេហូវ៉ាបានយកឈ្នះព្រះប្រាំបួនរបស់សាតាំង និងសង្ស្បកូនច្បងនៅក្នុងអេស៊ីព្ទ ដោយសង្គ្រោះជនជាតិអីស្រាអែលចេញពីការគ្រប់គ្រងរបស់ស្តេចផារោន។ អស់រយៈពេលសែសិបឆ្នាំនៅទីរហោស្ថាន តាមរយៈដៃរបស់លោកម៉ូសេ ព្រះយេហូវ៉ាបានគង់នៅក្នុងព្រះវិហារជាត្រសាលនៅជាមួយនឹងពួកគេដោយផ្តល់អាហារ បទគម្ពីរ និងការប្រោសឱ្យបានបរិសុទ្ធតាមរយៈយញ្ញបូជា។ ព្រះអង្គបាននាំពួកគេតាមរយៈដៃរបស់លោកយ៉ូស្វេចូលមកក្នុងទឹកដីកាណាន បានវាយឈ្នះសត្រូវអាក្រក់ទាំងអស់របស់ពួកគេ ដោយប្រទានឱ្យពួកគេមានផ្ទះទីក្រុង ចំការ និងសុវត្ថិភាព។

<u>***ចូរប្រាកដឱ្យមើលឃើញថា:***</u>

*រឿងនៅក្នុងស្រុកអេស៊ីព្ទនិយាយអំពីព្រះយេហូវ៉ាឈ្នះព្រះដទៃទៀត រឿងនៅក្នុងទីរហោឋាននិយាយអំពី«ចម្បាំង» របស់ព្រះយេហូវ៉ាជាមួយនិស្ស័យរបស់មនុស្ស! និមិត្តរូបអស្ចារ្យ: ព្រះអង្គនាំពួកគេថយក្រោយ(និក្ខមនំ ១៤:១-១០) ដើម្បីដាក់ពួកគេនៅចន្លោះ (ក) ស្តេចផារោនដែលពាក់មកុដរូបសត្វពស់ (ខ)ព្រះវិហារពីររបស់ព្រះប្រុសមួយ និងព្រះស្រីមួយ និង (គ) សមុទ្រដែលវ៉ាហាន-អារក្សសាតាំងនៅ។បន្ទាប់មក ព្រះអង្គបានសង្គ្រោះពួកគេតាមរយៈទឹកដែលបានញែកចេញពីគ្នា និងធ្វើឱ្យខ្មាំងសត្រូវទាំងអស់របស់ពួកគេលង់ស្លាប់អស់ (ដូចជាឈើឆ្កាងដែរ)! បន្ទាប់មក ព្រះយេហូវ៉ានាំយកពួកទាសករទាំងនេះបង្កើតឱ្យទៅជាប្រទេសដែលមានយុត្តិធម៌ មានរដ្ឋាភិបាល និងមានកងទ័ពនៅក្នុងពេលដ៏ត្រឹមត្រូវ។ តាមរយៈក្រឹត្យវិន័យ និងពិធីផ្សេងៗ ព្រះអង្គបង្កើតប្រព័ន្ធអប់រំថ្នាក់សិក្សាថ្ងៃអាទិត្យ (មិនមែនថ្នាក់សិក្សាថ្ងៃសប្ប័ទទេ) ដើម្បីសម្តែងអំពីបញ្ហាបាប និងដំណោះស្រាយប្រកដដោយភាពបរិសុទ្ធរបស់ព្រះអង្គដែលបានសម្រេចចូលមកក្នុងជីវិតប្រចាំថ្ងៃ។ ពួកគេបះបោរដប់ដង (ត្រូវជាមួយគ្រោះកាច–សេចក្តីសង្គ្រោះដប់ដង) ហើយនៅទីបញ្ចប់ព្រះជាម្ចាស់មកមើលការចោទប្រកាន់របស់ពួកគេមកលើខ្លួនពួកគេ។ ព្រះយេហូវ៉ាគឺជាស្តេច ជាចៅក្រម ជាឪពុកដែលខឹងយ៉ាងខ្លាំងដោយសារកូនដ៏គួរឱ្យខ្លាចរបស់ព្រះអង្គ !*




## ប ៨ អនាធិបតេយ្យ

***មនុស្សដើរតាមខ្លួនឯង - ~៣០០ឆ្នាំ***

**<u>ចៅហ្វាយ-១ សាំយូអែល ៧:</u>**
ការ បះបោរ ម្តង ទៀត ប្រឆាំង នឹង ព្រះយេហូវ៉ា នៅ ពេល ដែល «មនុស្សទាំងឡាយ គេតែងតែប្រព្រឹត្តការដែលខ្លួនគិតឃើញថាត្រឹមត្រូវ» ដោយបង្កើតឡើងវិញនូវការថ្វាយបង្គំរូបព្រះ អំពើប្រាសចាកសីលធម៌ គ្មានអរិយធម៌ សង្គ្រាមរវាងកុលសម្ព័ន្ធ ការសង្កត់សង្កិនពីពួកបរទេសដែលជាពូជសត្រូវ ការស្រែកអំពាវនាវយ៉ាងខ្លាំងរកព្រះយេហូវ៉ា ដែលបញ្ជូនពួកចៅហ្វាយ-ពួកវីរៈបុរសឱ្យមកជួយសង្គ្រោះពួកគេ...ម្តងហើយម្តងទៀតចំនួន ៧ ដង។

***<u>ចូរប្រាកដឱ្យមើលឃើញថា:</u>***
*នេះគឺជាអ្វីដែលគួរឱ្យភ័យខ្លាចបំផុត។ ស្ទើរតែគ្រប់ចៅហ្វាយ (អ្នកដឹកនាំទ័ព-អ្នកសង្គ្រោះ) មានគុណវិបត្តិយ៉ាងច្រើនមានភាពព្រៃផ្សៃ និងភាពឱនថយយ៉ាងខ្លាំង មិនមានការយល់ខាងវិញ្ញាណ ការប្រែចិត្តគ្រាន់តែជាការសោកស្តាយមិនមានវិប្បដិសារី។ នេះគឺជាអរិយធម៌ក្រោយសម័យទំនើបសុទ្ធសាធ។មនុស្សគ្មានអ្នកដឹកនាំ មិនចាំប្រវត្តិសាស្ត្ររបស់ខ្លួន និងតែងតែទុកចិត្តការវិនិច្ឆ័យរបស់ខ្លួនឯង ជាហេតុនាំខ្លួនឯងឆ្ពោះទៅរកការពុករលួយ និងការហិនវិនាស។ តើព្រះមែស៊ី–ស្តេច–ព្រះអង្គសង្គ្រោះនៅឯណា?«យើងត្រូវការស្តេចមកពីព្រះជាម្ចាស់!»។*




**ប ៩ ស្តេច**

***ប្រជាជាតិនាំទម្លាប់ស្គាល់សេជាតិនន្លេ***

<u>១ សាំយូអែល ៨-២ របាក្សត្រ ៩:</u>

មានស្តេចធំៗ៣: ស្តេចសុល ស្តេចដាវីឌ (ជាអ្នកដែលគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់) ស្តេចសាឡូម៉ូន (សេចក្តីសុខសាន្ត)។ ស្តេចទាំងនេះវាយឈ្នះសត្រូវទាំងអស់ កសាងរាជធានី ប្រទេស ព្រះវិហារសម្រាប់ព្រះយេហូវ៉ា គ្រប់គ្រងជាអន្តរជាតិ ពាណិជ្ជកម្ម និងពន្ធដា សេចក្តីសុខសាន្ត និងប្រាជ្ញា រហូតដល់សូម្បីតែសាសន៍ដទៃក៏មកដើម្បីស្ញើចសរសើរដែរ។

*<u>ចូរប្រាកដឱ្យមើលឃើញថា:</u>*

*នេះគឺជាល្ខោនដែលកាន់តែគួរឱ្យចាប់អារម្មណ៍ ប៉ុន្តែឥឡូវនេះ តួអង្គដែលមានអំណាចមានបុគ្គលិកលក្ខណៈលម្អិត។ ស្ត្រីម្នាក់ (នាងហាណា) ចាប់ផ្តើមរឿងសេចក្តីសង្គ្រោះម្តងទៀត។ លោកសាំយូអែលមានអត្តចរិតស្មោះត្រង់ ប៉ុន្តែជាឪពុកមិនល្អ ស្តេចសុលមានបុគ្គលិកលក្ខណៈមិនប្រក្រតីពិបាកទុកចិត្ត។ស្តេចដាវីឌមានជំនឿរឹងមាំ និងគុណវិបត្តិធម្មតា។ ស្តេចសាឡូម៉ូនឆ្លាត មានទ្រព្យសម្បត្តិច្រើន ឈ្លាសវៃនិងត្រូវបានប្រគល់ទៅឱ្យពហុជំនឿដែលនាំឱ្យស្លាប់តាមរយៈតណ្ហាត្រេកត្រអាល។ ជីវិតស្តេចដាវីឌបង្ហាញប្រាប់មុនអំពីជីវិតរបស់ព្រះយេស៊ូវតាមរបៀបជាច្រើន។ ព្រះជាម្ចាស់បានសម្រេចសេចក្តីសន្យាទាំងអស់ជាមួយលោកអ័ប្រាហាំនៅក្នុងរាជ្យស្តេចសាឡូម៉ូន ប៉ុន្តែតែនៅក្នុងពិភពលោកនេះប៉ុណ្ណោះ។ សេចក្តីសន្យាទាំងនោះមិនទាន់បានសម្រេចជាសាកល ឬនៅក្នុងចិត្តមនុស្សរយៈពេលមួយពាន់ឆ្នាំទៀត។*




## ម ១០ ការថ្វាយបង្គំរូបព្រះ

***ប្រជាជាតិនេះត្រេកត្រអាលរកព្រះដទៃទៀត_៤០០ឆ្នាំ***

**<u>១ ពង្សាវតារក្សត្រ ១១-២ ពង្សាវតារក្សត្រ ២៥ =២ របាក្សត្រ ១០-៣៦:</u>**

ការថ្វាយបង្គំរូបព្រះ និងអំពើប្រាសចាកសីលធម៌នាំទៅរកការបែកបាក់ខាងនយោបាយ និងខាងសាសនា ធ្វើឱ្យនគរបែកបាក់ មានសង្គ្រាម និងការថ្វាយបង្គំអារក្ស។ នៅក្នុងចំណោមស្តេច ២០ អង្គនៅនគរភាគខាងជើង គ្មានស្តេចមួយអង្គណាល្អទេ ហើយនៅក្នុងចំណោមស្តេច ១២ អង្គនៅនគរភាគខាងត្បូង មានតែស្តេច ៤ អង្គតែប៉ុណ្ណោះដែលល្អ។ ពូជពង្សព្រះមែសីគេចផុតពីសេចក្តីស្លាប់ម្តងហើយម្តងទៀត កិច្ចការបន្ថោកបន្ទាបពីអារក្សសាតាំង ធ្វើឱ្យជនជាតិនេះស័ក្តិសមល្មមសម្រាប់ការហិនវិនាស។

*<u>ចូរប្រាកដឱ្យមើលឃើញថា:</u>*

*ការថ្វាយបង្គំរូបព្រះតែងតែនៅមុខអំពើប្រាសចាកសីលធម៌។ ប្រវត្តិសាស្ត្រដែលកំពុងតែរីកចម្រើនឡើងរបស់អ៊ីស្រាអែលចាប់តាំងពីលោកអ័ប្រាហាំមក បានធ្លាក់ចុះនៅក្នុង ១ ពង្សាវតារក្សត្រ ១១ និង ១២ ហើយបន្តធ្លាក់ចុះមួយពាន់ឆ្នាំទៀត។ កុលសម្ព័ន្ធទាំងដប់នៅភាគខាងជើងនៅតែថ្វាយបង្គំព្រះយេហូវ៉ាទៅតាមការយល់ឃើញរបស់ពួកគេ រួមជាមួយព្រះដទៃទៀតដែលពួកគេចូលចិត្ត។ កុលសម្ព័ន្ធពីរក្រោយសម្លឹងមើលបងប្អូនរបស់ពួកគេដែលនៅភាគខាងជើងត្រូវលុបបំបាត់ ដោយព្រោះការថ្វាយបង្គំរូបព្រះប៉ុន្តែធ្វើរឹតតែអាក្រក់ជាងទៅទៀត។ ព្រះនាងអ័ថាលាដ៏អាក្រក់ (២ពង្សាវតារក្សត្រ ១១) សម្លាប់តំណវង្សរបស់ព្រះមែស៊ីសល់តែកូនតូចម្នាក់ប៉ុណ្ណោះដែលនៅរស់...ប៉ុន្តែនេះគឺជារឿងរបស់ព្រះយេហូវ៉ា។ឈាមយ៉ាងច្រើនរបស់ពួកហោរា និងពួកមនុស្សស្មោះត្រង់ត្រូវបានបង្ហូរដោយសារនយោបាយ ការពុករលួយនិងពិធីសាសន៍ដទៃ (ការថ្វាយកូនធ្វើយញ្ញបូជា) ប៉ុន្តែការអស្ចារ្យអំពីភាពអត់ធ្មត់របស់ព្រះជាម្ចាស់មានរយៈពេលរាប់រយឆ្នាំ។*




## ប ១១ ប្រាជ្ញា

***អ្នកប្រាជ្ញដែលទុកចិត្ត ស្គាល់សេចក្តីទន្លេ***

**<u>យ៉ូប ទំនុកដំកើង សុភាសិត សាស្តា និងចំរៀងសាឡូម៉ូន:</u>**

កណ្ឌគម្ពីរដែលនិយាយអំពីការសរសើរដំកើង សំណោក ការអធិស្ឋាន វិទ្យាសាស្ត្រ និងប្រាជ្ញាដ៏អស្ចារ្យ។ បញ្ហានៅក្នុងជីវិតរបស់មនុស្សត្រូវបានពណ៌នា និងស្រាវជ្រាវនៅក្នុងសិល្បៈកំណាព្យ។ ចំរៀងបរិសុទ្ធត្រូវបានប្រមូល និងអភិវឌ្ឍសម្រាប់ជំនាន់ក្រោយៗមកទៀត។

***<u>ចូរប្រាកដឱ្យមើលឃើញថា:</u>***

*ជាជាងជាកន្លែងដ៏ល្អបំផុតសម្រាប់បង្កើតប្រព័ន្ធទេវសាស្ត្រ ទាំងនេះគឺជាឃ្លាំងកំណាព្យ និងសោភ័ណភាព អំពីជីវិតរស់នៅដោយជំនឿនៅក្នុងពិភពលោកដែលចលាចល។ ចម្រៀងសាឡូម៉ូនអបអរអាពាហ៍ពិពាហ៍ប្រកបដោយសេចក្តីស្រឡាញ់និង ភាពស្រើបស្រាលដែលព្រះយេហូវ៉ាប្រទានពរ។ សាស្តាស្ទើរតែជារឿងគួរឱ្យអស់សំណើច: គ្រប់កណ្ឌគម្ពីរដទៃទៀតនិយាយថា «ព្រះយេហូវ៉ាមានបន្ទូលយ៉ាងដូច្នេះ» ចេញពីទស្សនៈស្ថានសួគ៌ ប៉ុន្តែកណ្ឌគម្ពីរនេះផ្តោតលើមនុស្ស «ខ្ញុំនិយាយថា» ជាទេវសាស្ត្រមួយដែលត្រូវបានបង្កើតឡើង«នៅក្រោមថ្ងៃ» ដោយម្នាក់ជាអ្នកប្រាជ្ញផង ជាមនុស្សលេលាផងដែលគ្រាន់តែទទួលស្គាល់ភាពឥតប្រយោជន៍ និងការវិនិច្ឆ័យប៉ុណ្ណោះ។ កណ្ឌគម្ពីរយ៉ូបគឺជាអាវុធនុយក្លេអ៊ែកាលពីសម័យបុរាណនៅក្រោមសាសនារបស់មនុស្សដោយបំផ្ទុះរូបភាពរបស់យើងអំពីព្រះជាម្ចាស់ថាស្លូតបូត និងមានសីលធម៌។ កណ្ឌគម្ពីរសុភាសិតគឺជាបណ្តុំសេចក្តីពិតដែលត្រូវកាន់តាម ពីព្រោះជាបណ្តុំដែលមានតុល្យភាព។កណ្ឌគម្ពីរទំនុកដំកើងគឺជាអ្វីៗទាំងអស់ដែលអាចទៅរួច ដែលអាចចូលមកក្នុងជីវិតរបស់តន្ត្រីករនៅក្នុងក្រុមជំនុំ ឬសេចក្តីអធិស្ឋានរបស់អ្នកដែលវិនាស។*




## ប ១២ ភាពលេលា

***មនុស្សលេលាទុកចិត្តលើខ្លួនឯង ហើយស្លាប់***

<u>សុភាសិត សាស្តា:</u>
ស្ត្រីលេលានៅក្នុងសុភាសិតតំណាងឱ្យប្រាជ្ញារបស់អារក្សសាតាំង ដែល មាន ការ ចង់ បាន ភ្លាម ៗ និង ការ លើក តម្កើង ខ្លួន ឯង ប្រវត្តិសាស្ត្រ អំពីការលាតត្រដាងអំពើបាបត្រូវបានកត់ត្រានៅក្នុងទំនុកដំកើង ការបោកបញ្ឆោតនៃចំលើយរបស់មនុស្សត្រូវបានប្តូលរលំនៅក្នុងយ៉ូប ភាពទទេនៅក្នុងការដែលមនុស្សនិពន្ធអំពីខ្លួនឯង «ខ្ញុំបាននិយាយថា» មិនមែន«ព្រះយេហូវ៉ាមានបន្ទូលថា»ត្រូវបានបង្ហាញចេញនៅក្នុងសាស្តា។

*<u>ចូរប្រាកដឱ្យមើលឃើញថា:</u>*
*គ្រប់ទាំងសេចក្តីណែនាំល្អៗត្រូវបានផ្តល់ឱ្យនៅក្នុងបច្ចកណ្ឌ និងនៅក្នុងកណ្ឌគម្ពីរប្រាជ្ញា។ កណ្ឌគម្ពីរទំនុកដំកើង និងសុភាសិតមានដំបូន្មានមិនចេះអស់សម្រាប់អភិវឌ្ឍការវិនិច្ឆ័យ និងប្រាជ្ញា។ បញ្ហាតែមួយគត់គឺ «ចិត្តនៃមនុស្សជាតិក៏ពេញដោយសេចក្តីអាក្រក់ ហើយក៏មានសេចក្តីចំកួតនៅក្នុងចិត្ត អស់ពេលដែលរស់នៅ» (សាស្តា ៩:៣)។ យើងស្រឡាញ់ប្រាជ្ញា ហើយចង់បណ្តុះបណ្តាលកូនរបស់យើងឱ្យបានល្អ ប៉ុន្តែយើងឃើញថា ពួកគេដូចជាឪពុកម្តាយរបស់ពួកគេដែរ គឺស្រឡាញ់ខ្លួនឯងច្រើន។ យើងឃើញថាយើងហាក់បីដូចជាមិនអាចធ្វើអ្វីមួយ ដើម្បីការពារខ្លួនយើងឱ្យរួចផុតពីការត្រេកត្រអាល និងភាពលេលាបានទេ។*



ពួកហោរា

## ច ១៣ ពួកហោរា

***ទន្លេនៅក្នុងគំណាព្យអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល***

<u>អេលីយ៉ា អេលីសេ អេសាយ យេរេមា អេសេគាល និងពួកហោរាតូច ៗ:</u>

អ្នកទាំងនេះមកជាទីបន្ទាល់ប្រឆាំងនឹងស្តេចអាក្រក់របស់អីស្រាអែល ពួកសង្ឃ និងប្រជាជន ដោយទូលអង្វរ និងបន្ទោសពួកគេទាំងបង្ហាញអំពីកំហុសបច្ចុប្បន្នរបស់ពួកគេ ឱ្យត្រលប់ទៅរកកិច្ចព្រមព្រៀងនៃសេចក្តីស្រឡាញ់របស់ព្រះយេហូវ៉ាវិញ ជាសេចក្តីតាំងសញ្ញាមុនសេចក្តីតាំងសញ្ញាថ្មី នគរថ្មី ស្តេចថ្មី។ ការថ្វាយបង្គំរូបព្រះ និងអំពើប្រាសចាកសីលធម៌ក្លាយទៅជាសាសនារួមភេទ ការថ្វាយបង្គំអារក្ស យញ្ញបូជាកូនក្មេង ការដាក់ទោសដែលបានសន្យាមិនបានកើតឡើងអស់រយៈពេលជាច្រើនសតវត្សរ៍។

*<u>ចូរប្រាកដឱ្យមើលឃើញថា:</u>*

*ពួកហោរាមានការខកចិត្ត និងការឈឺចាប់យ៉ាងខ្លាំង ដែលមានតែការខកព្រះហឫទ័យ និងការឈឺចាប់របស់ព្រះជាម្ចាស់ប៉ុណ្ណោះដែលធំជាង ។ ពួកគេបានប្រទានឱ្យមានភ្នែក និងស្លាបប៉ាកកា ហើយពួកគេត្រូវសម្លឹងមើលស្ថានសួគ៌មាន នៅលើផែនដី ។ ពួកគេប្រើសេចក្តីដែលបានសរសេរឡើងដោយមានគ្រប់បែបដើម្បីព្រមាន និងប្រាប់តាមលំដាប់លំដោយអំពីការជំនុំជម្រះដែលនឹងកើតឡើងពិតប្រាកដ ទាស់នឹងមនុស្សអាក្រក់ដែលមានចំនួនកាន់តែច្រើនឡើងនៅជុំវិញពួកគេ ។ការកម្សាន្តចិត្តតែមួយគត់ដែលពួកគេមាន គឺព្រះយេហូវ៉ាគឺជាព្រះពិតប្រាកដសម្រាប់ពួកគេ ហើយព្រះអង្គប្រទានឱ្យពួកគេមើលឃើញដំណឹងល្អដែលនឹងមកដល់ពីចម្ងាយ ។ ពួកគេដឹងថា គ្រប់ទាំងសេចក្តីសន្យាជាមួយលោកអ័ប្រាហាំនឹងបានសម្រេចនៅក្នុងព្រះមែស៊ី បន្ទាប់មកនៅក្នុងចិត្តមនុស្ស និងបន្ទាប់មកទៀតនៅស្ថានសួគ៌ និងនៅលើផែនដីទាំងមូល ។*




## ច ១៤ ការនិរទេស

***ជនជាតិដែលមានចិត្តរឹងរូសត្រូវបានដាក់ទោសនៅទីបញ្ចប់***

<u>យេរេមា អេសេគាល បរិទេវ:</u>

ដូចដែលបានសន្យា ក្រោយពីពួកអាសីរីបានបំផ្លាញនគរភាគខាងជើង ដែល បាន ធ្លាក់ ចូល ទៅ ក្នុង អំពើ បាប រួច ហើយ ក្រុង យេរូ-សាឡិមដែលបះបោរច្រើនជាង ត្រូវបានពួកបាប៊ីឡូនឡោមព័ទ្ធ ប្លន់ និងដុតកំទេចចោល។ អ៊ីស្រាអែលតែ~១% (តំណាវង្សពូជនោះ) នៅរស់រានមានជីវិត ភាគច្រើនត្រូវបាននិរទេសជាង ១៦០០ គីឡូម៉ែត្រទៅក្រុងបាប៊ីឡូន។

***<u>ចូរប្រាកដឱ្យមើលឃើញថា:</u>***

*ស្តេចនេប៊ូក្នេសា គឺជាអ្នកដាក់ទោសដែលព្រះយេហូវ៉ាបានតែងតាំង។ លោកយេរេមាគឺជាអ្នកប្រកាសអំពីភាពហិនវិនាសដែលព្រះយេហូវ៉ាបានកំណត់ទុក និងជាអ្នកសារព័ត៌មានឆ្លើយឆ្លងនៅក្នុងសង្គ្រាមសម្រាប់ការហិនវិនាសរបស់ក្រុងយេរូសាឡិម និងពួកអ៊ីស្រាអែល។ លោកមើលឃើញការពុករលួយទាំងស្រុង និងការបង្ខូរឈាមរបស់អ៊ីស្រាអែលទាស់នឹងខ្លួនឯង បន្ទាប់មកទៀតគឺខ្មាំងសត្រូវរបស់អ៊ីស្រាអែល។ លោករួចផុតពីគម្រោងការសម្លាប់ និងគ្រោះថ្នាក់ជាច្រើនចំពោះខ្លួនលោក។ លោកសរសេរកំណាត់ហេតុសម្រាប់បុណ្យសព (សំណោក)។ អស់រយៈពេលជាច្រើនទសវត្សរ៍ គ្មានអ្នកណាស្តាប់លោកទេ។ អត្ថបទរបស់លោកត្រូវបានដុតចោលមួយទំព័រម្តងៗ ហើយទីបញ្ចប់លោកត្រូវបានគេចាប់ខ្លួននិងអារផ្តាច់ជាពីរ។ នៅខណៈពេលនោះ លោកអេសេគាល និងលោកដានីយ៉ែលត្រូវបាននិរទេសទៅស្រុកបាប៊ីឡូនហើយមើលឃើញនិមិត្តអំពីក្រុងយេរូសាឡិម និងអនាគតរបស់អ៊ីស្រាអែលនៅក្នុងព្រះមែស៊ី។*


ប្រដាវាស្រ្តនៅស

## ច ១៥ ប្រដាវាស្រ្តដែលនៅសល់

### *អ្នកនៅរស់ស្គាល់រស់ជាតិមនុស្សម្តងទៀត*

**អែសរ៉ា នេហេមា អេសធើរ ហាកាយ សាការី ម៉ាឡាគី:**

សេរូបាបិល បាន នាំ ជន ជាតិ អ៊ីស្រាអែល ជា ច្រើន ត្រលប់ មក រស់ នៅ និងកសាង ក្រុង យេរូសាឡិមឡើងវិញ រួមទាំង ព្រះវិហារដែល តូច ជាង មុន។ ក្រោយមកទៀត ព្រះយេហូវ៉ាបានប្រើនាងអេសធើរ និងម៉ាដេកាយ ដើម្បីជួយសង្គ្រោះជនជាតិយូដាទាំងអស់នៅលើផែនដីចេញពីការសម្លាប់ប្រល័យពូជសាសន៍។ អែសរ៉ា បាននាំពួកសង្ឃជាច្រើនមក ហើយបង្កើតសកម្មភាពពួកសង្ឃឡើងវិញ ហើយនេហេមាបានដឹកនាំការកសាងកំពែងក្រុង និងសកម្មភាពញែកឱ្យបរិសុទ្ធដទៃទៀត។

***<u>ចូរប្រាកដឱ្យមើលឃើញថា:</u>***

*នៅក្នុងនិមិត្តរបស់លោក លោកអេសេគាលបានឃើញផែនការសម្រាប់ព្រះវិហារដែលគ្រប់លក្ខណ៍ជាងព្រះវិហាររបស់ស្តេចសាឡូម៉ូន ប៉ុន្តែនៅទីបញ្ចប់ ពេលដែលពួកគេកសាងព្រះវិហារឡើងវិញរួចហើយ ពួកចាស់ទុំបានយំ ពីព្រោះទំហំ ឬសោភ័ណភាពមិនបានដូចព្រះវិហាររបស់ស្តេចសាឡូម៉ូន ឬនិមិត្តរបស់លោកអេសេគាល។ ព្រះវិហារនេះក៏មិនមានភាពអស្ចារ្យ ដោយមានភ្លើងរបស់ព្រះជាម្ចាស់ ដូចជាព្រះវិហារទីមួយដែរ ពីព្រោះព្រះវិហារនេះគ្រាន់តែជាស្រមោលរបស់និមិត្តប៉ុណ្ណោះ។ នៅថ្ងៃមួយ ព្រះយេស៊ូវនឹងក្លាយជាព្រះវិហាររបស់លោកអេសេគាល។*




## ប ១៦ ភាពស្ងប់ស្ងាត់

***អ្នកនៅរស់រង់ចាំនៅក្នុងសេចក្តីងងឹត_៤០០ឆ្នាំ***

<u>៤០០ ម.គ.ស. ដល់សញ្ញាថ្មី:</u>

ក្រោយពីស្តេចអាឡិនសិនឌ័រ ឌឹក្រេត វាយយកបានពិភពលោកមានភាពចលាចល ខាងនយោបាយយ៉ាងខ្លាំងកើតឡើងនៅក្នុងពួកអ៊ីស្រាអែល រហូតដល់អធិរាជរ៉ូមគ្រប់គ្រងទាំងស្រុង ។ ពួកផារិស៊ីក្លាយជាអ្នកប្រឆាំងនឹងអតីតកាលរបស់អ៊ីស្រាអែល ដោយបង្កើតទំនៀមទម្លាប់ដែលតឹងរ៉ឹងជាងមុន និងលំអិតជាងមុនដើម្បីការពារកុំឱ្យរអិលដួល។

*<u>ចូរប្រាកដឱ្យមើលឃើញថា:</u>*

*ក្រោយពីលោកនេហេមាមក គណៈផារិស៊ីត្រូវបានបង្កើតឡើងជាការប៉ុនប៉ងកុំឱ្យត្រលប់ទៅរកអំពើបាបកាលពីមុនវិញ ។អ៊ីស្រាអែលមិនបានត្រលប់ទៅរកការថ្វាយបង្គំរូបព្រះទេ ប៉ុន្តែបានបង្កើតច្បាប់របស់មនុស្សយ៉ាងច្រើន ដែលគាបសង្កត់មនុស្សនៅក្រោមឋានៈនុក្រមខាងវិញ្ញាណដែលមនុស្សបានបង្កើត ។នៅពេលជាមួយគ្នា មហានគរផ្សេងៗ ប្តូរវេនគ្នាគាបសង្កត់អ៊ីស្រាអែលៈ ស្តេចមហានគរដែលចូលចិត្តសម្លាប់មនុស្សមួយអង្គ បានថ្វាយជ្រូកជាយញ្ញបូជានៅក្នុងព្រះវិហារហើយទុកក្បាលជ្រូកចោលនៅលើអាសនា ដើម្បីប្រមាថទីនោះ ។ តើព្រះមែស៊ីនឹងយាងមកដែរឬទេ ?*




**ប ១៧ ព្រះយេស៊ូវ**

***ព្រះដែលបានមកកើតជាមនុស្ស ជានព្រះនាំទាំងអស់!***

**ម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន:**

ព្រះយេស៊ូវ ដែលជាព្រះមែស៊ីបានប្រសូតមក មានពួកហោរាមកថ្វាយបង្គំ បានទទួលបុណ្យជ្រមុជទឹកពីលោកយ៉ូហាន បានទទួលការចាក់ប្រេងតាំងពីព្រះជាម្ចាស់ ត្រូវបានអារក្សសាតាំងល្បួង ក្នុងឋានៈជាលោកអ័ដាមទីពីរ ។ ព្រះអង្គបានជ្រើសរើសសិស្ស បានប្រកាសអត្ថន័យលាក់កំបាំងរបស់បទគម្ពីរ បានប្រោសមនុស្សទាំងអស់ឱ្យជាដោយព្រះហឫទ័យអាណិតអាសូរ ជារូបភាពពន្យល់អំពីអត្តសញ្ញាណរបស់ព្រះអង្គ បានដេញពួកអារក្សរបស់អារក្សសាតាំងចេញ បានលើសពីមនុស្សដែលបានធ្លាក់ចុះគ្រប់ការទាំងអស់។

***<u>ចូរប្រាកដឱ្យមើលឃើញថា:</u>***

*ព្រះយេស៊ូវគឺជាព្រះមែស៊ី–ស្តេចរបស់ជនជាតិយូដា ដែលសម្រេចពាក្យទំនាយទាំងអស់ (ដំណឹងល្អម៉ាថាយ សូមមើល២៧:៣៧)។ ព្រះយេស៊ូវគឺជាអ្នកបម្រើដែលរងទុក្ខវេទនា និងបង់ថ្លៃលោះសម្រាប់អំពើបាប (ដំណឹងល្អម៉ាកុស សូមមើល ១០:៤៥)។ ព្រះយេស៊ូវគឺជាព្រះអង្គសង្គ្រោះ ជាមនុស្សមួយរយភាគរយ និងជាព្រះមួយរយភាគរយ (ដំណឹងល្អលូកា សូមមើល១៩:១០)។ ព្រះយេស៊ូវគឺជាព្រះអង្គសង្គ្រោះខាងវិញ្ញាណ ជាមនុស្សមួយរយភាគរយ និងជាព្រះមួយរយភាគរយ ដែលបានចុះមក បានយកនិស្ស័យសាច់ឈាម និងមានភាពស្និទ្ធស្នាល (ដំណឹងល្អយ៉ូហាន សូមមើល៣:១៦)ព្រះអង្គជានរណានោះ មានតាំងពីមុនអ្វីៗទាំងអស់ដែលព្រះអង្គមានបន្ទូល និងធ្វើ។ ព្រះអង្គមកពីនាងអេវ៉ា មិនមែនអ័ដាមទេ។ ព្រះអង្គគឺជាមនុស្សថ្មី។ ព្រះអង្គមិនត្រឹមតែមានគុណធម៌ទាំងអស់ប៉ុណ្ណោះទេ (ពន្លឺ សេចក្តីស្រឡាញ់ សេចក្តីពិត សោភ័ណភាព) ព្រះអង្គថែមទាំងជាទាំងអស់នេះផងដែរ ។ ព្រះអង្គគឺជាព្រះដែលនៅលើផែនដី។ នេះមិនមែនជាការប្រៀបធៀបទេ។ ភាពជាព្រះមានតាំងពីលើ នៅលើ និងនៅក្នុងភាពជាមនុស្ស - សក់ស្បែក និងសេចក្តីស្រឡាញ់ ដោយមិនបានបាត់ភាពជាព្រះណាមួយទេ។ នៅពេលដែលយើងឃើញព្រះយេស៊ូវ យើងមិនមែនគ្រាន់តែឃើញរូបភាពស្រមោល ឬ«ផ្នែកជាមនុស្ស» «ផ្នែកជាព្រះ» យើងមើលឃើញសេចក្តីពោរពេញរបស់ព្រះជាម្ចាស់ស្ថិតនៅក្នុងរូបអង្គ(កូល៉ុស ២:៩)។ នេះគឺជាអ្នកនិពន្ធដែលកំពុងចុះមកលេង ដើម្បីនាំយកតួអង្គទាំងអស់ចូលទៅក្នុងពិភពរបស់ព្រះអង្គដែលពិតប្រាកដ និងធំជាង។*




## ៦ ១៨ ឈើឆ្កាង

***សត្វពស់សម្លាប់ព្រះដែលបានមកកើតជាមនុស្ស និងទន្លេ!***

មិត្តភក្តិម្នាក់បានក្បត់ព្រះយេស៊ូវ ពួកសិស្សបានបោះបង់ចោលព្រះអង្គ ពួកអាជ្ញាធរបានកាត់ទោសព្រះអង្គដោយអយុត្តិធម៌ ប្រជារាស្ត្ររបស់ព្រះអង្គបានបដិសេធន៍ព្រះអង្គ ត្រូវបានគេធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ ត្រូវបានគេយកមកដូរជាមួយមនុស្សដែលមានកំហុស ត្រូវបានគេឆ្កាងសុគត និងត្រូវបានគេយកទៅបញ្ចុះ។ ការដាក់ទោសសម្រាប់លោកអ័ដាម សម្រាប់មនុស្សទាំងអស់ សម្រាប់យើងបានធ្លាក់ទៅលើព្រះអង្គ។

*__ចូរប្រាកដឱ្យមើលឃើញថា:__*

*ដូចជាមួយនឹងកូនប្រុសច្បងរបស់អ័ដាម និងនាងអេវ៉ាអញ្ចឹង បុត្រាច្បងដែលកើតពីព្រះ និងមនុស្ស ត្រូវបានមនុស្សសម្លាប់។ នៅទីបញ្ចប់ ព្រះជាម្ចាស់អនុញ្ញាតឱ្យយើងមើលឃើញព្រះអង្គ ហើយនៅទីបញ្ចប់យើងបានធ្វើដាក់ព្រះអង្គនូវអ្វីដែលយើងតែងតែចង់ធ្វើ។ ឈើឆ្កាងគឺជារូបថតពិតប្រាកដអំពីនិស្ស័យពិតរបស់ព្រះជាម្ចាស់ (ការលះបង់ខ្លួនឯងគ្មានទីបញ្ចប់) និងនិស្ស័យរបស់យើង (អាក្រក់ ថែមទាំងមានភាពចំកួត)។ ភាពស្រមៃស្រមៃចុងក្រោយរបស់អារក្សសាតាំងបានក្លាយទៅជាការពិត ព្រះមែស៊ីត្រូវបានគេសម្លាប់។ គ្មានរឿងណាចប់ត្រឹមសម្លាប់អ្នកនិពន្ធទេ។*




## ច ១៩ ការមានព្រះជន្មរស់ឡើងវិញ

***ព្រះដែលបានមកប្រសូតជាមនុស្សបានឈ្នះអំពើបាប និងសេចក្តីស្លាប់***

ព្រះយេស៊ូវ និងពួកហោរាបានប្រាប់បណ្តាជនអំពីបេសកកម្មយាងមកសុគតរបស់ព្រះអង្គសម្រាប់យើងទាំងអស់គ្នា។ ភាពស្មោះត្រង់របស់ព្រះអង្គជាមួយព្រះយេហូវ៉ារហូតដល់ទីមរណាស័ក្តិសមនឹងឱ្យព្រះអង្គរស់ឡើងវិញ។ ព្រះជន្មដែលមិនចេះស្លាប់របស់ព្រះអង្គបានផ្តាច់ជារៀងរហូតនូវទំនាក់ទំនងរវាងអំពើបាប និងសេចក្តីស្លាប់ ដែលយើងជាប់ជាទាសកររបស់ការខ្លាចស្លាប់។

***<u>ចូរប្រាកដឱ្យមើលឃើញថា:</u>***

*ស្ថានភាពមិនអាចនឹកស្មានដល់ទេ ឥឡូវនេះ រឿងទាំងអស់អាចកើតឡើងបាន។ តួអាក្រក់ពិតប្រាកដបានចប់។ មនុស្សថ្មីដែលហួសបាប និងសេចក្តីស្លាប់ បានកើតហើយ។ នៅទីបញ្ចប់ ម្នាក់ក្នុងចំណោមយើងមានសេរីភាពហើយ។អ្វីៗអាចកើតឡើងបាន។ ឈើឆ្កាងគឺជាមេរោគនាំឱ្យជោគជ័យ (១កូរិន ១:១៧-២:៥, កូឡុស ២:១៥)។ ឥឡូវនេះ ការស្លាប់គឺជាទ្វារនាំទៅជីវិត សូម្បីតែនៅសព្វថ្ងៃនេះក៏ដូច្នោះដែរ។កំហុសត្រូវបានអត់ទោសឱ្យ និងលែងមានសមត្ថភាពជារៀងរហូត។ នៅពេលដែលព្រះយេស៊ូវយាងឡើងទៅលើវិញ ម្នាក់ក្នុងចំណោមយើងដែលមានស្បែក និងរោម ដែលយើងត្រូវបានលាក់នៅក្នុងព្រះអង្គ (កូល៉ុស ៣:៣) បានឡើងចូលទៅក្នុងព្រះត្រីឯកជារៀងរហូត! ការរាំដ៏ធំបានបំបាក់របាស្ថាននរក ហើយមិនអាចបរាជ័យម្តងទៀតបានទេ។ អ័ដាមទីពីរ (រ៉ូម ៥) បានឡើងទៅលើសអ្វីៗទាំងអស់សម្រាប់យើង!*

*ឈើឆ្កាង និងការមានព្រះជន្មរស់ឡើងវិញ*
*របស់ព្រះយេស៊ូវគ្រីស្ទ គឺជា*
*ស្នូលនៃប្រវត្តិសាស្ត្រ*
*ការចាញ់របស់អំពើបាបរហូតដល់សេចក្តីស្លាប់*
*ជ័យជម្នះរបស់សេចក្តីស្រឡាញ់បរិសុទ្ធ*
*«យល់ព្រម»ជាមួយសេចក្តីសន្យាទាំងអស់របស់ព្រះជាម្ចាស់*
*ការវាយប្រហារ និងការវាយឆ្មក់យ៉ាងខ្លាំងរបស់ព្រះយេហូវ៉ា*
*សន្លឹកបៀដែលធំជាងគេ កូនសោ ការប្តូរលំ អន្ទាក់*
*ជោគជ័យយ៉ាងអស្ចារ្យ ពណ៌ពិតប្រាកដ*
*ការដាក់បង្ហាញ ពេលដែលប្រកបដោយសិរីរុងរឿង*
*រូបភាពបរិយាយ ស្នាមក្រយៅដៃ*
*ជីវប្រវត្តិខ្លួនឯង*
*ការបើកសម្តែងអំពីខ្លួនឯង*
*ចិត្តពិតប្រាកដ*




## ច ២០ ក្រុមជំនុំ

***ទន្លេហូរទោទ និទនៅក្នុទមនុស្សដែលទុកចិត្ត!***

__កិច្ចការ-វិវរណៈ__

ព្រះ យេស៊ូវ និង ព្រះ វរបិតា របស់ ព្រះអង្គ បាន ចាត់ ព្រះវិញ្ញាណ បរិសុទ្ធ ចូល មកក្នុង អ្នក ដែល បាន ទុក ចិត្ត លើ យញ្ញ បូជា នៃ សេចក្តី សង្គ្រោះ របស់ ព្រះអង្គ ដោយ បង្កើត ឱ្យ មាន និស្ស័យ នៅ ក្នុង ពួកគេ បំពេញសមត្ថភាពដល់ពួកគេដើម្បីស្តាប់បង្គាប់ និងតំណាងឱ្យព្រះជាម្ចាស់ ដោយធ្វើឱ្យពួកគេឆេះឆួលនឹងចែកចាយដំណឹងល្អនៅកន្លែងណាដែលពួកគេបានទៅ។

*__ចូរប្រាកដឱ្យមើលឃើញថា:__*

*ទោះបីជាមានអំពើបាប និងភាពមិនបរិសុទ្ធក៏ដោយ ក្រុមជំនុំនៅលើផែនដីដែលមានមនុស្សរាប់លាននាក់មានពណ៌សម្បុរនិងមុខផ្សេងៗគ្នា គឺជាដំណាក់ផ្ទាល់របស់ព្រះជាម្ចាស់ ជារូបកាយ និងជាកូនក្រមុំរបស់ព្រះគ្រីស្ទ ជាព្រះវិហាររបស់ព្រះវិញ្ញាណបរិសុទ្ធ។ យើងគឺជាសង្ឃ ស្តេច រាជទូត អ្នកបម្រើ អ្នករួមការងារកូន គ្រួសារ មិត្តភក្តិ។ ពីព្រោះយើងភ្ជាប់ពាក្យដើម្បីរៀបការ ក្រុមជំនុំគឺជាថ្នាក់វាំសម្រាប់ទំនាក់ទំនងរបស់យើង។ យើងគឺជារបស់ព្រះអង្គ ពីព្រោះព្រះអង្គបានធ្វើឱ្យអង្គទ្រង់ទៅជារបស់យើង។ យើងប្រកាសដំណឹង ធ្វើពិធីបរិសុទ្ធ និងបម្រើព័ន្ធកិច្ចសម្រាប់ព្រះអង្គ និងក្នុងនាមជាព្រះអង្គ។ សម្រាប់ព្រះជាម្ចាស់ក្រុមជំនុំគឺជាល្ខោនលេខមួយនៅក្នុងប្រវត្តិសាស្ត្រពិភពលោក។*




## ប ២១ ថ្ងៃចុងក្រោយ

***សត្វពស់ដែលនឹងត្រូវបំផ្លាញ កុហក និងធ្វើឱ្យពួកអ្នកដែលទុកចិត្តឈឺចាប់!***

**<u>កិច្ចការ ១-អាវសានកាលៈ</u>**

អារក្សសាតាំងនៅតែកុហក និងសម្លាប់ជីវិតនៅកន្លែងណាក៏ដោយដែលវាអាចធ្វើបាន ដោយនាំយកបញ្ហាគ្រប់បែបយ៉ាងទាំងអស់មកដាក់លើអស់អ្នកដែលដើរតាមព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះអម្ចាស់ និងជាស្ដេចរបស់យើង។ គ្រប់ទាំងអំណាចនៅលើពិភពលោកត្រូវបាននាំមកប្រឆាំងនឹងគ្រីស្ទបរិស័ទនៅតាមពេលវេលា និងទីកន្លែងផ្សេងៗ ដោយញែកពួកគេឱ្យបរិសុទ្ធ និងធ្វើទីបន្ទាល់អំពីភាពស្មោះត្រង់ ការរងទុក្ខវេទនា និងអំណាចរបស់ព្រះយេស៊ូវ។

*<u>ចូរប្រាកដឱ្យមើលឃើញថាៈ</u>*

*ថ្ងៃចុងក្រោយបានចាប់ផ្ដើមនៅថ្ងៃបុណ្យទីហាសិប ហើយព្រះយេស៊ូវបានព្រមានយើងកុំឱ្យស្មានអំពីកាលបរិច្ឆេទចុងបញ្ចប់របស់ថ្ងៃចុងក្រោយ ផ្ទុយទៅវិញ ឱ្យត្រៀមខ្លួនសម្រាប់ព្រះអង្គ។ មិនដូចជានគរនៅក្នុងសញ្ញាចាស់ទេ នគររបស់ព្រះយេស៊ូវនៅលើផែនដីមិនមានព្រំដែនដែលភ្នែកមើលឃើញទេ ប៉ុន្តែផ្សាយដំណឹងល្អ និងឈ្នះចិត្តដោយមិនទ្រព្យសម្បត្តិ ឬសង្គ្រាមទេ។ យើងនឹងមានបញ្ហា នឹងរស់នៅដោយសារជំនឿ មិនមែនដោយមើលឃើញ ហើយមិនត្រូវភ័យខ្លាចទេ ពីព្រោះព្រះយេស៊ូវឈ្នះលោកិយនេះហើយ«គ្រប់ទាំងអស់ដែលកើតពីព្រះមក នោះបានឈ្នះលោកិយហើយ ឯជ័យជម្នះដែលឈ្នះលោកិយ នោះគឺជាសេចក្ដីជំនឿរបស់យើង» (១ យ៉ូហាន ៥:៤)។*



ដំណឹងល្អទៅដល់ជនជាតិនានា

## ច ២២ ដំណឹងល្អទៅដល់ជនជាតិនានា

***ទន្លេហូរចូលទៅគ្រប់ទីកន្លែង និងគ្រប់មនុស្ស***

**<u>កិច្ចការ ១-អាវសានកាលៈ</u>**

ព្រះវិញ្ញាណបរិសុទ្ធនាំព្រះបន្ទូល និងប្រជារាស្ត្ររបស់ព្រះយេស៊ូវចូលទៅគ្រប់ទីកន្លែង និងគ្រប់ភាសាសហគមន៍ និងវប្បធម៌។ ភាពផ្សេងគ្នានិងភាពចុះសម្រុងជាមួយគ្នារបស់គ្រួសារ ដែល កំពុង លេច ចេញ មក នេះ បង្ហាញពី សេចក្តីស្រឡាញ់ដែលបានកំទេចរនាំង និងប្រាជ្ញារបស់ព្រះអង្គនៅចំពោះមុខមនុស្ស និងពួកទេវតា។

*<u>ចូរប្រាកដឱ្យមើលឃើញថា:</u>*

*ដំណឹងល្អមិនពឹងផ្អែកលើវប្បធម៌ណាមួយទេ ដូច្នេះដំណឹងល្អវិនិច្ឆ័យ ប្រទានពរ បំផ្លាស់បំប្រែ និងលើសអស់ទាំងវប្បធម៌។ ព្រះជាម្ចាស់សព្វព្រះហឫទ័យគង់នៅក្នុងមនុស្សគ្រប់គ្នា និងគង់នៅគ្រប់ទីកន្លែង។ ការអត់ទោសនាំចិត្តមនុស្សនៅក្នុងពិភពលោកទាំងអស់ឱ្យមានជំនឿ។ គេមិនអាចបញ្ឈប់ព្រះវិញ្ញាណបានទេ។ ព្រះអង្គកត់ត្រាឈ្មោះយើងចូលក្នុងសៀវភៅរបស់ព្រះអង្គ និងគង់នៅក្នុងយើងជាភាជនៈសម្រាប់តែព្រះអង្គមួយប៉ុណ្ណោះ។ ទោះបីជាយើងនៅតែលេលា និងបានត្រលប់ជាកខ្វក់ដោយសារនិស្ស័យបាបដែលនាំឱ្យពុករលួយរបស់យើងក៏ដោយ ព្រះជាម្ចាស់សព្វព្រះហឫទ័យគង់នៅជាមួយនៅក្នុងមនុស្ស។*

*យើងនៅក្នុងព្រះគម្ពីរ!*

*រឿងរបស់យើងនៅត្រង់នេះ...*

*ប្រធានបទរបស់ព្រះអង្គគឺជាប្រធានបទរបស់យើង...*

*ព្រះអង្គសរសេរយើងចូលក្នុងរឿងរបស់ព្រះអង្គ...*

*យើងអានរឿងរបស់ព្រះអង្គអំពីរឿងរបស់យើង...*

*អ្នកនិពន្ធរស់នៅជាមួយ ហើយនៅក្នុង ព្រមទាំងតាមរយៈតួអង្គក្នុងរឿងរបស់ព្រះអង្គ...*
*មិនមែនតាមបែបប្រៀបធៀបទេ តែតាមបែបពិតជាក់ស្តែង!*
*មិនមែនគ្រាន់តែតាមរយៈពួកគេប៉ុណ្ណោះទេ ថែមទាំងជាពួកគេផង!*




## ប ២៣ ការជំនុំជម្រះ

***សត្វពស់ និងពួកបះបោរដែលមិនទុកចិត្តត្រូវបានដាក់ទោស***

នៅទីបញ្ចប់ គ្រប់ទាំងសេចក្តីអយុត្តិធម៌ គ្រប់ទាំងសេចក្តីស្រឡាញ់ គ្រប់ទាំងសេចក្តីមិនសប្បុរស គ្រប់ទាំងការក្បត់គ្រប់ទាំងអំពើព្រៃផ្សៃគ្រប់ទាំងគ្រោះថ្នាក់ គ្រប់ទាំងភាពអាម៉ាស់ គ្រប់ទាំងអំពើបាបឧក្រិដ្ឋកម្ម និងសេចក្តីអាក្រក់ដែលគេប្រព្រឹត្តតាំងពីដើមមក នឹងត្រូវបានដាក់ទោសយ៉ាងយុត្តិធម៌មកលើមនុស្សគ្រប់គ្នាដែលបដិសេធន៍មិនទទួលយកការអត់ទោសរបស់ព្រះយេហូវ៉ា។

*<u>ចូរប្រាកដឱ្យមើលឃើញថា:</u>*

*ប្រាសចាកពីគោលលទ្ធិដែលនាំឱ្យខ្មាស សេចក្តីពិតអំពីការជំនុំជម្រះមានសិរីរុងរឿង គួរឱ្យខ្លាច និងមានសោភ័ណភាព។សេចក្តីពិតនេះតែងតែយ៉ាងដូច្នេះ។ ការជំនុំជម្រះសំខាន់សម្រាប់សេចក្តីស្រឡាញ់ពិតប្រាកដ។ ការជំនុំជម្រះគឺជាភ្លើងការពារអាពាហ៍ពិពាហ៍ដែលបរិសុទ្ធបំផុត និងជារបស់ឪពុកដែលល្អជាងគេបំផុត។ ព្រះយេហូវ៉ាក្រោធទាស់នឹងអារក្សសាតាំង និងគ្រប់គ្នាដែលបង្កឱ្យមានស្នាមប្រឡាក់នៅលើកូនក្រមុំ កូន ស្ត្រី ជនរងគ្រោះ អ្នកមិនដឹងមនុស្សស្លូតត្រង់ជំណាក់ រាស្ត្រ ទឹកដី។ គ្រប់ទាំងសម្រែកទាស់នឹងការរងទុក្ខវេទនាដោយអយុត្តិធម៌ ការក្បត់ ការបោកបញ្ឆោត និងអំពើឧបាយមុខនឹងត្រូវបានវិនិច្ឆ័យ ហើយសងសឹក។ សេចក្តីអាក្រក់ពិតប្រាកដនឹងត្រូវបំផ្លាញនៅទីបញ្ចប់យ៉ាងពិតប្រាកដ។*




## ប ២៤ ការបង្កើតថ្មី

***អំណរនៃការជួបជុំគ្នារវាងព្រះយេហូវ៉ា និងអ្នកដែលទុកចិត្តត្រូវបានបញ្ចប់!***

ត្រែនឹងផ្លុំឡើង មនុស្សស្លាប់នឹងរស់ឡើងវិញមិនស្លាប់ទៀតទេ ព្រះគ្រីស្ទ នឹង យាង មក ដោយ នៅ ក្នុង សិរី រុងរឿង នៃ ព្រះ វរ បិតា របស់ព្រះអង្គ ជាមួយ ពួក ទេវតា ដ៏បរិសុទ្ធ ដើម្បីនាំ យក សិរី រុងរឿង និងរង្វាន់មកឱ្យអ្នកដែលបានទុកចិត្តលើព្រះអង្គដោយនាំយើងមកឯព្រះអង្គ ជាកូនក្រមុំនៅឯពិធីរៀបការដែលយើងនឹងបម្រើព្រះអង្គហើយព្រះអង្គបម្រើយើង នៅពេលដែលព្រះអង្គចាប់ផ្ដើមបង្កើតអ្វីៗជាថ្មីឡើងវិញ។

*__ចូរប្រាកដឱ្យមើលឃើញថា:__*

*អ្វីៗដែលយើងបានដឹង បានគិត មានអារម្មណ៍ ឬបានធ្វើ គឺជាការដេកលក់ និងស្រមោល បើប្រៀបធៀបទៅនឹងការមិនដេកលក់ និងពន្លឺរបស់ស្ថានសួគ៌ (១ កូរិនថូស ១៥)។ អ្វីៗដែលយើងបានបាត់បង់ ឬបានរងទុក្ខវេទនាគឺជាការកន្លងទៅតែមួយប៉ប្រិចភ្នែកប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងការលេចមកជាលើកដំបូងរបស់ «សេរីភាពនៃសិរីល្អ» នៅស្ថានសួគ៌ (រ៉ូម៨)។ អ្វីៗដែលយើងបានយល់សប្ដិ និងប្រាថ្នាចង់បាន នឹងសម្រេចឡើងយ៉ាងពោរពេញ និងយ៉ាងបរិសុទ្ធ (វិវរណៈ ២១-២២)។ បើប្រៀបធៀបជាមួយការបង្កើតថ្មី អ្វីៗទាំងអស់នៅក្នុងជីវិតរបស់យើងនៅក្នុងពិភពលោកនេះគ្រាន់តែជាការលសម្លៀកបំពាក់ គំនូរខ្មៅដៃព្រាលៗ បទភ្លេងចាប់ផ្ដើម ឈុតខ្លី ឈុត សេចក្ដីសន្យា។ ការបង្កើតថ្មីនឹងធ្វើឱ្យឃ្លា «ចូរឱ្យមានពន្លឺ» ហាក់បីដូចជាការកំដៅសាច់ដុំ។ គ្រប់ទាំងអ្វីៗ និងគ្រប់ទាំងបំណងប្រាថ្នាដែលព្រះយេហូវ៉ាបានតាក់តែងចូលមកក្នុងស្នាព្រះហស្តទាំងអស់ នឹងសម្រេចឡើងនៅក្នុងសេចក្ដីស្រឡាញ់យ៉ាងពេញហូរហៀររបស់ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ (យ៉ូហាន ១៧:២៤-២៦, អេភេសូរ ១:២០-២៣)។*

## ការឆ្លុះបញ្ចាំង:

នៅខាងចុងជួរដេកនីមួយៗរបស់ ទបនគ លោកអ្នកនឹងឃើញមានទំព័រទទេមួយ សម្រាប់ឱ្យ លោក អ្នក សរសេរការឆ្លើយតបរបស់លោកអ្នកចំពោះអ្វីដែលលោកអ្នកទើបតែបានឃើញ និងបានឮ។ តើការមួយចំនួនដែលលោកអ្នកចាប់អារម្មណ៍នៅពេលដែលលោកអ្នកបានធ្វើដំណើរយ៉ាងលឿនឆ្លងកាត់សម័យកាលធំៗទាំង ២៤ នៅក្នុងព្រះគម្ពីរមានអ្វីខ្លះ ?

តើលោកអ្នកមានគំនិតណាមួយអំពីព្រះជាម្ចាស់ ដែលលោកអ្នកកំពុងតាមមើលតាមរយៈសេចក្តីសង្ខេបព្រះគម្ពីរដ៏លឿននេះដែរឬទេ ?

**ការព្រមាន:** រហូតមកដល់ពេលនេះ យើងបានឃើញលំដាប់លំដោយរបស់សម័យកាល ដែលជាគ្រោងឆ្អឹងខ្នង...
ទំព័របន្ទាប់ចាប់ផ្តើមទន្លេទីមួយក្នុងចំណោមទន្លេទាំងប្រាំពីរ!

# ប្រធានបទ ១: ជីវិត

នៅពេលបង្កើតអ័ដាម និងនាងអេវ៉ាមាន **ជីវិត** របស់ព្រះយេហូវ៉ាដែលបានផ្លុំចូលក្នុងពួកគេ (លោកុ ២:៧)។ ជាងនេះទៅទៀត ព្រះអង្គបានប្រទានឱ្យពួកគេមានសួនច្បារ ដែលនៅក្នុងសួនច្បារនោះ មានដើម **ជីវិត** ដែលមិនត្រឹមតែនៅកណ្ដាលប៉ុណ្ណោះទេ (ខ ៩) ថែមទាំងសម្រាប់ឱ្យពួកគេបរិភោគ (ខ ១៦) និងមាន **ជីវិត** មិនចេះស្លាប់ជារៀងរហូត!

ប៉ុន្តែសេចក្ដីសន្យាអំពីការមិនស្លាប់បង្គាប់គឺថា «ឯងនឹងត្រូវស្លាប់ជាមិនខាន» ហើយដោយសារការលួច និងការបះបោររបស់ពួកគេ ពួកគេបានបោះចោល **ជីវិត**។ **សេចក្ដីស្លាប់** បានចាប់ផ្ដើមសោយរាជ្យ ហើយពួកគេមិនអាចធ្វើអ្វីបាន ដើម្បីស្អាងពួកគេឱ្យមាន **ជីវិត** ឡើងវិញទេ!

តើព្រះយេហូវ៉ាអាចឈោងហួស **សេចក្ដីស្លាប់** ដើម្បីស្អាង **ជីវិត** ដែលបាត់បង់នោះឡើងវិញបានដែរឬទេ ហើយតើព្រះអង្គនឹងធ្វើការនោះដែរឬទេ?



**<u>ប្រធានបទ ១: ជីវិតត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីសេចក្តីស្លាប់</u>**

# ប្រធានបទ: **ជីវិត**

# សម័យ: **បុព្វបុរស**

**<u>ជ៥ ការពណ៌នារូបភាពៈ</u>** លោកអ័ប្រាហាំបម្រុងនឹងសម្លាប់កូនប្រុសរបស់គាត់ ឈ្មោះអ៊ីសាក់នៅលើភ្នំម៉ូរីយ៉ា សម្លេងរបស់ព្រះជាម្ចាស់បានឃាត់ (តំណាងជាផ្លេកបន្ទោពីលើ និងពីខាងក្រោយគាត់)។ នៅខាងឆ្វេងដៃលោកអ័ប្រាហាំ គឺកូនប្រុសរបស់គាត់ដែលត្រូវបានចងដាក់នៅលើគំនរអុស ហើយនៅខាងស្តាំដៃលោកអ័ប្រាហាំ ឃើញមានចៀមឈ្មោលមួយជាប់ស្នែងនៅព្រៃ។

**<u>បទគម្ពីរៈ</u>** លោកុប្បត្តិ ២២ ហេព្រើរ ១១:១៧-១៩។

**<u>គំនិតប្រធានបទៈ</u>** នៅក្នុងលោកុប្បត្តិ ២២:៣, ២២:៨ និងនៅក្នុងហេព្រើរ ១១:១៧-១៩ លោកអ័ប្រាហាំគិតហើយទុកចិត្តថា ព្រះជាម្ចាស់មានអំណាចផ្តល់ *ជីវិត*ខ្លាំងជាងអំណាចរបស់ *សេចក្តីស្លាប់* គឺព្រះអង្គអាចជួយសង្គ្រោះ *ជីវិត*បាន ទោះបីជាមានន័យថា ប្រោសឱ្យរស់ពីស្លាប់ឡើងវិញក៏ដោយ! នៅត្រង់នេះ ព្រះជាម្ចាស់បង្ហាញពីរបៀបដែលព្រះអង្គនឹងនាំយក *ជីវិត*មកឱ្យមនុស្សជាតិនៅថ្ងៃមួយ ជា *ជីវិត*ដែលអស្ចារ្យជាង *សេចក្តីស្លាប់*ទៅទៀត ជា *ជីវិត*ដែលរួចផុតពីបណ្តាសានៃ *សេចក្តីស្លាប់*នៅក្នុងលោកុប្បត្តិ ២:១៧ និង ៣:២៤។ នៅលើភ្នំម៉ូរីយ៉ា យើងមើលឃើញរូបភាពតូចមួយ ដែលមានតែមនុស្សប្រុសម្នាក់ និងកូនប្រុសរបស់គាត់ ជារូបភាពអំពីព្រះយេហូវ៉ា ដ៏ជាព្រះ ចាប់ផ្តើមបង្ហាញរបៀបដែលព្រះអង្គនឹងស្តារ *ជីវិត*ឡើងវិញ ជា *ជីវិត*ដែលយើងបានបាត់បង់ នៅពេលដែលយើងបានធ្វើបាប ហើយបានទទួលភាពគ្មានជីវិតនៃការខំប្រឹងធ្វើការការឈឺចាប់ និង *សេចក្តីស្លាប់*នៅពេលដែលធ្លាក់ចុះនោះទុកជាមរតក។ ព្រះអង្គបង្ហាញពាក្យបន្ថែមចុងថ្មីទៅក្នុងព្រះនាមរបស់ព្រះអង្គគឺ *«យេហូវ៉ា-យីរេ»* - *«យើងគឺជាអ្នកផ្គត់ផ្គង់ឱ្យអ្នក»* ដោយសន្យាថា ព្រះអង្គនឹងផ្គត់ផ្គង់ព្រះបុត្រាមកធ្វើជាយញ្ញបូជាជំនួស ដើម្បីសម្រេចការជួយសង្គ្រោះ និងការមានជីវិតរស់ឡើងវិញរបស់យើង។



**<u>ប្រធានបទ ១: ជីវិតត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីសេចក្តីស្លាប់</u>**

## ប្រធានបទ: **ជីវិត**

## សម័យ: **និក្ខមនំ និងការវាយដណ្តើមបាន**

**<u>ជ៧ ការពណ៌នារូបភាព:</u>** នៅខាងឆ្វេងដៃ ទ្វារផ្ទះបុរាណដែលមានលាបឈាមនៅជុំវិញក្របទ្វារ។ នៅខាងស្តាំដៃ លោកម៉ូសេបាននាំបណ្តាជនឆ្លងកាត់សមុទ្រដែលបានញែកចេញ។

**<u>បទគម្ពីរ:</u>** និក្ខមនំ ១១-១៥:២១។

**<u>គំនិតប្រធានបទ:</u>** តាមរយៈយញ្ញបូជាកូនចៀមថ្ងៃបុណ្យរំលង ការកាត់ទោសរបស់ទេវតានៃសេចក្តីស្លាប់ត្រូវបានបញ្ចៀសចេញពីប្រជារាស្ត្រដែលបានរើសតាំង។ *ជីវិត/ការស្លាប់* របស់កូនចៀម នាំយក*ជីវិត*មកឱ្យកូនច្បង (នោះគឺ មកឱ្យមេដឹកនាំខាងសាសនានៅក្នុងគ្រួសារ ពីព្រោះកូនច្បងនៅក្នុងគ្រួសាររបស់ជនជាតិអេស៊ីព្ទ ត្រូវបានកំណត់ឱ្យធ្វើជាសង្ឃនៅក្នុងគ្រួសារ)។ ព្រះជាម្ចាស់បង្ហាញរបៀបដែលព្រះអង្គនឹងនាំយក*ជីវិត*មកឱ្យមនុស្សទាំងអស់នៅថ្ងៃខាងមុខ។ *ការស្លាប់*ជំនួសដើម្បីជួយសង្គ្រោះជីវិត ដ៏ជាសេចក្តីសន្យាដែលនឹងក្លាយទៅជាការពិត ហើយបានឃើញរួចមកហើយនៅក្នុងរឿងដ៏ខ្លីនៅស្រុកម៉ូរីយ៉ា ត្រូវបានពង្រីកធំឡើងចេញពី*ជីវិត*របស់មនុស្សម្នាក់ (អ៊ីសាក់) ទៅ*ជីវិត*របស់ជនជាតិមួយទាំងមូល។ស្រដៀងគ្នាដែរ ទឹកដែលបានញែកចេញជួយសង្គ្រោះ *ជីវិត* នៅពេលដែលអ៊ីស្រាអែលជាប់នៅរវាងកងទ័ពប្រហាររបស់ស្តេចផារ៉ោន អាសនានៃព្រះរបស់សាសន៍ដទៃ និងទីជម្រៅដែលមានទឹក។ នៅក្នុងសាសនាកាលពីបុរាណ ទឹកសមុទ្រដែលបោកបក់យ៉ាងខ្លាំងជានិមិត្តរូបតំណាងឱ្យកងទ័ពនៃសេចក្តីស្លាប់ និងសេចក្តីហិនវិនាស និងកងទ័ពរបស់ព្រះពស់(រ៉ាហាប់) ហើយនៅទីនេះ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ត្រូវបានប្រទានឱ្យមាន*ជីវិត*ដោយសារព្រះហស្តរបស់ព្រះអង្គលើអំណាចទាំងអស់នៃ*សេចក្តីស្លាប់*។ ដូច្នេះ នៅត្រង់នេះ យើងមើលឃើញព្រះជាម្ចាស់បង្ហាញតាមរបៀបដែលកាន់តែធំជាងមុន (ធំជាងជាមួយអ៊ីសាក់) ពីរបៀបដែលព្រះអង្គនឹងស្តារ*ជីវិត*ឡើងវិញ ជាជីវិតដែលយើងបានបាត់បង់ នៅពេលដែលយើងធ្វើបាប ហើយបានទទួលភាពគ្មានជីវិតនៃការខំប្រឹងប្រែង និងការឈឺចាប់រហូតដល់*ស្លាប់*នៅពេលដែលធ្លាក់ចុះទុកជាមរតក។



**<u>ប្រធានបទ ១: ជីវិតត្រូវបានស្តារឡើងវិញ សេចក្ដីសង្គ្រោះចេញពីសេចក្ដីស្លាប់</u>**

ប្រធានបទ: **ជីវិត**

សម័យ: **ស្ដេច**

**<u>ផ៩ ការពណ៌នារូបភាព:</u>** ទេវតានៃសេចក្តីស្លាប់កាន់ដាវចង្អុលទៅរកកំពែងក្រុងយេរូសាឡិម។ មានដៃធ្វើជាសញ្ញា «ឈប់»នៅចន្លោះដាវរបស់ទេវតា និងទីក្រុង។ នៅពីក្រោមដាវនោះ គឺជាស្តេចដាវីឌ (ពាក់មកុដ) លុតជង្គង់នៅក្បែរផើងឈាម ដោយបានថ្វាយគោឈ្មោលនៅក្នុងភ្លើង។

**<u>បទគម្ពីរ:</u>** ២សាំយូអែល ២៤, ១របាក្សត្រ ២១:១-២២:១ (លោកុប្បត្តិ ២២:២, ១៤, ចោទិយកថា ១២:១-២៨, ២ របាក្សត្រ ៣:១ នៅពេលបញ្ចប់)។

**<u>គំនិតប្រធានបទ:</u>** នៅត្រង់នេះ ស្តេចដាវីឌទូលអង្វរសម្រាប់ជីវិតរបស់អ្នកក្រុងយេរូសាឡិម ដោយថ្វាយយញ្ញបូជាធួននឹងបាបសម្រាប់ខ្លួនព្រះអង្គ ដែលព្រះអង្គបានថ្វាយដល់ព្រះជាម្ចាស់។ ម្តងទៀត ព្រះជាម្ចាស់ផ្ទេរ*សេចក្តីស្លាប់*ពីមនុស្ស(អ៊ីសាក់ អ៊ីស្រាអែល ដាវីឌ អ្នកក្រុងយេរូសាឡិម) មកលើសត្វ ដើម្បីជួយសង្គ្រោះមនុស្សដែលត្រូវស្លាប់ឱ្យមាន*ជីវិត*។ប៉ុន្តែស្តេចដាវីឌមិនមែនជាតួឯក ក៏មិនមែនជាវីរបុរសដែរ។ព្រះយេហូវ៉ាផ្ទាល់សង្គ្រោះព្រះអង្គ និងមនុស្សទាំងអស់ ដោយដឹកនាំល្ខោននេះ ជម្រុញឱ្យដាវីឌ កាឌ អ័រ៉ោណា និងសូម្បីតែអារក្សសាតាំង លេងល្ខោនដ៏ល្អនេះ។ ព្រះអង្គជ្រើសរើសទីកន្លែង ដើម្បីបត់រឿងនេះត្រលប់ទៅរកលោកអ័ប្រាហាំវិញ (លោកុ ២២:២, ១៤)។ «ទីកន្លែង» គឺជាកន្លែងដែលព្រះជាម្ចាស់ជួបជាមួយមនុស្ស ហើយប្រទានឱ្យគេមាន*ជីវិត* ដោយព្រោះអំពើបាបរបស់មនុស្សត្រូវបានដោះស្រាយរួចហើយដោយសារព្រះលោហិតរបស់យញ្ញបូជាជំនួស។ នៅត្រង់នេះ ព្រះអង្គស្តារ*ជីវិត*ឡើងវិញ តាមលក្ខណៈជាប្រជាជាតិមួយជាជីវិតដែលយើងបានបាត់បង់ នៅពេលដែលយើងបានធ្វើបាប ហើយបានទទួលភាពគ្មានជីវិតនៃការខំប្រឹងធ្វើការ ការឈឺចាប់ និងសេចក្តីស្លាប់នៅពេលដែលធ្លាក់ចុះនោះទុកជាមរតក។ ក្រោយមកទៀត នៅត្រង់នេះ ភ្នំម៉ូរីយ៉ា លានស្រូវគោឈ្មោលសម្រាប់ថ្វាយឱ្យធួននឹងបាបតង្វាយឱ្យធួននឹងបាប ក្រុងយេរូសាឡិម និងព្រះវិហារ ជួបជុំគ្នានៅលើភ្នំកាល់វ៉ារីជាតួអង្គតែមួយ...



**<u>ប្រធានបទ ១: ជីវិតត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីសេចក្តីស្លាប់</u>**

## ប្រធានបទ: **ជីវិត**

## សម័យ: **ធ្វារដ្ឋា**

**<u>ជ១១ ការពណ៌នារូបភាព:</u>** មានដៃមួយលូកចុះពីកណ្តាលពពកមក មានផ្លេកបន្ទោ ភ្លើង និងស្លាប ជួយដៃដែលខ្សោយកំពុងលង់នៅក្នុងសមុទ្រ ហើយមានព្រុយសត្វសមុទ្រលេចចេញពីផ្នែកខាងក្រោម។ មានរូបភាពបួននៅតាមជ្រុង រូបភាពនីមួយៗមានពីរដងៈ មនុស្សម្នាក់ដែលជិតស្លាប់ដោយសារស្រេកទឹកនៅក្នុងទីរហោស្ថាន បន្ទាប់មកគាត់រត់ចូលទៅក្នុងផ្ទះ។ មនុស្សដែលជាប់គុក បន្ទាប់មករួចពីច្រវាក។ សំពៅមួយនៅក្នុងរលកធំៗទន្ទឹមនឹងគ្នាដែរ សំពៅដដែលនោះចងនឹងកំពង់ផែ។ អ្នកឈឺម្នាក់មានស្នាមអុជៗដេកអស់សង្ឃឹមនៅមុខតួនៃសេចក្តីស្លាប់ដែលពាក់អាវវែង និងមានកណ្តៀវ ទន្ទឹងនឹងគ្នាដែរ រូបមនុស្សដដែលនោះរីករាយ ដោយសារសញ្ញារបស់គ្រូពេទ្យដែលកំពុងតែញញឹម ប្រាប់ថាជា។

**<u>បទគម្ពីរ:</u>** ទំនុកដំកើង ១៨ ទំនុកដំកើង ១០៧ (អាចបំបែកការសិក្សា/ក្រុម)។

**<u>គំនិតប្រធានបទ:</u>** ទំនុកដំកើងរៀបរាប់បែបជារឿងយ៉ាងអស្ចារ្យ និងយ៉ាងតានតឹងអំពីការជួយសង្គ្រោះដែលព្រះយេហូវ៉ា យាងមកមើលប្រជារាស្ត្រ ដែលអំពាវនាវរកព្រះអង្គក្នុងពេលដែលពួកគេមានការឈឺចាប់យ៉ាងខ្លាំង។ រូបភាពដែលនៅចំកណ្តាលចេញមកពីការពណ៌នានៅក្នុងទំនុកដំកើង ១៨ អំពីអំណាចរបស់ព្រះយេហូវ៉ាដើម្បីជួយសង្គ្រោះយើងចេញពី *សេចក្តីស្លាប់*មកឯ *ជីវិត* ដោយបង្ហាញរបៀបដែលព្រះអម្ចាស់នៃសាកលលោកមិនត្រឹមតែស្តាប់ឮប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យមេឃ និងផែនដីកក្រើក ដើម្បីមកតាមការស្រែកអំពាវនាវរបស់យើង។ រូបដែលនៅតាមជ្រុងទាំងនេះមកពីទំនុកដំកើង១០៧ ដែលបង្ហាញថា ព្រះយេហូវ៉ាអន្តរាគមន៍នៅគ្រប់ទាំងស្ថានភាពដែលអស់សង្ឃឹម និងដែលលំបាក ដើម្បីឆក់យក*ជីវិត*ចេញពី *សេចក្តីស្លាប់*។ រូបផ្សេងៗទាំងនេះប្រាប់ដល់អ្នកអាន អ្នកច្រៀង និងអ្នកដែលស្តាប់ឮថា របៀបយក*ជីវិត*ចេញពី *សេចក្តីស្លាប់* មាននៅក្នុងនិស្ស័យរបស់ព្រះយេហូវ៉ា។ ដូច្នេះហើយ យើងអាចទុកចិត្តព្រះអង្គបានសម្រាប់ *ជីវិត*។



**ប្រធានបទ ១: ជីវិតត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីសេចក្តីស្លាប់**

ប្រធានបទ: **ជីវិត**

សម័យ: **ពួកហោរា**

**ជ១៣ ការពណ៌នារូបភាព:** នៅខាងឆ្វេងដៃគឺជាកំពូលភ្នំដែលសម្បូរទៅដោយអាហារ ដែលនៅពីលើកំពូលភ្នំនោះ មានផ្ទាំងស្បៃមួយ ដែលជាយខាងស្តាំកំពុងបាត់ទៅ ដោយត្រូវបានមាត់លេបចូលទៅ នៅខាងស្តាំដៃ ផ្នែកខាងក្រោមៈ ជ្រលងភ្នំដែលពាសពេញទៅដោយឆ្អឹងខ្មោច ហើយមានអ្នកចម្បាំងដ៏ខ្លាំងពូកែម្នាក់កំពុងឈរ កាន់ដាវ និងលើកខែលឡើង។

**បទគម្ពីរ:** អេសាយ ២៥:៦:៨ អេសេគាល ៣៧:១-១៤ (អាចបំបែកការសិក្សា/ក្រុម)។

**គំនិតប្រធានបទ:** បទគម្ពីរអេសាយប្រាប់អំពីថ្ងៃដ៏អស្ចារ្យមួយដែលនឹងមកដល់ ជាពេលដែល *សេចក្តីស្លាប់* (ដែលត្រូវបានហៅថា មេលេបត្របាក់*ជីវិត* នៅក្នុងវប្បធម៌កាលពីបុរាណ) ត្រូវបាន*ជីវិត*លេបវិញ។ព្រះជាម្ចាស់នឹងធ្វើការយ៉ាងអស្ចារ្យអំពី*សេចក្តីស្លាប់*នៅលើភ្នំនេះ (ភ្នំស៊ីយ៉ូន នៅក្រុងយេរូសាឡិម) ដោយរៀបចំពិធីជប់លៀងអបអរ*ជីវិត* សម្រាប់មនុស្សនៅគ្រប់ទាំងសាសន៍ មិនមែនគ្រាន់តែសម្រាប់សាសន៍យូដាប៉ុណ្ណោះទេ។ ភ្នំអាថ៌កំបាំងនេះស្ថិតនៅកណ្តាលកិច្ចការរបស់ព្រះយេហូវ៉ាក្នុងការសម្រុះសម្រួល និងនាំយក*ជីវិត*មក (ភ្នំម៉ូរីយ៉ា លានស្រូវអ័រ៉ោណា ព្រះវិហារ ភ្នំកាល់វ៉ារី)។ អត្ថន័យរបស់រឿងអំពីឆ្អឹងស្ងួតគឺថា ទោះបីជាត្រូវបានបញ្ចុះ ហើយពុកផុយអស់ក៏ដោយ គ្មាននរណាម្នាក់ *ស្លាប់*រហូតដល់ព្រះជាម្ចាស់មិនអាចប្រោសឱ្យឆ្អឹងទាំងនោះមាន *ជីវិត*ពេញលេញឡើងវិញនោះទេ។ ដូច្នេះ នៅត្រង់នេះ យើងមើលឃើញព្រះយេហូវ៉ាបង្ហាញតាមរូបភាពជាលក្ខណៈទំនាយអំពី *ជីវិត*ដែលអស្ចារ្យ និងជ្រាលជ្រៅជាងដែលបានឃើញជាមួយនឹងអ៊ីសាក បុណ្យរំលង ទឹកសមុទ្រញែកចេញ និងលានស្រូវអ័រ៉ោណាទៅទៀត។ នៅត្រង់នេះព្រះអង្គនឹងស្អាងលក្ខណៈនៃ *ជីវិត*ដែលយើងបានបាត់បង់ នៅពេលដែលយើងបានធ្វើបាប ហើយបានទទួលភាពគ្មានជីវិតនៃការខំប្រឹងធ្វើការ ការឈឺចាប់ និងសេចក្តីស្លាប់នៅពេលដែលធ្លាក់ចុះនោះទុកជាមរតក។ ពួកហោរានិយាយអំពីលក្ខណៈនៃ*ជីវិត*របស់ព្រះអស្ចារ្យជាងអ្វីដែលយើងគិតថាជា*ជីវិត*ទៅទៀត។



**ប្រធានបទ ១: ជីវិតត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីសេចក្តីស្លាប់**

ប្រធានបទ: **ជីវិត**

សម័យ: **ប្រជារាស្ត្រដែលនៅសល់**

**ជ១៥ ការពណ៌នារូបភាព:** ស្តេចដែលមានពាក់មកុដដ៏ធំចូលមកតាមច្រកទ្វារតូច ហើយផ្ទុះកំហឹងឡើង ដោយឃើញហាម៉ានកំពុងលុតជង្គង់ ដាក់ដៃលើជង្គង់របស់ព្រះនាងអេសធើរ ដែលកំពុងតែអង្គុយ មានពាក់មកុដ និងមានទឹកមុខភ្ញាក់ផ្អើល។

**បទគម្ពីរ:** កណ្ឌគម្ពីរអេសធើរ (រូបភាពនិយាយអំពីជំពូក ៧:៨)។

**គំនិតប្រធានបទ:** ព្រះជាម្ចាស់មិនត្រូវបានលើកឡើងនៅក្នុងកណ្ឌគម្ពីរនេះទេ ដែលនិយាយអំពីការប៉ុនប៉ងសម្លាប់ប្រល័យពូជសាសន៍យូដា និងការបញ្ចប់ពូជពង្សរបស់ព្រះមែស៊ី។ ប៉ុន្តែកិច្ចការស្ពានជីវិតកន្លងមក ដែលអស្ចារ្យ និងនៅជារឿងរហូតរបស់ព្រះយេហូវ៉ានៅក្នុងការនាំយកជីវិតមកជំនួសសេចក្តីស្លាប់ ឱ្យដល់ប្រជារាស្ត្ររបស់ព្រះអង្គត្រូវបានប្រាប់ដោយប្រយោលនៅគ្រប់ទាំងខនៃរឿងដ៏អស្ចារ្យនេះ។លោកម៉ាដេកាយដឹងរឿងនេះ (៤:១៤)។ ជាពិសេស នៅ ក្នុង ២:៨-៩, ១៧, ២២; ៣:១, ៧; ៦:១-១៣; ៧:៨ និង ៩:១ យើង មើល ឃើញ របៀប ដែល ការអន្តរាគមន៍ផ្សេងៗមកពីព្រះជាម្ចាស់ត្រូវបានរៀបចំឡើងដើម្បីកំណត់ការជួយសង្គ្រោះប្រជារាស្ត្ររបស់ព្រះជាម្ចាស់ចេញពីចង្កូមរបស់ *សេចក្តីស្លាប់*។ នៅត្រង់នេះ សូម្បីតែពួកសត្រូវដ៏អាក្រក់របស់អ៊ីស្រាអែលក៏ទទួលស្គាល់ (៦:១៣) អំណាចការពារ *ជីវិត*ដ៏អស្ចារ្យមិនអាចតទល់បានរបស់ព្រះជាម្ចាស់មកលើជនជាតិយូដាដែរ។ ប៉ុន្តែ អំណាចនោះ ធំជាង *ច្រើន*ណាស់: ចូរធ្វើដំណើរ តាម ព្រះហស្តការពារ *ជីវិត* របស់ ព្រះជាម្ចាស់ តាមរយៈខគម្ពីរ ទាំង នេះ ដើម្បីឱ្យមានការភ្ញាក់ផ្អើលកាន់តែខ្លាំង! និក្ខមនំ ១៧:៨-១៦, ជនគណនា ២៤:២០, ចោទិយកថា ២៥:១៧-១៩,១សាំយូអែល ១០:២១ (កុលសម្ព័ន្ធ?) ១សាំយូអែល ១៥, អេសធើរ ៣:១៣, ៨:២, ៩-៩:១៦ បន្ទាប់មក ២:១៥ (កុលសម្ព័ន្ធ?)។ ហាម៉ានជាសាសន៍អ័កាក់ ស្តាប់មើលទៅដូចជាភាសាពើស៊ីបកប្រែមកពី...?!



**ប្រធានបទ ១: ជីវិតត្រូវបានស្ដារឡើងវិញ សេចក្ដីសង្គ្រោះចេញពីសេចក្ដីស្លាប់**

ប្រធានបទ: **ជីវិត**

សម័យ: **ព្រះយេស៊ូវ**

**ជ១៧ ការពណ៌នារូបភាព:** ព្រះយេស៊ូវលើកដៃឡើង បែរមុខទៅរកច្រកផ្នូរ ដែលមានសាកសពរុំក្រណាត់ចេញមក។

**បទគម្ពីរ:** យ៉ូហាន ១:៤, ៥:២៤-២៦, ៦:៥១, ៥៧, ជំពូក ១១:១-៥៧។

**គំនិត ប្រធានបទ:** ព្រះយេស៊ូវមិនត្រឹមតែជាអ្នកនាំយក *ជីវិត* ឬសង្គ្រោះ *ជីវិត*ប៉ុណ្ណោះទេ ថែមទាំងជា *ជីវិត*ផ្ទាល់។ ព្រះអង្គជា *ជីវិត*ដែលមានរូបអង្គ។ ព្រះអង្គមាន *ជីវិត*នៅក្នុងព្រះអង្គផ្ទាល់ ហើយមិនត្រឹមតែជួយសង្គ្រោះមនុស្សចេញពី *សេចក្ដីស្លាប់*ដែលជិតមកដល់ (ដូចដែលបានឃើញតាមរយៈរឿងនៅក្នុងសញ្ញាចាស់)ប៉ុណ្ណោះទេ ថែមទាំងមាន *ជីវិត*គ្រប់ គ្រាន់ ដើម្បី អាច នឹង ជួយ សង្គ្រោះ មនុស្ស ដែល បានរំលង ផុត ពី *សេចក្ដី ស្លាប់*។ រឿងអំពីកូន ស្រីរបស់លោកយ៉ៃរ៉ុស និងកូនប្រុសរបស់ស្ត្រីមេម៉ាយនៅក្រុងណាអ៊ីនបង្ហាញឱ្យឃើញអំពីអំណាចផ្ដល់ *ជីវិត*របស់ព្រះអង្គ។ រឿងអំពីឡាសា និងបងស្រីរបស់គាត់ត្រូវបានបង្កើតឡើងដើម្បីសង្កត់ធ្ងន់ថា ការរស់ឡើងវិញទាំងរូបកាយរបស់ឡាសាគឺជាភស្តុតាង សម្រាប់ការពិតដែលអស្ចារ្យជាងនេះ គឺថាបុរសនេះគឺជាព្រះអង្គផ្ទាល់ ជា« *សេចក្ដីរស់ឡើងវិញ* ហើយជា*ជីវិត*» ដែលនឹងនាំ*ជីវិត*ហួសពី *សេចក្ដីស្លាប់*មកឱ្យអស់អ្នកដែលទុកចិត្តលើព្រះអង្គ។



**ប្រធានបទ ១: ជីវិតត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីសេចក្តីស្លាប់**

ប្រធានបទ: **ជីវិត**

សម័យ: **ក្រុមជំនុំ**

**ជ២០ ការពណ៌នារូបភាព:** សត្វព្រាបហើរចេញពីច្រកទ្វារផ្នូរដែលទទេ ដែលនៅខាងក្នុងចិត្ត (មិននៅចំហៀងភ្នំទេ)។

**បទគម្ពីរ:** រ៉ូម ៥:៥, ៨:១០-១១, អេភេសូរ១:១៩-២:៦, ៣:១៦, ១៩, កូល៉ុស ៣:១-៤, ៧,កាឡាទី ២:២០, ១កូរិនថូស ៦:១៧-១៩, (អាចបំបែកការសិក្សា/ក្រុមនៅត្រង់នេះ) ១កូរិនថូស ១៥:១-៥៨, ២កូរិនថូស ៤:៧-៦:១០, យ៉ូហាន ៣:៥-៦, ៤:១៤, ១៤:២៣, ១៧:២៦, ហេព្រើរ ២:១៤-១៥។

**គំនិតប្រធានបទ:** *ជីវិត*រស់ឡើងវិញរបស់ព្រះជាម្ចាស់ ឥឡូវនេះរស់នៅខាងក្នុងចិត្តមនុស្ស។ ព្រះវត្តមាន និងអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងយើងម្នាក់ៗ ឱ្យ*ជីវិត*របស់ព្រះអង្គមកយើងនៅក្នុងពិភពលោកនៃ*សេចក្តីស្លាប់*។ *ជីវិត*នេះដោះស្រាយការភ័យខ្លាចខ្លាំងបំផុតរបស់មនុស្ស មានការជំនុំជម្រះ*សេចក្តីស្លាប់* ការដាក់ទោស ការបោះបង់ចោល ការធ្លាក់ចូលទៅក្នុងស្ថាននរក។ *សេចក្តីស្លាប់*មានអំណាចលើរូបកាយរបស់យើង និងនៅលើកិច្ចការនៅក្នុងពិភពលោកនេះជាយ៉ាងណា *ជីវិត*ស្ថានសួគ៌ក៏មានជ័យជម្នះនៅក្នុងយើង នៅក្នុងអ្នកដែលយើងឱ្យជីវិតនេះ និងនៅក្នុងក្រុមជំនុំរបស់ព្រះអង្គនៅលើផែនដីជាយ៉ាងនោះដែរ។ យើងថ្ងូរ ប៉ុន្តែបញ្ហារបស់យើងនឹងឃើញថាស្រាល ហើយបណ្តោះអាសន្នប៉ុណ្ណោះ នៅពេលដែលសត្រូវចុងក្រោយរបស់យើង គឺ*សេចក្តីស្លាប់* ត្រូវបានលេបទៅដោយនៅក្នុងជ័យជម្នះ!



**ប្រធានបទ ១: ជីវិតត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីសេចក្តីស្លាប់**

ប្រធានបទ: **ជីវិត**

សម័យ: **ការបង្កើតថ្មី**

**ជ២៤ ការពណ៌នារូបភាព:** មានត្រែផ្លុំ គំនូសផ្នូរដែលបើកចំហរលប់បាត់ មានជើងមនុស្សដែលមានសុខភាពល្អពណ៌ផ្កាឈូក ដោយរលាយបាត់ផ្នែកខាងលើ (មនុស្សដែលបានប្រោសឱ្យរស់ឡើងវិញឡើងទៅលើអាកាស)។ មានរូបព្រាលរបស់គ្រោងឆ្អឹងមនុស្សស្លៀកដណ្តប់ពណ៌ខ្មៅជុំវិញខ្លួន កាន់កណ្តៀវ ធ្លាក់សំយុងក្បាលចូលទៅក្នុងភ្លើង («សេចក្តីស្លាប់ត្រូវបានលេបបាត់ជារៀងរហូត»)។ មាន «បញ្ជីជីវិត»ដ៏ធំ ដែលមានកត់ត្រាឈ្មោះ។

**បទគម្ពីរ:** អេសាយ ២៥:៨, ១ កូរិនថូស ១៥:២១, ២៦, ៥៥, ២ ធីម៉ូថេ ១:១០, វិវរណៈ ២០:១២,១៤។

**គំនិតប្រធានបទ:** នៅពេលដែលត្រែបន្លឺសូរសំឡេងឡើង មនុស្សទាំងអស់ដែលបានទុកចិត្តលើព្រះយេស៊ូវ នឹងមាន*ជីវិត*រស់ឡើងវិញអស់កល្បជានិច្ច។ *សេចក្តីស្លាប់*ខ្លួនឯងនឹងស្លាប់ ត្រូវបាន*ជីវិត* លេបបាត់។ រូបកាយរបស់យើងរស់ឡើងវិញដោយមាន«សិរីរុងរឿង» «អំណាច» ជារូបកាយ«ខាងវិញ្ញាណ»«មិនចេះស្លាប់»ទេ។ «យើងនឹងមានលក្ខណៈដូចជាអ្នកនៅស្ថានសួគ៌»។ *ជីវិត*ដែលរស់ឡើងវិញជាជីវិតរបស់ព្រះ ដែលនៅអស់កល្បជានិច្ច ទាំងខាងក្នុង និងខាងក្រៅ។ «នៅក្នុងទ្រង់ មាន*ជីវិត*» ដូច្នេះ យើងទុកចិត្ត (កូល៉ុស ៣:៣-៤) ទាំងនិយាយថា:

ដ្បិតអ្នករាល់គ្នាបានស្លាប់

-ហើយជីវិតអ្នករាល់គ្នា

---ក៏លាក់ទុក

-----ក្នុងព្រះ

------ជាមួយនឹងព្រះគ្រីស្ទ

-----កាលព្រះគ្រីស្ទ

---ដ៏ជាជីវិតនៃយើង

-បានលេចមក

នោះអ្នករាល់គ្នានឹងលេចមកក្នុងសិរីល្អជាមួយនឹងទ្រង់ដែរ»។

## ការឆ្លុះបញ្ចាំងអំពីទន្លេ "ជីវិត និងសេចក្ដីស្លាប់":

តើការមួយចំនួនដែលលោកអ្នកចាប់អារម្មណ៍ នៅពេលដែលលោកអ្នកបានធ្វើដំណើរយ៉ាងលឿនឆ្លងកាត់ទន្លេ «ជីវិត»មានអ្វីខ្លះ?

តើមានអ្វីខុសប្លែក តើមានចង្វាក់បែបណា តើមានអ្វីគួរឱ្យចាប់អារម្មណ៍ តើមានអ្វីគួរឱ្យភ្ញាក់ផ្អើល?

តើលោកអ្នកកំពុងមានអារម្មណ៍យ៉ាងដូចម្ដេចអំពីព្រះយេហូវា ដ៏ជាព្រះ?

# ប្រធានបទទី ២: ការសម្រាក

នៅពេលបង្កើត អ័ដាម និងនាងអេវ៉ាមានការសម្រាករបស់ព្រះអម្ចាស់ដែលបានប្រទានឱ្យពួកគេ។ ព្រះអម្ចាស់បានប្រកាស និងបានអបអរចំពោះ**ការសម្រាកនៅថ្ងៃសប្ប័ទ** របស់ព្រះអង្គ ក្រោយពីព្រះអង្គបានធ្វើការបង្កើតអស់ហើយ (លោកុ ២:១-៣) ដោយនាំយកអ័ដាម និងនាងអេវ៉ា ព្រមទាំងស្នាព្រះហស្តទាំងអស់ចូលមកក្នុងការសម្រាកជាមួយព្រះអង្គ!

ប៉ុន្តែការបះបោរមិនចេះសម្រាករបស់ពួកគេ បានធ្វើឱ្យប្រាកដថា អ័ដាម និងនាងអេវ៉ា ព្រមទាំងយើងទាំងអស់ដែលជាពូជពង្ស **មិនស្តាប់បង្គាប់** ត្រូវបានដាក់ទោសឱ្យស្វែងរក **ការសម្រាក** ប៉ុន្តែមិនដែលរកឃើញឡើយ។ ការខំប្រឹងប្រែងរបស់ពួកគេមិនអាចធ្វើអ្វីបាន ដើម្បីស្អាងពួកគេឱ្យមាន **ការសម្រាក** ឡើងវិញទេ!

តើព្រះយេហូវ៉ាអាចធ្វើឱ្យមនុស្សដែល **មិនបានសម្រាក** អាចរកឃើញ **ការសម្រាក** ពិតប្រាកដរបស់ព្រះអង្គបានដែរឬទេ ហើយតើព្រះអង្គនឹងធ្វើការនោះដែរឬទេ?



**<u>ប្រធានបទ ២: ការសម្រាកត្រូវបានស្តារឡើងវិញសេចក្តីសង្គ្រោះចេញពីការចប់បារម្ភ</u>**

ប្រធានបទ: **ការសម្រាក**

សម័យ: **បុព្វបុរស**

**<u>ស៥ ក្រុម ក ការពណ៌នារូបភាព:</u>** រូបដាក់ចូលគ្នារវាង (ក) រូបមនុស្សម្នាក់ (លោកអ័ប្រាហាំ) កាន់ដំបងរបស់អ្នកគង្វាលចៀម កំពុងឈរនៅលើកំពូលភ្នំ មើលទៅឆ្ងាយ និង (ខ) នៅចំហៀងភ្នំផ្នែកខាងមុខ មានផ្នូរមួយ ដែលមានសាកសពមួយរុំនឹងសំពត់ (សារ៉ា) នៅពីមុខផ្នូរនោះ ជាមួយនឹងបុរសពីរនាក់ (លោកអ័ប្រាហាំ និងអេប្រុន) ប្តូរថង់លុយ មានសាក្សីមើល។

**<u>បទគម្ពីរ:</u>** លោកុប្បត្តិ ១២:១, ១៣ (ជាពិសេស ខ ១៤-១៥), ២៣ (អាចចែកជំពូក ២៣ ឱ្យទៅក្រុមសិក្សាទី ២) ។

**<u>គំនិតប្រធានបទ:</u>** ក្រោយពីសន្យាជាមួយលោកអាប់រ៉ាមថានឹងឱ្យ«ស្រុកដែលអញនឹងបង្ហាញឯង » ជាស្រុកដែលគាត់មិនដែលបានឃើញ ឥឡូវនេះនៅក្នុងលោកុប្បត្តិ ១៣ ព្រះយេហូវ៉ាប្រទានឱ្យគាត់មើលឃើញរបស់ពិត។ ព្រះជាម្ចាស់ពង្រីកសេចក្តីសន្យារបស់ព្រះអង្គដោយព្រះហឫទ័យសប្បុរសកាន់តែខ្លាំងជាងមុន។ នៅពេលដែលលោកអាប់រ៉ាមរស់នៅក្នុងត្រសាលនៅឡើយ គាត់ទុកចិត្តព្រះយេហូវ៉ា។ នៅពេលដែលដល់ពេល លោកទិញដីបញ្ចុះសពដើម្បីដាក់សពគ្រួសាររបស់លោកឱ្យ*សម្រាក*។ នេះគឺជាការទុកចិត្តយ៉ាងអស្ចារ្យ ពីព្រោះឆ្អឹង ដែលមិនបានដាក់ឱ្យ*សម្រាក*នៅក្នុងស្រុកកំណើតរបស់ខ្លួន ជាមួយឆ្អឹងដូនតារបស់ខ្លួនទេ ត្រូវបានគេជឿថាដាក់បណ្តាសាវិញ្ញាណរបស់អ្នកស្លាប់ឱ្យដើរវង្វេងជារៀងរហូត*មិនបានសម្រាក*អស់កល្បជានិច្ច។ លោក«គួរតែ» ដាក់សពរបស់សារ៉ា និងខ្លួនឱ្យ*សម្រាក*នៅជាមួយព្ធយុកោរបស់ពួកគេនៅក្រុងអើរ ឬស្រុកខារ៉ាន់។ ផ្ទុយទៅវិញ លោកអ័ប្រាហាំចំណាយលុយយ៉ាងច្រើននៅក្នុងការទិញ*ការសម្រាក*នៅក្នុងទឹកដីសន្យាដោយដឹងថា ទឹកដី*នេះ*នឹងក្លាយទៅជាទីលំនៅអស់កល្បជានិច្ចសម្រាប់គ្រួសាររបស់លោក។




**<u>ប្រធានបទ ២: ការសម្រាកត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីការថប់បារម្ភ</u>**

## ប្រធានបទ: **ការសម្រាក**

## សម័យ: **និក្ខមនំ និងការវាយដណ្តើមបាន**

**<u>ស៧ ការពណ៌នារូបភាព:</u>** ផែនទីស្រុកកាណាន ដោយមានប្លុកពណ៌កុលសម្ព័ន្ធ និងឈ្មោះកុលសម្ព័ន្ធ។

**<u>បទគម្ពីរ:</u>** និក្ខមនំ ៣:៨ ចោទិយកថា ៦:១០-១១, ៨:៧-១០, យ៉ូស្វេ ១០-២១ ជាពិសេស ២១:៤៣។

**<u>គំនិតប្រធានបទ:</u>** ព្រះជាម្ចាស់បានសម្រេចសេចក្តីសន្យារបស់ព្រះអង្គដល់លោកអ័ប្រាហាំ យ៉ាកុប-អ៊ីស្រាអែល និងពួកអ៊ីស្រាអែល ដោយប្រទាន*ការសម្រាក*ដល់កូនចៅរបស់ពួកគេនៅក្នុងទឹកដីសន្យា។កាលពីសម័យបុរាណដែលមានចោរប្លន់ និងពួកដណ្តើមទឹកដី ទីក្រុងដែលមានសុវត្ថិភាព មានទឹក មានដីដែលមានដំណាំ និងទ្រព្យសម្បត្តិនៅក្នុងមរតកគ្រួសារជារៀងរហូត មានតំលៃមិនអាចកាត់ស្មានបាន។ព្រះយេហូវ៉ាប្រគល់ឱ្យជនជាតិអ៊ីស្រាអែលនូវទឹកដីមួយដ៏ធំនិងសម្បូរជីជាតិ (ទឹកដីត្រលប់ជាលែងមានជីជាតិចាប់តាំងពីមជ្ឈិមសម័យមក) សម្បូរទៅដោយផ្លែឈើស្រា ទំពាំងបាយជូរ ស្រូវសាលី ព្រមទាំង«សម្បូរ ទៅដោយ ទឹកដោះ និង ទឹកឃ្មុំ» ទីក្រុង ដែល បាន សង់ កំពែង រួច ហើយ ផ្លូវទឹក ឃ្លាំង ទុក អាហារ ចំការ ដំណាំ និង ចំការ ទំពាំង បាយ ជូរ! នេះគឺជា *ការសម្រាក* ដែល ពួកគេ ទាំង អស់ យល់សប្តិចង់បាន និងជាសេចក្តីសន្យារបស់ព្រះអង្គ។



**ប្រធានបទ ២: ការសម្រាកត្រូវបានស្តារឡើងវិញសេចក្តីសង្គ្រោះចេញពីការថប់បារម្ភ**

ប្រធានបទ: **ការសម្រាក**

សម័យ: **ស្តេច**

**ស៥ ការពណ៌នារូបភាព:** បុរសម្នាក់កំពុងតែញញឹមដាក់អ្នកមើល នៅពេលដែលសម្រាកនៅលើកៅអីយោលនៅពីក្រោមដើមទំពាំងបាយជូរ និងដើមល្វា ដោយមានកាន់កែវស្រាទំពាំងបាយជូរនៅក្នុងដៃ។

**បទគម្ពីរ:** ១ ពង្សាវតារក្សត្រ ៤:២៥ និងជំពូកក្បែរៗនោះ។

**គំនិតប្រធានបទ:** ឥឡូវនេះ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់បានរស់នៅ និង*សម្រាក*នៅក្នុងទឹកដីមួយ។ស្តេចដាវីឌបានវាយឈ្នះសត្រូវទាំងអស់របស់អ៊ីស្រាអែល រហូតដល់ធ្វើឱ្យពួកគេទាំងអស់មកធ្វើជំនួញ និងបង់សួយសាអាករមកឱ្យស្តេចសាឡូម៉ូននៅពេលនេះ។ ពួកគេរីកចម្រើនយ៉ាងខ្លាំងនៅក្នុងសម័យរបស់ស្តេចមួយអង្គ (ឈ្មោះសាឡូម៉ូន) ដែលមានន័យថា «*សុខសាន្ត*»។ មានដីដែលមានដើមទំពាំងបាយជូរ និងដើមល្វារ គឺជាសញ្ញាបង្ហាញពីសុវត្ថិភាពអាហារសម្រាប់ពេលអនាគត។ ដើមល្វាមានប្រយោជន៍ផ្តល់ជាម្លប់សម្រាប់*សម្រាក* និងជាកន្លែងអធិស្ឋានដោយសម្ងាត់ផងដែរគឺលោកណាថាណែលបានអធិស្ឋាន ដោយសម្ងាត់នៅក្រោមដើមល្វារនេះ (យ៉ូហាន ១:៤៨) ដូច្នេះនៅត្រង់នេះ យើងមានរូបភាព និងរូបមន្តរបស់ជនជាតិហេព្រើរអំពី*ការសម្រាក* និងសុវត្ថិភាពយ៉ាងអស្ចារ្យនៅលើផែនដី។ នៅសម័យបច្ចុប្បន្នអ្នកដែលស្មើនឹង «អ្នកដែលមានដើមទំពាំងបាយជុរ និងដើមល្វា» គឺ «*អស់អ្នកដែលមានទ្រព្យសម្បត្តិល្មមនឹងមានសុវត្ថិភាពដើម្បីឈប់ធ្វើការ រហូតដល់មហាសេដ្ឋីដែលមានភូមិគ្រឹះមានទីធ្លាវាយកូនហ្គូលនៅតាមមាត់បឹង*»។ នេះគឺជាការសម្រេចសេចក្តីសន្យារបស់ព្រះជាម្ចាស់អំពី*ការសម្រាក*សម្រាប់ប្រជាជាតិទាំងមូលមួយ។




**<u>ប្រធានបទ ២: ការសម្រាកត្រូវបានស្តារឡើងវិញសេចក្តីសង្គ្រោះចេញពីការថប់បារម្ភ</u>**

ប្រធានបទ: **ការសម្រាក**

សម័យ: **ឆ្នាំជួរ**

**<u>ស១១ ការ ពណ៌នា រូប ភាព :</u>** រូប អ្នក គង្វាល ចៀម ឱប ចៀម យ៉ាង ថ្នម ហើយ រូបភាពនៅ ជុំវិញដែលបញ្ជាក់ទ្រនិចនាឡិកាគឺជារូបភាពទំនុកដំកើង ២៣ ដែលមានស្មៅ ប្រឡាយទឹក ផ្លូវដី ទំពក់ និងដំបង តុដែលមានអាហារពេញ ប្រេងតាំងពែង និងព្រះវិហារ។

**<u>បទគម្ពីរ:</u>** ទំនុកដំកើង ២៣ (អាចបំបែកការសិក្សា / ក្រុម ខ ១-៤ និង ខ ៥-៦)។

**<u>គំនិតប្រធានបទ:</u>** ទំនុកដំកើង ២៣ គឺជាទំនុកដំកើងមួយដែលមានគេស្គាល់ច្រើនបំផុត ពីព្រោះទំនុកដំកើងនេះផ្តល់ឱ្យយើងមានរូបភាពយ៉ាងអស្ចារ្យនៃការសន្យាអំពី*ការសម្រាក* និងសុវត្ថិភាពនៅក្នុងព្រះជាម្ចាស់។ ចិត្តរបស់អ្នកគង្វាលល្អត្រូវបានបង្ហាញចេញមកនៅក្នុងការមើលថែរបស់គាត់ចំពោះផ្នែកផ្សេងៗដែលទាក់ទងនឹងជីវិតរបស់សត្វចៀម។ គាត់ប្រាកដថា សេចក្តីត្រូវការរបស់សត្វចៀមត្រូវបានបំពេញ និងធានាដល់*ការសម្រាក*របស់សត្វចៀម។ ស្តេចដាវីឌ និងអ៊ីស្រាអែលបានយល់ថា នេះជាការប្រៀបប្រដូចនៅលើផែនដីអំពីទំនាក់ទំនងរបស់ព្រះយេហូវ៉ាជា-មួយពួកគេ ទាំងម្នាក់ៗ និងជាក្រុម។ ការអធិស្ឋានបែបកំណាព្យត្រលប់ទៅមុខទៅក្រោយរវាងសត្វចៀម និងអ្នកថ្វាយបង្គំ ស្មៅ និងព្រះវិហារ ទឹក និងសេចក្តីសុចរិត។ តាមរយៈការនេះ ចិត្តដែលមិនបានសម្រាករបស់យើងនឹងបានស្ងប់។ ព្រះជាម្ចាស់ធានាដល់អស់អ្នកដែលទុកចិត្តលើព្រះអង្គថានឹងបាន*សម្រាក* ដែលផ្តល់ការកម្សាន្តចិត្ត និងសេចក្តីសុខសាន្ត ជា*ការសម្រាក* ល្អមនឹងប្រឈមមុខជាមួយការគំរាមកំហែងរបស់សត្រូវ និងច្រកភ្នំនៃម្លប់សេចក្តីស្លាប់។



**ប្រធានបទ ២: ការសម្រាកត្រូវបានស្តារឡើងវិញសេចក្តីសង្គ្រោះចេញពីការថប់បារម្ភ**

## ប្រធានបទ: **ការសម្រាក**

## សម័យ: **ពួកហោរា**

**ស១៣ ការពណ៌នារូបភាព:** មកុដនៅចំពាក់កណ្តាល ផ្នែកខាងលើឈើច្រត់អ្នកគង្វាល ដោយមានទំពក់ព័ន្ធជុំវិញផ្កាយរបស់ស្តេចដាវីឌ ។ មានសត្វព្រាបពាំស្លឹកអូលីវ (និមិត្តសញ្ញាអំពីសេចក្តីសុខសាន្ត)។ នៅខាងក្រោមឃើញរូបក្បាលសត្វលា ឆ្កែចចក និងកូនចៀម ហើយមានរូបបេះដូងសេចក្តីស្រឡាញ់នៅចន្លោះសត្វទាំងពីរ។

**បទគម្ពីរ:** អេសាយ ៩:៦-៧, ១១:៦-១០, (អាចបំបែកការសិក្សា/ក្រុមនៅត្រង់នេះ) អេសេគាល ៣៤:២២-៣១, ៣៧:២៣-៣១ សាការី ៩:៩-១១, មីកា ៥:២-៥។

**គំនិតប្រធានបទ:** គំនិតសំខាន់ៗនៅក្នុងបទគម្ពីរមាន «សេចក្តីសុខសាន្ត ព្រះអម្ចាស់ សេចក្តីសន្យាប្រកាស»។ បទគម្ពីរអេសេគាលមានពាក្យទំនាយក្រោយស្តេចដាវីឌអំពីម្នាក់ដែលនឹងជាទាំងអស់ ដាវីឌស្តេច អ្នកគង្វាល សេចក្តីសុខសាន្តព្រះពរ សេចក្តីតាំងនៃ*មេត្រីភាព*។ បទគម្ពីរសាការីនិយាយអំពីស្តេចមួយអង្គជិះលើ លាជំទង់ ជាកូនរបស់មេលា (មិនមែនសេះចម្បាំងទេ) ដែលនឹងកាច់ផ្ទួរចំបាំង និងប្រកាសសេចក្តីសន្តិសុខដល់គ្រប់ទាំងសាសន៍។ បទ គម្ពីរ អេសាយនិយាយអំពីម្ចាស់នៃ*មេត្រីភាព*ដែលនឹងមកដល់ និងទី*សម្រាក*របស់ព្រះអង្គហើយដោយសារព្រះអង្គ ឆ្កែព្រៃ និងកូនចៀមខ្លារខិន និងកូនពពែ កូនគោ និងសិង្ហស្ទាវ កូនមនុស្សដែលនៅបៅដោះនិងសត្វពស់មាន*សេចក្តីសុខសាន្ត*ជាមួយនឹងគ្នា។លោកមីកាបង្ហាញថា អ្នកគង្វាល និងជាស្តេចប្រកបដោយសិរីរុងរឿង និងអំណាចគ្រប់គ្រងនេះមកពីភូមិបេថ្លេហិម មិនត្រឹមតែនាំ*សេចក្តីសុខសាន្ត*មកប៉ុណ្ណោះទេ ថែមទាំងជា*សេចក្តីសុខសាន្ត*របស់ពួកគេថែមទៀតផង!



**<u>ប្រធានបទ ២: ការសម្រាកត្រូវបានស្តារឡើងវិញសេចក្តីសង្គ្រោះចេញពីការថប់បារម្ភ</u>**

ប្រធានបទ: **ការសម្រាក**

សម័យ: **ប្រជារាស្ត្រដែលនៅសល់**

**<u>ស១៥ ការពណ៌នារូបភាព:</u>** មានតន្ត្រីករសង្ឃ អបអរ និងច្រៀង ដោយមានឧបករណ៍តន្ត្រី និងកំពុងកាន់មែកធាងចាកនៅពេលដែលកំពុងដង្ហែរក្បួនជាមួយជួរនៅលើកំពែងក្រុង។ ផ្នែកខាងក្រោយ មានទិដ្ឋភាពដែលព្រាលៗពីចម្ងាយ។

**<u>បទគម្ពីរ:</u>** នេហេមា ១២:២៧-៤៣ (សូមអានរឿងចាប់ពីជំពូក ២:១១ ដល់ជំពូក ១២)។

**<u>គំនិតប្រធានបទ:</u>** ដោយសារការផ្គត់ផ្គង់ និងការការពារមកពីព្រះយេហូវ៉ា ប្រជារាស្ត្រដែលនៅសល់អាចកសាងកំពែងក្រុងយេរូសាឡិមដែលបាក់បែកនោះឡើងវិញ ទោះបីជាមានការគំរាមកំហែង និងការលំបាកជាច្រើនក៏ដោយ។ កំពែងក្រុងកាលពីបុរាណគឺជាមធ្យោបាយយ៉ាងសំខាន់ដើម្បីបាន*សម្រាក*រួចផុតពីការគំរាមកំហែងសម្រាប់មនុស្ស។ ចូរចាំថាសូម្បីតែកងទ័ពរបស់ស្តេចនេប៊ូក្នេសា ជាទ័ពមហាអំណាចខ្លាំងជាងគេបំផុតនៅលើផែនដី បានប្រើពេលវេលាពីរឆ្នាំពេញដើម្បីទម្លាយកំពែងក្រុងយេរូសាឡិម។ ប្រជាជនអ៊ីស្រាអែលដែលនៅសល់ បានអបអរការបញ្ចប់ការកសាងកំពែងដែលផ្តល់*ការសម្រាក* ដោយមានពិធីបរិសុទ្ធយ៉ាងធំនៅចំពោះព្រះយេហូវ៉ា។



**<u>ប្រធានបទ ២: ការសម្រាកត្រូវបានស្តារឡើងវិញសេចក្តីសង្គ្រោះចេញពីការថប់បារម្ភ</u>**

ប្រធានបទ: **ការសម្រាក**

សម័យ: **ព្រះយេស៊ូវ**

**<u>ស១៧ ការពណ៌នារូបភាព:</u>** ព្រះយេស៊ូវបែរមុខទៅរកមនុស្សមួយហ្វូងតូច ដែលញញឹម និងកំពុងបង្រៀនមនុស្សមួយក្រុមដែលមានអាយុ និងភេទផ្សេងៗគ្នា។ ព្រះយេស៊ូវដាក់ព្រះហស្តម្ខាងលើកូនក្មេង។ នឹមសត្វគោនៅពីលើរូបនេះ។

**<u>បទគម្ពីរ:</u>** ម៉ាថាយ ១១:២៥-២៩ (ព្រះយេស៊ូវដកស្រង់យក និក្ខមនំ ៣៣:១៤) ប្រៀបធៀបជាមួយម៉ាថាយ ២៣:៤។ សូមមើលផងដែរ ១ យ៉ូហាន ៥:៣, អេភេសូរ ២:១៤-១៨, កូល៉ុស ១:២០-២២។

**<u>គំនិតប្រធានបទ:</u>** រហូតមកដល់ពេលនេះ យើងបានឃើញ*ការសម្រាក*ដែលជាសេចក្តីសន្យាកំពុងសម្រេចនៅលើផែនដីសម្រាប់បុព្វបុរសមួយចំនួនតូច បន្ទាប់មកមនុស្សជាច្រើន បន្ទាប់មកទៀតប្រជាជាតិទាំងមូល និងក្រោយមកទៀតសម្រាប់ប្រជារាស្ត្រដែលនៅសល់។ កណ្ឌគម្ពីរប្រាជ្ញា និងកណ្ឌគម្ពីរពួកហោរាបាននិយាយអំពី *ការសម្រាក* តាមលក្ខណៈជាកំណាព្យ ជានិមិត្តរូប និងអធិធម្មជាតិ។ ឥឡូវនេះ ព្រះយេស៊ូវគឺជាទាំងអស់នេះដែលជួបជុំគ្នានៅក្នុងអង្គតែមួយ។ព្រះយេស៊ូវប្រាប់អំពី*ការសម្រាក*ដែលនឹងមិនត្រឹមតែខាងសាច់ឈាម/ស្ថិតនៅទីតាំងភូមិសាស្ត្រណាមួយប៉ុណ្ណោះទេ ថែមទាំងជា«*ការសម្រាក*សម្រាប់ព្រលឹងរបស់អ្នករាល់គ្នា» -ខាងក្នុង ខាងវិញ្ញាណ ខាងទំនាក់ទំនងនៅអស់កល្ប លើសពី*ការមិនបានសម្រាក*ដែលយើងប្រហែលជាស្គាល់សូម្បីតែការបៀតបៀន និងសេចក្តីស្លាប់ផង! វិសេសទៅទៀតនោះ *ការសម្រាក*នេះគឺជា*ការសម្រាក*ដ៏ជាព្រះអង្គផ្ទាល់ដែលជាព្រះ។ *ការសម្រាក*របស់យើងគឺជាព្រះអង្គ។



**<u>ប្រធានបទ ២: ការសម្រាកត្រូវបានស្តារឡើងវិញសេចក្តីសង្គ្រោះចេញពីការថប់បារម្ភ</u>**

ប្រធានបទ: **ការសម្រាក**

សម័យ: **ក្រុមជំនុំ**

**<u>ស២០ ការពណ៌នារូបភាព:</u>** វាំងននព្រះវិហារព្យួរពីគ្រោងខាងលើចុះមក។ មនុស្សម្នាក់នៅខាងឆ្វេងវាំងនន មិនអាចមើលឃើញឆ្លងវាំងននទេ ប៉ុន្តែមានខ្សែចងនៅជុំវិញចង្កេះ ហើយខ្សែនោះត្រង់កាត់តាមវាំងនន ហើយចងទៅនឹងយុថ្កានៅម្ខាងទៀត ដែលជាប់នៅនឹងយុថ្កាយ៉ាងធំ ដែលព្រះយេស៊ូវកាន់នៅអិបនឹងដើមទ្រូងរូបរបស់ព្រះអង្គទាំងមានពាក់មកុដ និងញញឹម។

**<u>បទគម្ពីរ:</u>** ហេព្រើរ៦:១៨-២០,១០:២០ (អាចមើលបានផងដែរនៅ ៣:៥-៤:១១, ១១:១០,១៦ ហើយខគម្ពីរទាំងនេះអាចដាក់ចូលទៅក្នុង ស ២៤ បានផងដែរ)។

**<u>គំនិតប្រធានបទ:</u>** ដូចជាយុថ្កាឱ្យសំពៅបាន*សម្រាក* និងមានសុវត្ថិភាពនៅក្នុងព្យុះជាយ៉ាងណា ព្រះបន្ទូល និងសេចក្តីសន្យារបស់ព្រះជាម្ចាស់ក៏ជាសេចក្តីសង្ឃឹមសម្រាប់យើង និងជាយុថ្កាសម្រាប់ព្រលឹងរបស់យើងជាយ៉ាងនោះដែរ។ ខ្សែយុថ្កាចងយើង ហើយកាត់តាមវាំងននព្រះវិហារចូលទៅក្នុងទីបរិសុទ្ធខាងក្នុង ជាកន្លែងដែលមានសុវត្ថិភាពជាងកន្លែងណាទាំងអស់នៅក្នុងពិភពលោកនេះ។ ព្រះយេស៊ូវបានយាងទៅមុនរួចទៅហើយដើម្បីធ្វើជា«សម្តេចសង្ឃយ៉ាងធំ»សម្រាប់យើង ហើយដោយសារសេចក្តីសុចរិត និងនិស្ស័យព្រះរបស់ព្រះអង្គ ព្រះអង្គបានថ្វាយតង្វាយធួននឹងបាបរបស់យើង និងអំពើបាបទាំងអស់របស់យើង ដើម្បីឱ្យយើងបានទទួលសេចក្តីសុចរិត និស្ស័យថ្មី និងទីបញ្ចប់ដែលនៅអស់កល្បជានិច្ច។ ឥឡូវនេះ *ការសម្រាក*របស់យើងនៅក្នុងព្រះគ្រីស្ទ មិនចេះរង្គើ និងមិនចេះបាត់បង់ឡើយ។



**ប្រធានបទ ២: ការសម្រាកត្រូវបានស្តារឡើងវិញសេចក្តីសង្គ្រោះចេញពីការថប់បារម្ភ**

ប្រធានបទ: **ការសម្រាក**

សម័យ: **ការបង្កើតថ្មី**

**សង៤ ការពណ៌នារូបភាព:** កំពែងក្រុងយ៉ាងធំមួយ មានអគារ ប៉មខ្ពស់ដល់មេឃ។ ជញ្ជាំងធ្វើពីមាសនិងគ្រឹះធ្វើពីត្បូង នៅខាងក្រៅក្រុង។ នៅតាមជាយបាតខាងក្រោម មាននិមិត្តសញ្ញា ៥ និមិត្តសញ្ញានីមួយៗ មានគំនូស x បង្ហាញថានិមិត្តសញ្ញាទាំងនោះត្រូវបានខ្វែងចោល មានន័យថា និមិត្តសញ្ញាទាំងនោះនឹងមិននៅទីនោះទេ: រលក (សមុទ្រ) ប្រអប់ដៃដែលមានប្រឡាក់ឈាម តំណក់ទឹកភ្នែកដែលស្រក់ចេញពីភ្នែក មនុស្សដែលដួលចុះដោយឱបពោះទាំងឈឺចាប់ និងមឈូស។

**បទគម្ពីរ:** វិវរណៈ:២១:១,៤,៨,១០-២៧ ហេព្រើរ ៣:៥-៤:១១,១១:១០,១៦យ៉ូហាន ១៤:២-៣។

**គំនិតប្រធានបទ:** «ទីក្រុងដែលមានគ្រឹះ» និងដែលមានសុវត្ថិភាពពិតប្រាកដ គឺជាកន្លែង*សម្រាក*ដែលយើងតែងតែស្វែងរកជានិច្ច ដើម្បីរួចផុតពី*ការមិនបានសម្រាក* ពីចលាចលរបស់សមុទ្រ (ដូច្នេះ គឺរបស់រ៉ាហាប់ ឬសាតាំង ដែលជាសត្វកំណាចនៅក្នុងសមុទ្រ) រួចផុតពីអំពើបាប និងការរងទុក្ខវេទនា ពីការឈឺចាប់ បាត់បង់ និងទុក្ខព្រួយ នៅទីបញ្ចប់បាននៅជាមួយព្រះយេស៊ូវ និងព្រះវរបិតា។ អាហ៍ នេះជា*ការសម្រាក* យ៉ាងអស្ចារ្យ!

## ការឆ្លុះបញ្ចាំងអំពីទន្លេ "ការសម្រាក និងការមិនបានសម្រាក":

តើការមួយចំនួនដែលលោកអ្នកចាប់អារម្មណ៍ នៅពេលដែលលោកអ្នកបានធ្វើដំណើរយ៉ាងលឿនឆ្លងកាត់ទន្លេ «ការសម្រាក» មានអ្វីខ្លះ?

តើមានអ្វីខុសប្លែក តើមានចង្វាក់បែបណា តើមានអ្វីគួរឱ្យចាប់អារម្មណ៍ តើមានអ្វីគួរឱ្យភ្ញាក់ផ្អើល?

តើលោកអ្នកកំពុងមានអារម្មណ៍យ៉ាងដូចម្ដេចអំពីព្រះយេហូវ៉ា ដ៏ជាព្រះ?

# ប្រធានបទទី ៣: ការគ្រប់គ្រង

នៅពេលបង្កើត អ័ដាម និងនាងអេវ៉ាត្រូវបានតែងតាំងមកក្នុងតួនាទីរបស់ព្រះយេហូវ៉ា។ ព្រះអង្គបានប្រទានឱ្យពួកគេមានអំណាច **គ្រប់គ្រង** លើ **ស្នាព្រះហស្ត** ទាំងអស់ (លោកុ ១:២៦-៣០) ដោយបង្គាប់ឱ្យពួកគេគ្រប់គ្រង និងត្រួតត្រាលើអ្វីៗទាំងអស់ ព្រមទាំងលើកតម្កើងពួកគេ ដោយប្រទានឱ្យមាន **អំណាច** នឹង **ដាក់ឈ្មោះ** ឱ្យ**ស្នាព្រះហស្ត** ទាំងអស់!

ប៉ុន្តែការបះបោរប្រឆាំងនឹង **អ្នកគ្រប់គ្រង** ពិតប្រាកដ បានបំផ្លាញ **ការគ្រប់គ្រង** របស់ពួកគេ។ សត្វពស់នាំមនុស្សឬ?! ឥឡូវនេះ អំណាចគ្រប់គ្រងរបស់ពួកគេលេបពួកគេនៅក្នុងធូលីដីដែលពួកគេមកពីនោះ! ពួកគេមិនអាចធ្វើអ្វី ដើម្បីស្អាងពួកគេឱ្យមាន **ការគ្រប់គ្រង** ឡើងវិញទេ!

តើព្រះយេហូវ៉ាអាចប្តូរការបរាជ័យរបស់ពួកគេ ដើម្បីស្អាងពួកគេឱ្យមាន **ការគ្រប់គ្រង** ឡើងវិញបានដែរឬទេ ហើយតើព្រះអង្គនឹងធ្វើការនោះដែរឬទេ?



**ប្រធានបទ ៧: ការគ្រប់គ្រងត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីការនៅក្រោមការគ្រប់គ្រង**

ប្រធានបទ: **ការគ្រប់គ្រង**

សម័យ: **បុព្វបុរស**

**គ៥ ការពណ៌នារូបភាព:** មានមកុដ ៤ នៅផ្តុំគ្នា បន្ទាប់មកមានមកុដ ៥ ផ្សេងទៀតនៅផ្តុំគ្នា បន្ទាប់មកទៀត មានមកុដមួយទៀតនៅតែឯង (មកុដរបស់លោកអ័ប្រាហាំ) ដែលមាននៅផ្នែកខាងលើ។ នៅផ្នែកខាងមុខ មានរូបភាពទាហានបួននាក់ដែលកំពង់រត់។

**បទគម្ពីរ:** លោកុប្បត្តិ ១៤:១-១៦; ១៧; ២២:១៧។

**គំនិតប្រធានបទ:** លោកអ័ដាម និងនាងអេវ៉ា ត្រូវបានប្រទានឱ្យមានការគ្រប់គ្រងលើពិភពលោកគ្រប់ផ្នែក ប៉ុន្តែការគ្រប់គ្រងនេះបានបាក់បែក ហើយបាត់បង់ទៅនៅពេលដែលធ្លាក់ចុះ។ នៅក្នុងលោកុប្បត្តិជំពូកដំបូងៗ យើងមើលឃើញ *ការគ្រប់គ្រង*បានពុករលួយ បន្ទាប់មកបានធ្លាក់ចុះនៅប៉មបាបិល ព្រមទាំងឃើញមានស្តេច និងនគរមក ហើយទៅវិញ។ភ្លាមៗ ក្រោយពីអ្នកដែលបានរើសតាំង គឺលោកអ័ប្រាហាំ (នៅជាអាប់រ៉ាមនៅឡើយ) ទៅដល់ទឹកដីសន្យា មានការការផ្លាស់ប្តូរមួយផ្សេងទៀតនៅក្នុង *ការគ្រប់គ្រង*ដែលបានធ្លាក់ចុះរបស់មនុស្ស។ សង្គ្រាមអយុត្តិធម៌បានផ្ទុះឡើង នៅពេលដែលស្តេច ៥ អង្គ និងស្តេច ៤អង្គមានសង្គ្រាមនៅទិសនិរតីនៃត្រសាលរបស់លោកអ័ប្រាហាំ។ អ្នកឈ្លានពានចាប់ក្មួយប្រុសរបស់លោកអ័ប្រាហាំ គឺឡុត។ លោកអ័ប្រាហាំនិងមិត្តភក្តិបីនាក់របស់លោក ដេញតាមអ្នកឈ្លានពាន ដោយមានទ័ពតែ ៣១៨ នាក់ប៉ុណ្ណោះ ហើយពួកគេបានឈ្នះ។ លោកអ័ប្រាហាំទទួលស្គាល់ថា ព្រះជាម្ចាស់ជាប្រភពនៃជ័យជម្នះរបស់គាត់ ហើយបដិសេធមិន*គ្រប់គ្រង* ចេញពីទ្រព្យសម្បត្តិដែលមនុស្សបានឱ្យមកលោក (ពួកស្តេចដែលត្រូវបានដោះលែង)។ បន្ទាប់មក ព្រះជាម្ចាស់បានសន្យាជាមួយ លោកអ័ប្រាហាំថា មានស្តេចគ្រប់គ្រងកើតចេញពីពូជពង្សរបស់លោកនៅក្នុងលោកុប្បត្តិ ១៧។ នៅក្នុងជីវិត លោកអ័ប្រាហាំបានភ្លក់ការគ្រប់គ្រងតែមួយចំណែក និងមួយភ្លែតប៉ុណ្ណោះ គឺជាការគ្រប់គ្រងដ៏ខ្លី ប៉ុន្តែសេចក្តីសន្យាប្រាប់ថានឹងមានការគ្រប់គ្រងច្រើនថែមទៀតនឹងមកដល់...នៅថ្ងៃមួយ។



**<u>ប្រធានបទ ៣: ការគ្រប់គ្រងត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីការនៅក្រោមការគ្រប់គ្រង</u>**

ប្រធានបទ: **ការគ្រប់គ្រង**

សម័យ: **និក្ខមនំ និងការវាយដណ្តើមបាន**

**<u>គ៧ ការពណ៌នារូបភាព:</u>** កំពែងក្រុងយេរីខូដួលរលំ។ ជនជាតិអ៊ីស្រាអែលកំពុងដើរជាក្បួនក្បែរកំពែង។ បន្ទាប់មកមានក្រុមសង្ឃផ្លុំស្នែងចៀមដើរមកតាមក្រោយ រួចដើរមកតាមក្រោយទៀត គឺពួកសង្ឃសែងហិប ដោយប្រើឈើស្នែង នៅពីក្រោមក្រណាត់ ថ្មនៅតាមកំពែងកំពុងតែរបូតចុះមក ហើយមានប្រហោងនៅតាមកំពែង។

**<u>បទគម្ពីរ:</u>** យ៉ូស្វេ ២; ៥:១៣-៦:២៧។

**<u>គំនិតប្រធានបទ:</u>** ដោយសារការគ្រប់គ្រងរបស់ព្រះជាម្ចាស់ (នៅក្រោមអ្នកដែលជាកំពូលលើពួកពលផងព្រះយេហូវ៉ានៅក្នុង ៥:១៣) លោកយ៉ូស្វេវាយដណ្តើមបានក្រុងយេរីខូ និងចាប់ផ្តើមបង្កើត*ការគ្រប់គ្រង*សម្រាប់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់លើសត្រូវរបស់ពួកគេនៅស្រុកកាណាន។ នៅក្នុងករណីនេះ ព្រះយេហូវ៉ាបង្ហាញ*ការគ្រប់គ្រង*ពិតប្រាកដរបស់ព្រះអង្គ ដោយប្រទានឱ្យអ៊ីស្រាអែលមានជ័យជម្នះ ដោយពួកគេមិនចាំបាច់ទៅច្បាំងទេ។ ព្រះជាម្ចាស់ប្រទានឱ្យលោកយ៉ូស្វេមានជ័យជម្នះជាច្រើនដង ទៅតាមដែលពួកគេទុកចិត្តព្រះយេហូវ៉ា គ្មាននរណាអាចតទល់នឹង*ការគ្រប់គ្រង*របស់ពួកគេបានទេ។



**<u>ប្រធានបទ ៧: ការគ្រប់គ្រងត្រូវបានស្តារឡើងវិញ</u>**
**<u>សេចក្តីសង្គ្រោះចេញពីការនៅក្រោមការគ្រប់គ្រង</u>**

ប្រធានបទ: **ការគ្រប់គ្រង**

សម័យ: **ស្តេច**

**<u>គ៩ ការពណ៌នារូបភាព:</u>** ផែនទីមជ្ឈឹមបូព៌ានៅសម័យស្តេចដាវីឌ និងស្តេចសាឡូម៉ូន មានពន្លឺចាប់ពីក្រុងយេរូ-សាឡិមដោយកាំរស្មីបាញ់ចេញពីក្រុងយេរូសាឡិមទៅកាន់មកុដធំមួយ។ ឃើញមេកហ៊ីស៊ុប និងសត្វមួយចំនួនមកពីរូបភាព «ការបង្កើតលោក» នៅផ្នែកកណ្តាលនៃផែនទី។

**<u>បទគម្ពីរ:</u>** ២ សាំយ៉ូអែល ៥, ៨ និង ១២:២៩-៣១, ១ពង្សាវតារក្សត្រ ៤:២០-៣៤, ២របាក្សត្រ ៩ ជា ពិសេស ១៣, ១៩, ២២-២៨។

**<u>គំនិតប្រធានបទ:</u>** ឈ្មោះ «សាឡូម៉ូន» មានន័យថា «សេចក្តីសុខសាន្ត»។ ព្រះជាម្ចាស់បានប្រទានការសម្រាក និង *ការគ្រប់គ្រង*លើទឹកដីយ៉ាងធំ គឺប្រជារាស្ត្ររបស់ព្រះអង្គ*គ្រប់គ្រង*លើសត្រូវកាលពីមុនទាំងអស់ (និមិត្តរូបអំពីសត្រូវទាំងអស់ដែលប្រឆាំងនឹងនគររបស់ព្រះយេហូវ៉ា)។ អ្វីដែលព្រះជាម្ចាស់បានធ្វើតាមលក្ខណៈមួយតូចសម្រាប់លោកអ័ប្រាហាំព្រះអង្គបានធ្វើតាមលក្ខណៈធំសម្រាប់លោកយ៉ូស្វេ ហើយឥឡូវតាមលក្ខណៈទូទាំងពិភពលោកសម្រាប់ស្តេចដាវីឌ និងស្តេចសាឡូម៉ូន។ តើ ១ ពង្សាវតារក្សត្រ ៤:៣៣ ជួយយើងមើលឃើញរូបភាពធំៗទាំងនេះ ប្រៀបធៀបទៅនឹងកណ្ឌគម្ពីរលោកុប្បត្តិ ១:២៨ យ៉ាងដូចម្តេច?



**ប្រធានបទ ៧: ការគ្រប់គ្រងត្រូវបានស្តារឡើងវិញសេចក្តីសង្គ្រោះចេញពីការនៅក្រោមការគ្រប់គ្រង**

ប្រធានបទ: **ការគ្រប់គ្រង**

សម័យ: **ប្រាជ្ញា**

**គ១១ ការពណ៌នារូបភាព:** មានស្តេចមួយអង្គយ៉ាងធំ មានពាក់មកុដ និងអង្គុយនៅលើបល្ល័ង្ក ព្រះហស្តលាចេញមកដោយមានអំណាច និងព្រះពរ ព្រះហស្តម្ខាងកាន់ដំបងរាជ និងព្រះហស្តម្ខាងទៀត ធ្វើកាយវិការឱ្យពរ ទៅដល់មនុស្សដែលមានពណ៌សម្បុរផ្សេងៗគ្នា សត្វមានជីវិតទាំងអស់ ខ្សែកោងនៃផែនដី និងលំហអាកាស។

**បទគម្ពីរ:** ទំនុកដំកើង ៨; ៤៥; ៧២។

**គំនិតប្រធានបទ:** នៅក្នុងទំនុកដំកើង ៨ យើងត្រូវបានរំឮកថា ការដែលព្រះយេហូវ៉ាចាត់តាំងលោកអ័ដាម និងនាងអេវ៉ាឱ្យ*គ្រប់គ្រង*លើផែនដី នៅតែជាភស្តុតាងអំពីកិត្តិយសយ៉ាងអស្ចារ្យដូចជាព្រះ ដែលព្រះយេហូវ៉ាដាក់មកលើពូជពង្សទាំងអស់របស់ពួកគេ។ រូបរាងរបស់ព្រះអង្គ ទោះបីជាបានពុករលួយក៏ដោយ នៅតែឈរនៅក្នុងកន្លែង*គ្រប់គ្រង*របស់ខ្លួន។ ទំនុកដំកើង ៤៥ គឺជាកំណាព្យរំឮកអំពីពិធីអភិសេកស្តេចសាឡូម៉ូនឱ្យឡើងសោយរាជ្យលើអ៊ីស្រាអែល។ នៅត្រង់នេះ ព្រះអង្គឈរជាស្តេចរបស់ព្រះយេហូវ៉ាអ្នកចម្បាំងប្រកបដោយសេចក្តីសុចរិត *គ្រប់គ្រង*ដោយនៅក្នុងសិរីរុងរឿង និងអត្តចរិតរបស់ព្រះយេហូវ៉ា។បល្ល័ង្ករបស់ព្រះអង្គ និងបល្ល័ង្ករបស់ព្រះយេហូវ៉ាគឺតែមួយ។ ប៉ុន្តែ តើព្រះអង្គស្ទើរតែជាមនុស្សយ៉ាងអស្ចារ្យឬ? នៅក្នុងទំនុកដំកើង ៧២ យើងអានអំពីការថ្វាយព្រះពរក្នុងពិធីអភិសេកឡើងគ្រងរាជ្យលើស្តេចមួយអង្គដែលនឹងយាងមក ព្រះអង្គពោរពេញទៅដោយសេចក្តីសុចរិត និងការប្រោសលោះ ដោយជួយសង្គ្រោះមនុស្សជាច្រើនព្រមទាំង*ការគ្រប់គ្រង*លាតសន្ធឹងពីសមុទ្រមួយទៅសមុទ្រមួយអស់កល្បជានិច្ច! ប្រាជ្ញាបង្ហាញថា *ការគ្រប់គ្រង*នៅលើផែនដីរបស់មនុស្ស និង*ការគ្រប់គ្រង*យ៉ាងគ្រប់លក្ខណ៍របស់ព្រះយេហូវ៉ា នឹងបានពាសពេញលើសពីការបាត់បង់របស់លោកអ័ដាម និងហួសពីការស្មានទៅទៀត។



**<u>ប្រធានបទ ៧: ការគ្រប់គ្រងត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីការនៅក្រោមការគ្រប់គ្រង</u>**

## ប្រធានបទ: **ការគ្រប់គ្រង**

## សម័យ: **ពួកហោរា**

**<u>គ១៣ ការពណ៌នាតាមរូបភាព:</u>** ខ្លួន និងក្បាលគំនូរមនុស្សម្នាក់យ៉ាងធំ ដែលលាតសន្ធឹងដៃពីលើក្បាលមនុស្សជាច្រើនដែលមានពាក់មកុដ។ ដៃរបស់មនុស្សម្នាក់នេះវែងចម្លែក ហើយរលកហាក់បីដូចជាទង់ជ័យកំពុងបក់ នៅពេលដែលមានខ្យល់បក់រំភើយៗ។ មានមកុដធំមួយដែលមានផ្កាយរបស់ស្តេចដាវីឌបាំងត្រង់ចង្កេះរូបនោះ។ មានក្បាលមនុស្ស២០ដែលមានពាក់មកុដ។

**<u>បទគម្ពីរ:</u>** អេសាយ ១១:១០-១៦, ដានីយ៉ែល ៤:១៣-១៤, ៧:២១-២៧។

**<u>គំនិតប្រធានបទ:</u>** ពួកហោរាប្រកាសអំពីព្រះមែសី ដែលនឹងជាទង់ជ័យ (អេសាយ ១១:១០, ១២ ជាសញ្ញាអំពីទង់ជ័យ/បទដ្ឋាននៃសង្គ្រាម/*ការគ្រប់គ្រង*)ដល់មនុស្សដែលនឹងធ្វើជាស្តេច ដែលនឹងយកឈ្នះខ្មាំងសត្រូវទាំងអស់ដែលនឹង*គ្រប់គ្រង*លើពិភពលោកទាំងមូល ហើយដែល*ការគ្រប់គ្រង*របស់ព្រះអង្គនឹងធ្វើឱ្យប្រជារាស្ត្ររបស់ព្រះយេហូវ៉ាក្លាយទៅជាស្តេចខ្លួនពួកគេផ្ទាល់។ អ្វីដែលព្រះជាម្ចាស់បានធ្វើនៅក្នុងប្រវត្តិសាស្ត្រជាក់ស្តែង ឥឡូវនេះព្រះអង្គប្រាប់ទុកមុនអំពី*ការគ្រប់គ្រង*ខាងវិញ្ញាណ/ខាងក្នុងចិត្ត/បែបប្រៀបធៀប ដែលព្រះអង្គនឹងស្អាងឡើងវិញសម្រាប់ស្នាព្រះហស្តរបស់ព្រះអង្គដែលបានធ្លាក់ចុះតាមរយៈសេចក្តីសន្យារបស់ព្រះអង្គដល់លោកអ័ប្រាហាំ។



## ប្រធានបទ ៧: ការគ្រប់គ្រងត្រូវបានស្តារឡើងវិញសេចក្តីសង្គ្រោះចេញពីការនៅក្រោមការគ្រប់គ្រង

## ប្រធានបទ: **ការគ្រប់គ្រង**

## សម័យ: **ប្រជារាស្ត្រដែលនៅសល់**

**គ១៥ ការពណ៌នារូបភាព:** មានផ្ទាំងថ្មដែលមានបញ្ញត្តិដប់ប្រការមួយចំណែក ត្រួតពីលើផ្ទាំងថ្មនោះ មានក្រាំងដែលមានអក្សរចាប់តាំងពីសំបុត្ររបស់ស្តេចអើថាសើកសេសរហូតដល់អែសរ៉ា។ កាត់ពីលើរូបទាំងពីរ មានញញួររបស់ចៅក្រមនិងដុំឈើបួនជ្រុង (ដំបងរាជកាលពីសម័យបុរាណមិនសូវមានគេស្គាល់ទេប៉ុន្តែជានិមិត្តរូបដែលត្រូវអំពីបញ្ញា និងអំណាចរបស់ស្តេច)។

**បទគម្ពីរ:** ២ របាក្សត្រ ២៦, អេសាយ ៤៤-៤៥ (អាចបំបែកការសិក្សា/ក្រុមនៅត្រង់នេះ) អែសរ៉ា ១, ៦,៧:១១; នេហេមា ២:១-៩។

**គំនិត ប្រធានបទ:** ព្រះយេហូវ៉ា ជា *អ្នកគ្រប់គ្រង* ព្រះអង្គបានធ្វើឱ្យរង្គោះរង្គើអំណាច និងសិទ្ធិអំណាច *សាសន៍ដទៃ* ដើម្បីបង្កើតអំណាច និងសិទ្ធិអំណាចសម្រាប់ប្រជារាស្ត្ររបស់ព្រះយេហូវ៉ា គឺនៅពីក្រោមព្រះយេហូវ៉ា ប៉ុន្តែនៅពីលើខ្មាំងសត្រូវរបស់ពួកគេ ត្រលប់ទៅក្នុងទឹកដីរបស់ពួកគេវិញ ។ មហាអំណាចដែលជាសត្រូវទាំងនេះបានចំណាយយ៉ាងសន្ធឹកសន្ធាប់ដើម្បីឱ្យជនជាតិយូដាជាច្រើនពាន់នាក់វិលត្រលប់ទៅវិញ និងបង្កើត*ការគ្រប់គ្រង*របស់ព្រះជាម្ចាស់នៅក្នុងនគររបស់ព្រះអង្គដែលប្រកាន់ព្រះធិបតេយ្យ!លោកអេសាយបានថ្លែងទំនាយអំពីមហាអំណាចសាសន៍ដទៃ ឈ្មោះស៊ីរូស ១៤០ឆ្នាំមុននិរទេស ។ ប្រវត្តិវិទូជនជាតិយូដាម្នាក់ឈ្មោះ យ៉ូសែបហ្វ៊ុស បានកត់ត្រាថា ពេលដែលស្តេចស៊ីរ៉ុសអានពាក្យទំនាយទាំងនេះ «ព្រះអង្គមានបំណង និងមហិច្ឆតាពិតប្រាកដ ដើម្បីសម្រេចអ្វីដែលបានកត់ត្រាទុក»។ កណ្ឌគម្ពីរអេសធេរផ្តល់គំរូជាច្រើនអំពីការនេះ អំណាចរបស់ម៉ាដេកាយគឺជាគំរូអំពី*ការគ្រប់គ្រង*ដែលបានប្រទានមកយ៉ាងអស្ចារ្យតាមរយៈព្រះគុណរបស់ព្រះជាម្ចាស់។



**<u>ប្រធានបទ ៧: ការគ្រប់គ្រងត្រូវបានស្តារឡើងវិញសេចក្តីសង្រ្គោះចេញពីការនៅក្រោមការគ្រប់គ្រង</u>**

ប្រធានបទ: **ការគ្រប់គ្រង**

សម័យ: **ព្រះយេស៊ូវ**

***<u>គ១៧ ការពណ៌នារូបភាព:</u>*** *រូបភាពនេះបង្ហាញមែកធាងចាកពីរ ព្រះយេស៊ូវជិះសត្វលា ចានខ្លាំដែលមានទឹក ដៃលាងសំអាតជើង ព្រះយេស៊ូវនៅលើឈើឆ្កាង។*

**<u>បទគម្ពីរ:</u>** ម៉ាថាយ ២០:១៧-១៩, ២៩-៣៤, ២១:១-១១ (នៅក្នុងបរិបទ សាការី ៩:៩-១១) យ៉ូហាន ១៣:១-១៧,យ៉ូហាន ១៣:១-១៧ ភីលីព ២:៥-១០, កូល៉ុស ២:១៣-១៥។

**<u>គំនិតប្រធានបទ:</u>** នៅក្នុងព្រះយេស៊ូវ ដ៏ជាស្តេច យើងរកឃើញការចាប់កំណើតជាថ្មីនៃអត្ថន័យរបស់*ការគ្រប់គ្រង*។ យើងឃើញស្តេចមួយអង្គជិះលើកូនលាដោយមានជ័យជម្នះ មិនមែនសេះអ្នកចម្បាំងទេ។ នៅក្នុងព្រះយេស៊ូវ ដ៏ជាស្តេច យើងរកឃើញអត្ថន័យថ្មីរបស់ការគ្រប់គ្រង។ យើងឃើញស្តេចមួយអង្គធ្វើកិច្ចការរបស់បាវបម្រើដែលមានឋានៈទាបជាងគេបំផុត គឺលាងជើងដែលកខ្វក់ ស្តេចមួយអង្គដែលលះបង់ព្រះជន្មរបស់ព្រះអង្គសម្រាប់ប្រជារាស្ត្ររបស់ទ្រង់ ស្តេចមួយអង្គដែលមិនមែនមកពីលោកិយនេះទេ។ស្តេចអង្គនេះនឹងប្រើការរងទុក្ខវេទនា និងការបរាជ័យរបស់ខ្លួនដើម្បីផ្តួលរំលំសេចក្តីអាក្រក់ទាំងអស់របស់លោកិយ និងស្ថាននរក ព្រមទាំងយកឈ្នះពួកមានអំណាចទាំងអស់ ដោយ*អំណាចគ្រប់គ្រង*ប្រកបដោយសេចក្តីស្រឡាញ់របស់ព្រះយេហូវ៉ា (សូមមើលឧយោង ភីលីព ២ និង កូល៉ុស ២)។



**ប្រធានបទ ៧: ការគ្រប់គ្រងត្រូវបានស្តារឡើងវិញ សេចក្ដីសង្គ្រោះចេញពីការនៅក្រោមការគ្រប់គ្រង**

ប្រធានបទ: **ការគ្រប់គ្រង**

សម័យ: **ក្រុមជំនុំ**

**គ២០ ការពណ៌នារូបភាព:** បេះដូងមួយយ៉ាងធំនៅផ្នែកខាងក្រោយ មានមកុដនៅពីលើ មានកូនសោជាច្រើនជាប់នឹងកងបណ្ដោងសោមួយ និងមានរូបភាពភពផែនដី។

**បទគម្ពីរ:** ទាក់ទងនឹងការសោយរាជ្យនៅក្នុងក្រុមជំនុំ និងនៅក្នុងពិភពលោក សូមមើលម៉ាថាយ១៦:១៦-១៩ និង ២៨:១៦-២០ កូល៉ុស ១:១៨។ ការសោយរាជ្យជាថ្មីនៅក្នុងយើង (អាចបំបែកការសិក្សា/ក្រុមនៅត្រង់នេះ) សូមមើលរ៉ូម ៥:១៧, ២១, ៦:១២, ៨:៣៧, អេភេសូរ ១:២២,៣:១០,២១, ៥:២៣,កូល៉ុស ១:១៨, ១ ធីម៉ូថេ ៣:១៥។

**គំនិតប្រធានបទ:** «នគរ»ថ្មី លែងមានភូមិសាស្ត្រទៀតហើយ ប៉ុន្តែខាងវិញ្ញាណ និងខាងសាច់ឈាម។ នៅក្នុងម៉ាថាយ១៦ ព្រះយេស៊ូវមានបន្ទូលអំពី*ការគ្រប់គ្រង*ថ្មី ពាក់ព័ន្ធជាមួយនឹងក្រុមជំនុំ ដោយប្រៀបធៀបទៅនឹងកូនសោ ថ្មដា និងទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់។ នៅក្នុងជំពូក ២៨ ក្នុងនាមជាស្ដេច ដែលជាអ្នក*គ្រប់គ្រង* ព្រះអង្គប្រគល់បេសកកម្មរបស់ព្រះអម្ចាស់នៃចម្រូត។ ចាប់តាំងពីពេលនេះទៅ *ការគ្រប់គ្រង*របស់នគរព្រះអង្គទៅដល់សាសន៍ដទៃត្រលប់ជាអន្តរជាតិ មានគ្រប់ជនជាតិ គ្រប់ប្រទេសទាំងអស់ និងរីកសុះសាយជាច្រើនសតវត្សតទៅ ប៉ុន្តែ*ការគ្រប់គ្រង*ដែលត្រូវបានស្ដារឡើងវិញនោះ ស្ថិតនៅក្នុងចិត្តរបស់មនុស្ស មិនមែនគ្រាន់តែលើការប្រព្រឹត្តិរបស់មនុស្ស ឬព្រំដែនប៉ុណ្ណោះទេ។ប្រជារាស្ត្ររបស់ព្រះអង្គសោយរាជ្យនៅក្នុងជីវិត ហើយរកឃើញអំណាចរបស់ពួកគេលើសត្រូវដ៏អាក្រក់បំផុតរបស់ពួកគេគឺអំពើបាប សេចក្តីស្លាប់ និងអារក្សសាតាំង ដោយព្រោះតែអ្វីដែលព្រះយេស៊ូវធ្វើ ដើម្បី*គ្រប់គ្រង* វាសនាដ៏នៅអស់កល្បជានិច្ចរបស់ពួកគេ។



**<u>ប្រធានបទ ៧: ការគ្រប់គ្រងត្រូវបានស្តារឡើងវិញ</u>**

**<u>សេចក្តីសង្គ្រោះចេញពីការនៅក្រោមការគ្រប់គ្រង</u>**

## ប្រធានបទ: **ការគ្រប់គ្រង**

## សម័យ: **ការបង្កើតថ្មី**

**<u>គ២៤ ការពណ៌នារូបភាព:</u>** ព្រះយេស៊ូវមានពាក់មកុដ កំពុងតែញញឹម អង្គុយនៅលើបល្ល័ង្ក ព្រះអង្គលូកព្រះហស្ត មកឱបមនុស្សជាច្រើនដែលមានពាក់មកុដ កំពុងតែអង្គុយនៅលើដៃបល្ល័ង្ក/បល្ល័ង្ក/ឈរនៅក្បែរព្រះអង្គ។ នេះជាសញ្ញាបង្ហាញអំពីការសោយរាជ្យជាមួយព្រះអង្គ។

**<u>បទគម្ពីរ:</u>** ដានីយ៉ែល ៧:១៤, ១៧-១៨, ២៧, វិវរណៈ ២:២៦, ៣:២១, ៥:១០, ២២:៥។

**<u>គំនិត ប្រធានបទ:</u>** បទគម្ពីរផ្សេងៗចង្អុលទៅរកថ្ងៃមួយ ដែលប្រជារាស្ត្ររបស់ព្រះជាម្ចាស់នឹង *គ្រប់គ្រង*ជាមួយព្រះអង្គមានសិទ្ធិអំណាចរបស់ព្រះអង្គលើប្រជាជាតិនានា អង្គុយលើបល្ល័ង្ករួមជាមួយព្រះជាម្ចាស់ដោយធ្វើជាសង្ឃហ្លួង។ អត្ថបទទាំងនេះនឹងបានសម្រេច នៅពេលដែលឈុតក្នុង វិវរណៈ ២២ ក្លាយជាការពិត គឺយើងនឹងសោយរាជ្យជាមួយព្រះអង្គនៅក្នុង*ការគ្រប់គ្រង*នោះ ដែលកាលពីដំបូងឡើយ ព្រះអង្គបានឱ្យទៅលោកអ័ដាម និងនាងអេវ៉ា។ ព្រះអង្គបានស្តារ*ការគ្រប់គ្រង*នោះឡើងវិញ បានសម្រេច និងបានពង្រីកធំឡើងនៅក្នុងព្រះគ្រីស្ទ។ នៅក្នុងអ័ដាមទីពីរ យើងនឹងរួមចំណែកនៅក្នុង*ការគ្រប់គ្រង*លើអ្វីៗដែលព្រះអង្គបង្កើតជាថ្មី ពេលនេះគ្មានអំពើបាបទេ គឺជារៀងរហូត។

## ការឆ្លុះបញ្ចាំងអំពីទន្លេ "ការគ្រប់គ្រង និងការបរាជ័យ":

តើការមួយចំនួនដែលលោកអ្នកចាប់អារម្មណ៍ នៅពេលដែលលោកអ្នកបានធ្វើដំណើរយ៉ាងលឿនឆ្លងកាត់ទន្លេ «ការគ្រប់គ្រង» មានអ្វីខ្លះ?

តើមានអ្វីខុសប្លែក តើមានចង្វាក់បែបណា តើមានអ្វីគួរឱ្យចាប់អារម្មណ៍ តើមានអ្វីគួរឱ្យភ្ញាក់ផ្អើល?

តើលោកអ្នកកំពុងមានអារម្មណ៍យ៉ាងដូចម្ដេចអំពីព្រះយេហូវា ដ៏ជាព្រះ?

# ប្រធានបទទី ៤: ព្រះពរ

នៅពេលបង្កើត អ័ដាម និងនាងអេវ៉ាមាន **ព្រះពរ** របស់ព្រះជាម្ចាស់ ដែលបាន មានបន្ទូលមកលើពួកគេ (លោកុ ១:២៨)។ ពួកគេរស់នៅក្នុង **ព្រះពរថ្ងៃសប្ប័ទ** ជាមួយព្រះយេហូវ៉ា (២:៣) ហើយរីករាយនឹងអំណោយនៃអ្វីៗទាំងអស់ ព្រម ទាំង **ព្រះពរ** យ៉ាងលើសលប់នៅក្នុងសួនឧស្យានរបស់ព្រះអង្គ!

ប៉ុន្តែ **ព្រះពរ** ត្រូវបានបាត់បង់ទៅ នៅពេលដែលពួកគេបានបដិសេធ **អ្នក ប្រទានឱ្យ**។ **បណ្ដាសា** និង **ការដាក់ទោស** បានមកតាមក្រោយ។ ពួកគេមិនអាច ធ្វើអ្វីបាន ដើម្បីទទួលបាន **ព្រះពរ** កាលពីដំបូងរបស់ពួកគេឡើងវិញទេ!

តើព្រះយេហូវ៉ាអាចឈោងហួស **បណ្ដាសា** និង **ការដាក់ទោស** ដើម្បីនាំពួកគេ ត្រលប់ចូលមកក្នុង **ព្រះពរ** វិញបានដែរឬទេ ហើយតើព្រះអង្គនឹងធ្វើបែបនោះ ដែរឬទេ?



**ប្រធានបទ ៤: ព្រះពរត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីបណ្តាសា**

## ប្រធានបទ: **ព្រះពរ**

## សម័យ: **បុព្វបុរស**

**ព៥ ការពណ៌នារូបភាព:** ស្នាមនៅលើខ្សាច់មានស្នាមជើងមនុស្សនៅកណ្តាល (លោកអ័ប្រាហាំ) បន្ទាប់មកមានគំនូសតំណាងឱ្យស្នាមកង់រទេះ ដែលដឹកទ្រព្យសម្បត្តិ រួចមានស្នាមជើងសត្វអូដ្ឋនៅខាងឆ្វេងស្នាមជើងសេះ (មានន័យថា សត្វលា) នៅខាងស្តាំ បន្ទាប់មកទៀត ស្នាមជើងសត្វគោនៅខាងឆ្វេង និងស្នាមជើងសត្វចៀម/ពពែនៅខាងស្តាំ រួចហើយមានមានស្នាមជើងមនុស្សនៅខាងក្រៅ តំណាងឱ្យអ្នកបម្រើ និងបាវបម្រើ។

**បទគម្ពីរ:** លោកុប្បត្តិ:១២:១០-១៧; ២០; ២៦:១-១៤។

**គំនិតប្រធានបទ:** ទំនាក់ទំនងរវាងពូជពង្សរបស់លោកអ័ប្រាហាំ និងប្រជាជាតិនានា ដែលជាសត្រូវ ជាពួកថ្វាយបង្គំរូបព្រះ ជាពិសេសពួកអេស៊ីព្ទ និងពួកភីលីស្ទីន ត្រូវបានសំគាល់ដោយ *ព្រះពរ*ដែលហូរចេញពីពួកគេទៅឯលោកអ័ប្រាហាំ/អ៊ីស្រាអែល។ រឿងចម្លែកទាំងនេះនៅក្នុងលោកុប្បត្តិ ១២, ២០, និង ២៦ មិនមាននិយាយអំពីសីលធម៌ឬអសីលធម៌ទេ ប៉ុន្តែដើរតួជាសេចក្តីបន្ទាល់អំពីភាពមិនប្រែប្រួលនៃសេចក្តីសន្យារបស់ព្រះជាម្ចាស់ថា «*នឹងឱ្យពរដល់អ្នកដែលឱ្យពរអ្នក*» ហើយ«*ដាក់បណ្តាសាដល់អ្នកដែលដាក់បណ្តាសាអ្នក*» ទោះជាលោកអ័ប្រាហាំមានគុនធម៌ ឬមិនមានគុណធម៌ក៏ដោយ។ ឈុតមួយចំនួនតូចដែលត្រូវបានលើកឡើងនៅត្រង់នេះ គ្រាន់តែជាឈុតដំបូងក្នុងចំណោមឈុតដែលនិយាយអំពីការផ្លាស់ប្តូរពូជសាសន៍នៅក្នុងប្រវត្តិសាស្ត្រសញ្ញាចាស់ដែលនិយាយអំពីប្រជារាស្ត្ររបស់ព្រះជាម្ចាស់។



**ប្រធានបទ ៩: ព្រះពរត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីបណ្តាសា**

## ប្រធានបទ: **ព្រះពរ**

## សម័យ: **និក្ខមនំ និងការវាយដណ្តើមបាន**

**ពា ការពណ៌នារូបភាព:** ប្រអប់ដៃឱ្យពរបួនផ្តុំមករកចំណុចកណ្តាល ដែលត្រូវបានគំរាមកំហែងដោយប្រអប់ដៃហិង្សាពីរមកពីខាងក្រោម។ មានប្រអប់ដៃឱ្យពរដ៏ធំពីរ គឺធំជាងប្រអប់ដៃដទៃទៀតទាំងអស់។នៅពីក្រោយរូបទាំងអស់នេះ មានរូបត្រសាលរបស់ជនជាតិអ៊ីស្រាអែលដែលនៅក្បែរអូរយ័រដាន់ និងទឹកដីសន្យា។

**បទគម្ពីរ:** ជនគណនា ២២-២៤ ។

**គំនិតប្រធានបទ:** ប្រអប់ដៃកំណាចទាំងពីរតំណាងឱ្យបាឡាក និងបាឡាម ជាតួអង្គមនុស្សសំខាន់នៅក្នុងរឿងនេះ។ ប្រអប់ដៃឱ្យពរទាំងបួនតំណាងឱ្យ *ព្រះពរ*ទាំងបួនដែលបាឡាមបានប្រកាសមកលើជនជាតិអ៊ីស្រាអែល ។ ប្រអប់ដៃដ៏ធំដែលនៅខាងក្រោយ គឺជា*ព្រះពរ*របស់ព្រះជាម្ចាស់មកលើប្រជារាស្ត្ររបស់ព្រះអង្គ ដែលបានផ្លាស់ប្តូរសេចក្តីចេញពីបាឡាក និងបាឡាម ហើយធ្វើឱ្យមាន*ព្រះពរ*ទាំងបួន។ សេចក្តីសន្យារបស់ព្រះជាម្ចាស់ថានឹងឱ្យ*ពរ*លោកអ័ប្រាហាំ និងគ្រួសាររបស់លោក ឥឡូវនេះត្រូវបានពង្រីក ដើម្បីឱ្យ*ពរ*ដល់គ្រួសាររបស់លោកអ័ប្រាហាំរាប់លាននាក់ ដោយព្រះហឫទ័យសប្បុរសយ៉ាងអស្ចារ្យ។ *បណ្តាសា*របស់បាឡាក់ បាឡាម និងម្ចាស់របស់ពួកគេ គឺអារក្សសាតាំង គ្មានអំណាចទេនៅក្រោម*ព្រះពរ*របស់ព្រះយេហូវ៉ា។



**ប្រធានបទ ៤: ព្រះពរត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីបណ្តាសា**

ប្រធានបទ: **ព្រះពរ**

សម័យ: **ស្តេច**

**៣៩ ការពណ៌នារូបភាព:** មហាក្សត្រីស្រុកសេបាអង្គុយនៅលើសត្វលាដែលមានការតុបតែងលំអរ នៅក្នុងក្បួនធ្វើដំណើរមកក្រុងយេរូសាឡិម ដើម្បីជួបនឹងស្តេចសាឡូម៉ូន ជាស្តេចសាសន៍អ៊ីស្រាអែល។

**បទគម្ពីរ:** ១ពង្សាវតារក្សត្រ:៤:២០-៣៤, ៩:១០-២៨,១ ពង្សាវតារក្សត្រ១០, ២ របាក្សត្រ ៩។

**គំនិតប្រធានបទ:** ព្រះជាម្ចាស់*បានប្រទានពរ*យ៉ាងបរិបូរដល់ប្រជារាស្ត្រដែលព្រះអង្គបានរើសតាំង គឺឱ្យមាន*ព្រះពរ*គ្រប់បែបយ៉ាងនៅផែនដី រួមទាំងទ្រព្យសម្បត្តិ ប្រាជ្ញា សេចក្តីសុខសាន្ត ការគ្រប់គ្រង សុវត្ថិភាព សួយសារ-អាករ វិទ្យាសាស្ត្រចំណេះដឹង កេរ្តិ៍ឈ្មោះ ។ល។ មហាក្សត្រីស្រុកសេបា ទទួលស្គាល់*ព្រះពរ*ទាំងនេះ ដែលគ្មានអ្វីប្រៀបបាន ថាមកពីព្រះយេហូវ៉ា។ *ព្រះពរ*ទាំងអស់ដែលបានសន្យាឱ្យដល់លោកអ័ប្រាហាំ ត្រូវបានសម្រេចយ៉ាងច្បាស់ក្រឡែត លើកលែងតែសេចក្តីសន្យាចុងក្រោយនៅក្នុងលោកុប្បត្តិ១២:៣។ សេចក្តីសន្យាមួយនេះនឹងមិនទាន់សម្រេចឡើយ រហូតដល់ព្រះជាម្ចាស់បានបង្ហាញឱ្យប្រជារាស្ត្ររបស់ព្រះអង្គឃើញថា *ព្រះពរ*នៅផែនដីទោះជាច្រើនយ៉ាងណាក៏ដោយ នឹងមិនគ្រប់គ្រាន់ល្មមដើម្បីជួយសង្គ្រោះពួកគេចេញពីជម្ងឺនៅក្នុងព្រលឹង ដែលត្រូវការ*ព្រះពរ*ដ៏សំខាន់ដែលមកជាមួយព្រះមែស៊ី។



**ប្រធានបទ ៩: ព្រះពរត្រូវបានស្ដារឡើងវិញ សេចក្ដីសង្គ្រោះចេញពីបណ្ដាសា**

ប្រធានបទ: **ព្រះពរ**

សម័យ: **ឆ្នាំជ្វា**

**ពាក្យ ការពណ៌នារូបភាព:** ជួរដេកផ្នែកខាងលើមានមានក្មេងប្រុសម្នាក់ដែលមានលេខ ៧ ក្មេងស្រីម្នាក់ដែលមានលេខ ៣ សត្វចៀមមួយក្បាល សត្វអូដ្ឋមួយក្បាល គោមួយក្បាល លាមួយក្បាល និងមនុស្សមួយក្រុម។ ជួរដេកផ្នែកខាងក្រោមមានរូបដូចគ្នាតាមលំដាប់លំដោយនេះវិញ សត្វចៀម សត្វអូដ្ឋ សត្វគោ សត្វលា ក្មេងប្រុងលេខ ៧ ក្មេងស្រីលេខ ៣ និងមនុស្សមួយក្រុម (ពេលនេះ រៀបតាមទំហំពីធំមកតូច)។ នៅចំកណ្ដាលផ្នែកខាងឆ្វេងមានរូបដើមឈើល្អមួយ នៅក្បែរផ្លូវទឹកហូរគ្រឿនៗហើយមានមនុស្សរីករាយម្នាក់កំពុងអង្គុយអានក្រាំងនៅលើមែកឈើខាងលើ។ នៅចំកណ្ដាល ផ្ទៃទឹកដដែលនេះកក្រើកជារលកសមុទ្រ ដែលមានប៉មមួយលេចចេញពីក្នុងមកដោយមានមនុស្សរីករាយម្នាក់កំពុងអធិស្ឋាននៅផ្នែកខាងលើនៃប៉មនោះ។

**បទគម្ពីរ:** យ៉ូប ១:១-៥ និង ៤២:១០+ ទំនុកដំកើង ៣២ ទំនុកដំកើង ១ សូមមើលផងដែរ (មិនមាននៅក្នុងរូបគំនូរ) ទំនុកដំកើង ២១, ៦៧, ១១២, ១១៥, ១២៨ (អាចបំបែកការសិក្សា/ក្រុមនៅត្រង់នេះៈយ៉ូប និងទំនុកដំកើង ៣២ ទំនុកដំកើង ១, ១១២, ១២៨ ទំនុកដំកើង ២១, ៦៧, ១១៥)។

**គំនិតប្រធានបទ:** ទំនុកដំកើង ១ អបអរនឹងព្រះពររបស់ព្រះយេហូវ៉ាលើអ្នកដែលរត់ចេញពីអំពើបាបហើយទុកចិត្តលើព្រះបន្ទូលរបស់ព្រះយេហូវ៉ាតែមួយប៉ុណ្ណោះ។ ទំនុកដំកើង ៣២ អបអរនឹងរបៀបដែលព្រះយេហូវ៉ា *ប្រទានព្រះពរ*នៃការអត់ទោសឱ្យដល់អ្នកដែលបានបះបោរប្រឆាំងនឹងព្រះអង្គ។ ទំនុកដំកើងនិយាយអំពីទឹក ប៉ុន្តែមានអត្ថន័យផ្ទុយគ្នា។ ការរងទុក្ខវេទនារបស់លោកយ៉ូបត្រូវបានហ៊ុំព័ទ្ធពីមុខ (ខាងលើ) ពីក្រោយ (ខាងក្រោម) ដោយ *ព្រះពរ* ខាងសាច់ឈាម។តាមរយៈការបញ្ចប់ទាំងនេះនៅក្នុងកណ្ឌគម្ពីរ ព្រមទាំងសេចក្ដីអធិស្ឋានចុងក្រោយរបស់លោកប្រាជ្ញាសួរយើងថាតើសូម្បីតែការរងទុក្ខវេទនារបស់លោកអាចជា *ព្រះពរ*មួយផ្នែករបស់ព្រះយេហូវ៉ាដែរឬយ៉ាងណា។



**<u>ប្រធានបទ ៤: ព្រះពរត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីបណ្តាសា</u>**

# ប្រធានបទ: **ព្រះពរ**

# សម័យ: **ពួកហោរា**

**<u>៣១៣ ការពណ៌នារូបភាព:</u>** មានមនុស្សបីនាក់ដែលមានស្លៀកពាក់តាមវប្បធម៌របស់ពួកគេ តំណាងឱ្យជនជាតិអេស៊ីព្ទ ជនជាតិអ៊ីស្រាអែល និងជនជាតិអាស៊ីរី ។ មានផ្លូវធំមួយ រត់កាតពីក្រោយពីមនុស្សទាំងនោះកាត់តាមអ៊ីស្រាអែលទៅស្រុកអាស៊ីរី។ បាទដៃឱ្យពរដ៏ធំរបស់ព្រះជាម្ចាស់ក៏នៅពីក្រោយអ្នកទាំងនោះដែរ។

**<u>បទគម្ពីរ:</u>** អេសាយ ១៩:១-១៧, បន្ទាប់មកប្រៀបធៀបជាមួយ ១៨-២៥ ជាពិសេសពីរខចុងក្រោយ ។សូមមើលផងដែរសូមមើលផងដែរ អេសាយ ១១:១១, ១៥-១៦។

**<u>គំនិតប្រធានបទ:</u>** អាស៊ីរីបានវាយឈ្នះ និងបានធ្វើឱ្យកុលសម្ព័ន្ធទាំងដប់នៅនគរភាគខាងជើងបានបែកខ្ចាត់ខ្ចាយទៅក្នុងប្រជាជាតិនានា នៅតែកុលសម្ព័ន្ធអ៊ីស្រាអែលពីរប៉ុណ្ណោះនៅភាគខាងត្បូង ។ ពួកអ្នកស្មោះត្រង់នៅក្នុងអ៊ីស្រាអែលបានស្រែកអំពាវនាវអស់រយៈពេលជាច្រើនសតវត្សរ៍ ដែល*ព្រះពរ*របស់ព្រះយេហូវ៉ាហាក់បីដូចជាបានដកចេញ ដោយព្រោះតែពួកគេថ្វាយបង្គំរូបព្រះ និងបោះបង់ចោលជំនឿ ។ប៉ុន្តែ ពួកហោរានៅតែប្រកាសអំពីសេចក្តីសង្ឃឹម។ នៅក្នុងពាក្យទំនាយនេះ យើងឃើញ*ព្រះពរ*របស់ព្រះជាម្ចាស់មិនត្រឹមតែយកឈ្នះសត្រូវកាលពីយូរមក-ហើយរបស់អ៊ីស្រាអែលប៉ុណ្ណោះទេថែមទាំងដាក់ពួកគេចូលនៅក្នុង*ព្រះពរ*របស់ប្រជារាស្ត្រដែលបានរើសតាំងថែមទៀតផង។ ពួកគេប្រកាសថានឹងមានថ្ងៃមួយដែល*ព្រះពរ*របស់ព្រះជាម្ចាស់នឹង«រត់»ចេញពីប្រជារាស្ត្រដែលបានរើសតាំង ហើយមានដល់ប្រជាជាតិដែលបាត់បង់ដែលជាសត្រូវរបស់អ៊ីស្រាអែល។



**<u>ប្រធានបទ ៩: ព្រះពរត្រូវបានស្តារឡើងវិញ សេចក្តីសង្រ្គោះចេញពីបណ្តាសា</u>**

ប្រធានបទ: **ព្រះពរ**

សម័យ: **ប្រជាជនដែលនៅសល់**

**<u>៣១៥ ការពណ៌នារូបភាព:</u>** ថ្មឫសជញ្ជាំងព្រះវិហារ បង្ហាញជាបញ្ឆៀង ដោយមើលពីលើ ដែលផ្នែកខាងមុខដាក់កាលបរិច្ឆេទថា ១៨ ធ្នូ ៥២០ មុនគ្រិស្តសករាជ មានរូបភាពដើមស្រូវ ដើមទំពាំងបាយជូរ ដើមល្វា ដើមទទឹម និងដើមអូលីវនៅផ្នែកខាងក្រោយ។

**<u>បទគម្ពីរ:</u>** ហាកាយ ២ ជាពិសេស ខ១៨-១៩។

**<u>គំនិតប្រធានបទ:</u>** ជនជាតិអ៊ីស្រាអែលដែលបានត្រលប់មកវិញ ជាប្រជារាស្ត្ររបស់ព្រះយេហូវ៉ាដែលនៅសល់ បានកសាងកំពែងក្រុងយេរូសាឡិមឡើងវិញ ប៉ុន្តែបានបោះបង់ចោលការទទួលខុសត្រូវរបស់ពួកគេក្នុងការកសាងព្រះវិហារឡើងវិញ។ ហោរាហាកាយ រួមជាមួយលោកសាការី ដែលជាហោរាផង ជាសង្ឃផង ត្រូវបានព្រះជាម្ចាស់ចាត់មកដើម្បីបន្ទោស និងដាស់តឿនពួកបណ្តាជន។ លោកហាកាយបានពន្យល់ថា ការលំបាកខាងសេដ្ឋកិច្ចរបស់ពួកគេ គឺជាការដាក់ទោសយ៉ាងជាក់លាក់របស់ព្រះជាម្ចាស់សម្រាប់អំពើបាបសម្ភារៈនិយមរបស់ពួកគេ។ ពួកគេខ្វល់ខ្វាយអំពីការកសាងផ្ទះរបស់ពួកគេនៅលើផែនដីជាងអំពីការកសាងព្រះដំណាក់របស់ព្រះជាម្ចាស់នៅលើផែនដី។ ពួកគេបានប្រែចិត្ត ហើយបានត្រលប់មកធ្វើការវិញយ៉ាងលឿន។ នៅថ្ងៃមួយក្នុងខែមិគសិរ គឺក្រោយពីពួកគេបានទទួលផលមិនល្អ និងមុនពេលដែលពួកគេដាំដុះនៅចំការម្តងទៀត ពួកគេបានដាក់ថ្មឫសជញ្ជាំងព្រះវិហារឡើងវិញ។ ភ្លាមនោះ ព្រះជាម្ចាស់បានមានបន្ទូលថា ដំណាំ និងជីវភាពរបស់ពួកគេនឹងចម្រើនឡើង ដោយមានបន្ទូលសន្យាថា «ចាប់តាំងពីថ្ងៃនេះទៅ អញនឹង*ផ្តល់ពរ*ដល់ឯងវិញ»។



**ប្រធានបទ ៩: ព្រះពរត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីបណ្តាសា**

ប្រធានបទ: **ព្រះពរ**

សម័យ: **ព្រះយេស៊ូវ**

**ព១៧ ការពណ៌នារូបភាព:** ព្រះយេស៊ូវលើកថូរពីរដែលមានត្រចៀក ហើយចាក់ (អំណោយដែលបានរុំខ្ចប់និងក្រាំងគម្ពីរតំណាងឱ្យ«ព្រះគុណ» និង «សេចក្តីពិត») មករកអ្នកមើល ដូចដែលព្រះហស្តព្រះបិតាធ្វើបែបនោះដែរពីផ្នែកខាងលើនៃផ្ទាំងរូបភាពមកលើព្រះសិរសារបស់ព្រះយេស៊ូវ។

**បទគម្ពីរ:** ម៉ាថាយ ៥:១-១២, ១៣:១៦-១៧, យ៉ូហាន ១:១៤-១៦ កិច្ចការ ១៣:៣៤ រ៉ូម ១៥:២៩។

**គំនិតប្រធានបទ:** ព្រះយេស៊ូវមានបន្ទូលឱ្យ*ពរ*ជាច្រើនរបស់ព្រះជាម្ចាស់ដល់ប្រជារាស្ត្ររបស់ព្រះអង្គតាមរបៀបថ្មី នៅខាងក្នុង។ ប្រឆាំងនឹងបណ្តាសានៅពេលធ្លាក់ចុះ ព្រមទាំង*ព្រះពរ* និងបណ្តាសានៃសេចក្តីតាំងសញ្ញានៅភ្នំស៊ីណាយ នៅត្រង់នេះ ព្រះយេស៊ូវប្រទាន*ព្រះពរ*ដល់កូនចៅទាំងអស់របស់លោកអ័ដាមដែលនឹងរួមចំណែកនៅក្នុង*ភាពមានពរ*របស់ព្រះអង្គ។ ព្រះយេស៊ូវបាននាំព្រះពរដែលគ្មានទីបញ្ចប់មកឱ្យយើង មិនមែនជាការណែនាំអំពីសីលធម៌ទេ ប៉ុន្តែជាសេចក្តីប្រកាស និងជាសេចក្តីសន្យាត្រង់ៗមកពីព្រះជាម្ចាស់ គឺ *ព្រះពរ* «ហើយយើងទាំងអស់គ្នាបានទទួលអំពីសេចក្តីពោរពេញរបស់ទ្រង់មក គឺជាព្រះគុណថែមលើព្រះគុណផង»។ លោកយ៉ូហានប្រៀបធៀបការនេះទៅនឹងក្រិត្យវិន័យ និងចាត់ទុកការនេះថាជា «ព្រះគុណ និងសេចក្តីពិត»។



**<u>បទានបទ ៩: ព្រះពរត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីបណ្តាសា</u>**

ប្រធានបទ: **ព្រះពរ**

សម័យ: **ក្រុមជំនុំ**

**<u>១២០ ការពណ៌នារូបភាព:</u>** រូបភាពនិមិត្តរូបមួយចំនួននៅជួរដេកផ្នែកខាងលើៈ មុខមានពុកមាត់របស់ពួកហោរាមួយចំនួន (ឧទាហរណ៍ លោកម៉ូសេ លោកអេសាយ លោកសាំយូអែល លោកយេរេមា និងលោកដានីយ៉ែល)ដែលរូបភាពនីមួយៗជាន់ពីលើគ្នា។ ប្រអប់ដៃមួយដែលមានស្នាមដែកគោលលូកចុះមកជួយសង្គ្រោះប្រអប់ដៃមួយដែលបានលើកឡើងចេញពីប្រហោងពណ៌ខ្មៅមួយ។ បេះដូងពណ៌ក្រហមមួយដែលមានគំនូសសញ្ញាធំមួយប្រាប់ថាមានសុខភាពល្អ។ មានព្រាបពណ៌សមួយ។ ជួរដេកផ្នែកខាងក្រោមៈចង់ធំមួយស្រដៀងនឹងខាងលើ មានអក្សរ «ស្ថានសួគ៌»។ មានដៃមួយឈោងឡើង ដោយម្រាមដៃចង្អុលទៅរក(ជ្រើសរើស) អ្នកនៅកណ្តាលក្នុងចំណោមមនុស្សបីនាក់។ កាក់មួយដែលមានរូបព្រះសិរសារបស់ព្រះគ្រីស្ទ និងឈើឆ្កាងត្រាសំគាល់មួយដែលបញ្ជាក់ថា «ធានា» និង ១០០% «ផ្តិតលើក្រមួនក្រហម»។

**<u>បទគម្ពីរ:</u>** កិច្ចការ ៣:១៨-២៥ (រូបភាព ១) កិច្ចការ ៣:២៦ (រូបភាព ២) កាឡាទី ៣:៦-១៤ (រូបភាពទី ៣) កាឡាទី ៣:១៤ (រូបភាពទី ៤) អេភេសូរ ១:៣ (រូបភាពទី ៥) អេភេសូរ ១:៤-៦ (រូបភាពទី៦)អេភេសូរ ១:៧-១២ (រូបភាពទី ៧) និងអេភេសូរ ១:១៣-១៤ (រូបភាពទី ៨)។

**<u>គំនិតប្រធានបទ:</u>** នៅក្នុងកិច្ចការ ៣ លោកពេត្រុសប្រាប់អំពីរបៀបដែលគ្រីស្ទបរិស័ទថ្មីបានត្រលប់ទៅជាអ្នកស្នងមរតកនៃ*ព្រះពរ*ទាំងអស់ដែលបានសន្យាមកតាមរយៈហោរាម្នាក់ៗនៅក្នុងសញ្ញាចាស់ ពីព្រោះព្រះយេស៊ូវគឺជា«ពូជ»ដែលបានសន្យាដល់លោកអ័ប្រាហាំដោយផ្ទាល់ ដែលតាមរយៈព្រះអង្គ«គ្រប់ទាំងគ្រួនៅផែនដីនឹងបានពរ»។ កិច្ចការ ៣:២៦ ចែងថា *ព្រះពរ*នេះប្រទានមកជាលើកដំបូង នៅពេលដែលព្រះយេស៊ូវបង្វែរយើងចេញពីអំពើបាប។ កាឡាទី ៣ ពន្យល់ថា*ព្រះពរ*ដ៏ជាពូជនេះគឺយ៉ាងណានោះ ដែលយើងត្រូវបានញែកចេញជាបរិសុទ្ធ និងប្រោសឱ្យបានសុចរិតដោយសារការទុកចិត្ត (នោះគឺ ជំនឿ) មិនមែនក្រិត្យវិន័យទេ។ ខ ១៤ សរសើរការនេះដោយពណ៌នាការនេះថាជាការទទួលយកព្រះវិញ្ញាណដោយសេចក្តីជំនឿ។ អេភេសូរ ១:៣ ពណ៌នា*ព្រះពរ*មួយចង់យ៉ាងធំ ដែលព្រះជាម្ចាស់ប្រទានឱ្យយើងតាមរយៈព្រះយេស៊ូវ។ បីខទៀតពណ៌នាអំពី*ព្រះពរ*នៃការដែលត្រូវបានជ្រើសតាំង ប្រាំមួយខទៀតអំពី*ព្រះពរ*នៃការដែលត្រូវបានប្រោសលោះដោយសារព្រះលោហិតរបស់ព្រះអង្គ និងពីរខទៀតអំពី*ព្រះពរ*នៃការដែលត្រូវបានដៅចំណាំដោយព្រះវិញ្ញាណរបស់ព្រះអង្គយ៉ាងមានសុវត្ថិភាពសម្រាប់ស្ថានសួគ៌ គឺទាំងអស់«សម្រាប់ជាសេចក្តីសរសើរដល់សិរីល្អនៃទ្រង់»។



**ប្រធានបទ ៤: ព្រះពរត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីបណ្តាសា**

ប្រធានបទ: **ព្រះពរ**

សម័យ: **ការបង្កើតថ្មី**

**ពា២៤ ការពណ៌នារូបភាព:** ដើមជីវិតនៅក្បែរទន្លេជីវិត ដោយមានវាំងននរហែកចុះក្រោម មួយចំហៀងមកខាងឆ្វេង និងមួយចំហៀងទៀតមកខាងស្តាំនៃផ្ទាំងរូបភាព។

**បទគម្ពីរ:** លោកុប្បត្តិ ២:៨, ៣:៨, ២៤, ៤:២២-២៤, និក្ខមនំ ២៦:៣១-៣៥ លូកា ២៣:៤៣-៤៥ ម៉ាថាយ ២៧:៥១-៥៣ វិវរណៈ ២:៧, ២២:១-៣, ១៤។

**គំនិតប្រធានបទ:** ពាក្យ «ស្ថានសួគ៌» ដែលមានបីដងនៅក្នុងព្រះគម្ពីរ យោងទៅរកសួនសប្បាយរបស់ស្តេច ដែលព្រះអង្គចែករំលែកដល់គ្រួសារ និងភ្ញៀវដែលព្រះអង្គសព្វព្រះហឫទ័យ។ ព្រះជាម្ចាស់បានបង្កើតសួនច្បារអេដែនដែលដូចជាស្ថានសួគ៌សម្រាប់ឱ្យព្រះអង្គយាងមក«នៅពេលថ្ងៃល្ងើយ» (លោកុប្បត្តិ ២:៨, ៣:៨)។ សួនច្បារនោះមានដើមឈើជីវិត។ ទោះបីយ៉ាងណាក៏ដោយ នៅក្នុងលោកុប្បត្តិ៣ *ភាពដែលប្រកបដោយពរ*របស់យើងត្រូវបានបាត់ ដោយព្រោះតែបណ្តាសាដែលកើតមកពីការធ្លាក់ចុះ (ខ ១៦+) ហើយយើងមិនអាចចូលទៅកន្លែងនេះបានទៀតទេ ដោយព្រោះមានចេរូប៊ីនកាន់ដាវភ្លើងយាម (ខ ២៤)។ ប៉ុន្តែ យើងមើលឃើញនៅក្នុងនិក្ខមនំ ២៦ ថា ព្រះយេហូវ៉ា បង្ហាញ លោក ម៉ូសេ ពី របៀប ធ្វើ ចេរូប៊ីន ដែល យាម ការ ពារ រវាង ព្រះ ជា ម្ចាស់ និង មនុស្ស ហើយ នៅ ក្នុង លេវីវិន័យ (ជាពិសេសជំពូក ១៦)បង្ហាញយ៉ាងច្បាស់ពីរបៀបដែលរនាំងនេះអាចត្រូវបានយកឈ្នះដោយសារឈាមយញ្ញបូជាប៉ុណ្ណោះ។ នៅក្នុងលូកា ២៣ យើងឮព្រះយេស៊ូវសន្យាអំពីស្ថានសួគ៌ដែលបានបើកឡើងវិញនេះដល់ចោរម្នាក់។ នៅពេលដែលព្រះយេស៊ូវសុគត ព្រះជាម្ចាស់ផ្ទាល់បានហែកស្បៃដែលមានរចនាជាចេរូប៊ីន ដែលជានិមិត្តរូបអំពីការបណ្តេញលោកអ័ដាម និងនាងអេវ៉ាចេញ។ ម៉ាថាយ២៧:៥១-៥៣ ជាស្រមោលអំពីវិវរណៈ ជំពូក២ និង ២២ ដែលយើងអានអំពីថ្ងៃមួយ ដែលយើងនឹងបានស្គាល់ឱជារស ដោយរូបកាយយើងផ្ទាល់អំពីអ្វីដែលបានធានាសម្រាប់យើងខាងវិញ្ញាណ។ ពាក្យ*បណ្តាសា*នឹងបាត់ទៅ រនាំងដកចេញយើងនឹងមើលឃើញព្រះភ័ក្ត្រព្រះអង្គ នឹងស្គាល់ឱជារស និងត្រូវបានប្រោសឱ្យជាពីសេចក្តីស្លាប់ ព្រមទាំងនឹងត្រូវបានហៅថា «*អ្នកមានពរ*»របស់ព្រះអង្គអស់កល្បជានិច្ច។

## ការឆ្លុះបញ្ចាំងអំពីទន្លេ "ព្រះពរ និងបណ្ដាសា":

តើការមួយចំនួនដែលលោកអ្នកចាប់អារម្មណ៍ នៅពេលដែលលោកអ្នកបានធ្វើដំណើរយ៉ាងលឿនឆ្លងកាត់ទន្លេ «ព្រះពរ» មានអ្វីខ្លះ?

តើមានអ្វីខុសប្លែក តើមានចង្វាក់បែបណា តើមានអ្វីគួរឱ្យចាប់អារម្មណ៍ តើមានអ្វីគួរឱ្យភ្ញាក់ផ្អើល?

តើលោកអ្នកកំពុងមានអារម្មណ៍យ៉ាងដូចម្ដេចអំពីព្រះយេហូវ៉ា ដ៏ជាព្រះ?

# ប្រធានបទទី ៥: ភាពបរិសុទ្ធ

នៅពេលបង្កើត អ័ដាម និងនាងអេវ៉ាមាន **ភាពបរិសុទ្ធ** របស់ **ព្រះអម្ចាស់** ដែលបានប្រទានមកលើពួកគេ។ ពួកគេត្រូវបានបង្កើតឡើងចំនឹងរូបអង្គរបស់ **ព្រះយេហូវ៉ា** (លោកុ ១:២៦-២៧) ហើយពួកគេគ្មានអំពើបាបទាល់តែសោះ ដែលធ្វើឱ្យពួកគេរីករាយនឹងនៅជាអាក្រាតខ្លួនទទេ ដោយគ្មានសេចក្តីអៀនខ្មាសឡើយ (២:២៥)។

ប៉ុន្តែលទ្ធផលដំបូងរបស់អំពើបាបគឺជាទ្រនិចរោលរាលរបស់សេចក្តីអៀនខ្មាស នៅពេលដែល **ភាពបរិសុទ្ធ** ត្រលប់ជាមានស្លាកស្នាម-ដែលមិនរលប់។ ពួកគេបានពួនពី **ព្រះយេហូវ៉ា** និងពីគ្នាទៅវិញទៅមក ដោយមាន **សេចក្តីភ័យខ្លាច** និង **សេចក្តីអៀនខ្មាស**។ ពួកគេមិនអាចធ្វើអ្វីបាន ដើម្បីសម្អាតស្នាមប្រឡាក់ត្រលប់មកក្នុង **ភាពបរិសុទ្ធ** វិញបានទេ!

តើ **ព្រះយេហូវ៉ា** អាចលាងសម្អាត **ស្លាមប្រឡាក់** និងបង្កើត **ភាពបរិសុទ្ធ** របស់ពួកគេឡើងវិញបានដែរឬទេ ហើយតើព្រះអង្គនឹងធ្វើបែបនោះដែរឬទេ?



**ប្រធានបទ ៥: ភាពបរិសុទ្ធត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីអំពើបាប និងអារម្មណ៍ខុសឆ្គង**

## ប្រធានបទ: **ភាពបរិសុទ្ធ**

## សម័យ: **បុព្វបុរស**

**ប៥ ការពណ៌នាតាមរូបភាព:** ផ្នែកខាងក្រោយងងឹតមានផ្កាយពាសពេញនៅផ្នែកខាងលើ យោងទៅរក ១៥:៥-៦។ នៅចំកណ្តាលរូបភាពមានប្រអប់ដៃពីរ ប្រអប់ដៃមួយកាន់កូនកាំបិតពីរ (កូនកាំបិតមួយតំណាងឱ្យការស្តាប់បង្គាប់នៅក្នុងការកាត់ស្បែកនៅក្នុងជំពូក ១៧ កូនកាំបិតមួយទៀតតំណាងឱ្យការសម្លាប់អ៊ីសាក់នៅក្នុងជំពូក ២២)។ ប្រអប់ដៃមួយទៀតកាន់រងើកភ្លើងដែលកំពុងឆេះ (លោកុ ២២:៦)ចិញ្ចៀនអាពាហ៍ពិពាហ៍នៅផ្នែកខាងក្រោមបំផុតនៃរូបភាព។

**បទគម្ពីរ:** លោកុប្បត្តិ ១៥:៥-៦, ១៧, ១៨:១៩, ២២, ២៦:៥ លេវីវិន័យ២០:២៦។

**គំនិតប្រធានបទ:** ចិញ្ចៀមអាពាហ៍ពិពាហ៍ជាសញ្ញាអំពីការដែលត្រូវបាន«*កាត់ចេញ*»ពីគ្រួសារ និងអ្នកតាមស្រឡាញ់ ការផ្លាស់ប្តូរឈ្មោះ ពាក្យសម្បថអំពីភាពស្មោះត្រង់ និងភាពជាសាច់ញាតិ ចំណងគ្រួសារថ្មី ម្ចាស់កម្មសិទ្ធិថ្មី និងស្វាមីភក្តិ អត្តសញ្ញាណថ្មី។ ការកាត់ស្បែកគឺជាពិធី*កាត់*កាលពីបុរាណ គឺជានិមិត្តរូបអំពីការញែកចេញសម្រាប់ទំនាក់ទំនងមួយ។ ការកាត់ស្បែកមានន័យថាជា*ការកាត់ចេញពីអំពើបាប* និង*ជាកម្មសិទ្ធិ*របស់ព្រះយេហូវ៉ា កម្មសិទ្ធិថ្មីត្រូវបានបង្ហាញចេញនៅក្នុងអាកប្បកិរិយាថ្មី គឺ«សេចក្តីសុចរិត និងសេចក្តីទៀងត្រង់» នៅក្នុង ១៨:១៩។ «រក្សាបញ្ញើ នឹងបញ្ញត្តិ ហើយច្បាប់» នៅក្នុង ២៦:៥ ព្រមទាំងមានចិត្តចុះចូល ស្តាប់បង្គាប់ ទុកចិត្ត ជំនឿ (ឧទាហរណ៍ លោកអ័ប្រាហាំបានជឿព្រះជាម្ចាស់...ហើយបានស្តាប់បង្គាប់ភ្លាម នៅក្នុង ១៧ និង ២២ រហូតដល់បញ្ហាស្លាប់រស់នៅក្នុង ២២)។ ដូច្នេះ *ភាពបរិសុទ្ធ* និង*ភាពដែលបានកាត់ចេញ*មិនមែនអរិជ្ជមាន ឬប្រាសចាកសីលធម៌ទេ តែជាទំនាក់ទំនងអាពាហ៍ពិពាហ៍ ដូចដែលបានពន្យល់នៅក្នុងលេវីវិន័យ ២០:២៦ ជាគំនិតអំពីភាពជាកម្មសិទ្ធិ និងទំនាក់ទំនង។អ្នកកាន់តាមក្រឹត្យវិន័យស្រឡាញ់ការកាន់តាមសីលធម៌ អ្នកមានសេចក្តីស្រឡាញ់ស្រឡាញ់*ភាពបរិសុទ្ធ*។ព្រះយេហូវ៉ាគឺជា*ភាពបរិសុទ្ធ*សម្រាប់យើង ហើយយើងត្រូវបរិសុទ្ធសម្រាប់ព្រះអង្គ *ត្រូវបានញែកចេញសម្រាប់ភាពស្និទ្ធស្នាលយ៉ាងគ្រប់លក្ខណ៍*។



**ប្រធានបទ ៩: ភាពបរិសុទ្ធត្រូវបានស្តារឡើងវិញ**

**សេចក្តីសង្គ្រោះចេញពីអំពើបាប និងអារម្មណ៍ខុសឆ្គង**

# ប្រធានបទ: **ភាពបរិសុទ្ធ**

# សម័យ: **និក្ខមនំ និងការវាយដណ្តើមបាន**

**<u>ប៧ ការពណ៌នារូបភាព:</u>** ផ្នែកខាងឆ្វេងនៃរូបភាពមានផ្នែកខាងក្រោយពណ៌ស ផ្នែកខាងស្តាំមានពណ៌ខ្មៅ។ រូបភាពមានបីជួរដេក: ជួរដេកផ្នែកខាងលើមានរូបអាវយឺតជះស្រមោលពណ៌បៃតងទៅខាងឆ្វេងដៃ បន្ទាប់មកទៀតអាវយឺត ដែលមានក្រឡាចត្រង្គ ពណ៌បៃតង និងពណ៌លឿងនៅចំកណ្តាល ដែលមានសញ្ញា X ពណ៌ក្រហម មានន័យថា «មិនអនុញ្ញាត» និងអាវយឺតពណ៌លឿងនៅផ្នែកខាងស្តាំ។ ជួរដេកកណ្តាលមានរូបគោបានៅខាងឆ្វេងដៃ ចៀមកំពុងដុតនៅចំកណ្តាល និងជ្រូកនៅខាងស្តាំដៃ។ ផ្នែកខាងឆ្វេងដៃនៃរូបភាពមានផ្ទៃខាងក្រោយពណ៌ខ្មៅ ផ្នែកខាងស្តាំដៃមានផ្ទៃពណ៌ខ្មៅ។ ជួរដេកដែលនៅក្រោមគេបង្អស់ មានរូបហិបសេចក្តីតាំងសញ្ញានៅខាងឆ្វេងដៃ មនុស្សបួននាក់ជារូបភាពស្រមោលពណ៌សនៅខាងស្តាំដៃ និងសម្តេចសង្ឃម្នាក់ ដែលពាក់អេផូឌ និងឈ្នួតក្បាលនៅចំកណ្តាល ដៃម្ខាងប្រោះឈាមទៅលើហិប និងម្ខាងទៀតទៅលើមនុស្ស

**<u>បទគម្ពីរ:</u>** លេវីវិន័យ ១៩:១៩ សម្រាប់រូបភាពខាងលើ ជំពូក ១១ សម្រាប់រូបភាពនៅកណ្តាល អេសេគាល ៤៤:២៣ បក ស្រាយ រូបភាព ទាំង អស់ និក្ខមនំ ២៤:៣-៨ និង លេវីវិន័យ ១៦ (ជា ពិសេស ខ ១៥-១៧)។ លេវីវិន័យ ៤, ៥:៦-៧,៨:៣០, ៩ គឺជាអត្ថបទដែលត្រូវជាមួយជួរដេកផ្នែកខាងក្រោម។ និក្ខមនំ១៩:១-២, ៥-៦, លេវីវិន្ទ័ ២០»២៦ជាពិសេសអេសេគាល ៤៤:២៣ បកស្រាយទាំងអស់ (អាចបំបែកការសិក្សា /ក្រុមតាមជួរដេក ឬជួរដេកពីរខាងលើ និងជួរដេកខាងក្រោម ប៉ុន្តែទាំងអស់ត្រូវការអេសេគាល ៤៤:២៣)។

**<u>គំនិតប្រធានបទ:</u>** <u>ជួរដេកខាងលើ</u> ពូជសត្វដែលមានសម្បុរឈើឆ្កាង ការដាំឈើឆ្កាង និងការត្បាញឈើឆ្កាង ត្រូវបានហាមឃាត់នៅក្នុងអ៊ីស្រាអែល។ សកម្មភាពទាំងនេះមិនមែនអាក្រក់ទេ ប៉ុន្តែគឺជារឿងប្រៀបធៀប ជាមេរៀនដោយប្រើរបស់ប្រចាំថ្ងៃនៅក្នុងជីវិត ដើម្បីរំឭកប្រជារាស្ត្ររបស់ព្រះជាម្ចាស់កុំឱ្យយក*ភាពបរិសុទ្ធ*ទៅលាយឡំជាមួយភាពមិនស្អាតនៅក្នុងសាសនា ឬនៅក្នុងចិត្តរបស់ពួកគេ។ <u>ជួរដេកកណ្តាល</u> សត្វជាច្រើនត្រូវបានចាត់ទុកថា«មិនស្អាត» ស្ទើរតែទាំងអស់ដោយព្រោះតែហេតុផលអនាម័យ(ជាពិសេសសត្វដែលមានផ្ទុកមេរោគផារ៉ាស៊ិត) ហើយទាំងអស់មានទំនាក់ទំនងជាមួយសេចក្តីស្លាប់: កាកសំណល់ ភាពមិនស្អាត ភាពកខ្វក់ ការបរិភោគសាច់ដែលរលួយ។ ជម្ងឺ ភាពខុសប្រក្រតីនៅក្នុងរូបកាយ ការមករដូវនិងដុះផ្សិត ក៏ជា*និមិត្តរូប*អំពីភាពពុករលួយនៅក្នុងចិត្តនិងនៅក្នុងទឹកដី ដែលបណ្តាលមក*ពីអំពើបាប*។ <u>ជួរខាងក្រោម</u>: សង្ឃមានតួនាទីជាអ្នកសម្របសម្រួលរវាងមនុស្ស*មានបាប* និងព្រះជាម្ចាស់ដែលពោរពេញដោយ*ភាពបរិសុទ្ធ* ដោយនាំមកនូវឈាមយញ្ញបូជា ដើម្បីទទួលស្គាល់ និងដើម្បីឱ្យធួននឹង*បាប*របស់មនុស្ស។ អេសេគាល៤៤:២៣ បកស្រាយអត្ថន័យប្រព័ន្ធវិន័យទាំងមូល: ព្រះជាម្ចាស់កំពុងបង្រៀនអំពី«*ភាពបរិសុទ្ធ*» គឺជាការញែកចេញសម្រាប់ជំនឿដែលមានទំនាក់ទំនងជាមួយជនជាតិអ៊ីស្រាអែលដែលបានកើតជាថ្មី ដែលជាកូនក្រមុំរបស់ព្រះអង្គ។



**ប្រធាន បទ ៩ : ភាពបរិសុទ្ធត្រូវ បាន ស្តារ ឡើង វិញ សេចក្តីសង្គ្រោះចេញពីអំពើបាប និងអារម្មណ៍ខុសឆ្គង**

ប្រធានបទ: **ភាពបរិសុទ្ធ**

សម័យ: **ស្តេច**

**ប៩ ការពណ៌នារូបភាព:** ស្តេចដាវីឌឈរនៅពីក្រោយរទេះ ដែលដឹកហិប ដោយមានកាយវិការថប់បារម្ភនៅពេលដែលស្តេចមើលសាកសពរបស់អ៊ុសានៅលើដី។

**បទគម្ពីរ:** ២ សាំយូអែល ៦, ១ របាក្សត្រ ១៣, ១៥-១៦, យ៉ូស្វេ ៧ កិច្ចការ ៥។

**គំនិតប្រធានបទ:** ក្រោយពីព្រះជាម្ចាស់ប្រទានជ័យជម្នះយ៉ាងអស្ចារ្យឱ្យស្តេចដាវីឌ និងអ៊ីស្រាអែលរួចមក ពួកគេតាំងចិត្តនាំហិប*បរិសុទ្ធ*នៃព្រះរបស់ពួកគេចូលមកក្នុងក្រុងយេរូសាឡិមវិញ ដោយពឹងផ្អែកលើជាតិនិយមដែលមានជ័យជម្នះ និងប្រាជ្ញារបស់មនុស្ស។ ជ័យជម្នះរបស់ព្រះអង្គសម្រាប់អ៊ីស្រាអែល ភ្លាមនោះត្រូវបានគេយល់ថាជាឱកាសសម្រាប់មនុស្សមានអំនួត។ ប៉ុន្តែ ព្រះជាម្ចាស់តែងតែបង្ហាញថា ព្រះអង្គយកព្រះហឫទ័យទុកដាក់នឹង*ភាពបរិសុទ្ធ*នៅក្នុងទំនាក់ទំនងខ្លាំងជាងព្រះអង្គចាប់អារម្មណ៍នឹងអំណាច ឬជ័យជម្នះរបស់មនុស្ស។ នៅក្នុងឱកាសដ៏អស្ចារ្យនៅក្នុងប្រវត្តិសាស្ត្រអំពីសេចក្តីសង្គ្រោះនេះ ដែលជានិមិត្តរូបអំពីការមកដល់របស់ព្រះ-ស្តេច ដែលមានជ័យជម្នះ (មិនមែនស្តេចដាវីឌទេ!) ព្រះជាម្ចាស់បង្ហាញម្តងទៀតថា របៀបវីរៈរបស់ព្រះអង្គគឺជា*ភាពបរិសុទ្ធ* មិនមែនការផ្គាប់ចិត្តមនុស្សទេ។ អ៊ូសា ដើរតួរជានិមិត្តរូបអំពីជនជាតិអ៊ីស្រាអែល ដែលមិនយកចិត្តទុកដាក់នឹងព្រះជាម្ចាស់ ប៉ុន្តែបានបង់ថ្លៃយ៉ាងច្រើន ដូចជាអេកាន នៅចំពោះព្រះអង្គ (យ៉ូស្វេ ៧) និងអន្នានាស និងសាភីរ៉ា ក្រោយមកទៀត (កិច្ចការ ៥)។ បីខែក្រោយមកទៀត ជនជាតិអ៊ីស្រាអែលបញ្ចប់ពិធីចប់សព្វគ្រប់ ដោយផ្អែកលើលក្ខខណ្ឌ*បរិសុទ្ធ*របស់ព្រះជាម្ចាស់ មិនមែនប្រាជ្ញាជាមនុស្សរបស់ពួកគេទេ ដែលនាំឱ្យមានអំណររីករាយយ៉ាងខ្លាំង។




**<u>ប្រធានបទ ៥: ភាពបរិសុទ្ធត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីអំពើបាប និងអារម្មណ៍ខុសឆ្គង</u>**

ប្រធានបទ: **ភាពបរិសុទ្ធ**

សម័យ: **ទ្រាជ្វា**

**<u>ប១១ ការពណ៌នារូបភាព:</u>** ព្រះវិហាររបស់ព្រះយេហូវ៉ានៅលើភ្នំស៊ីយ៉ូន មែកហ៊ីស៊ុប ដែលប្រោះទឹកទៅម្ខាង និងប្រោះឈាមទៅម្ខាងទៀត និងមានតួអក្សរហេព្រើរទាំងអស់ព័ទ្ធជុំវិញ (ដែលរត់ពីស្តាំទៅឆ្វេង)។

**<u>បទគម្ពីរ:</u>** ទំនុកដំកើង ១៥, ៥១, ១១៩។

**<u>គំនិតប្រធានបទ:</u>** <u>រូបភាពខាងឆ្វេង</u>: ទំនុកដំកើង ១៥ សួរសំណួរថា «តើអ្នកណាអាចឡើងទៅឯភ្នំបរិសុទ្ធរបស់ព្រះយេហូវ៉ា ទៅក្នុងព្រះវត្តមានរបស់ព្រះអង្គបាន» ចំលើយគឺជាអ្នកដែលយល់អំពីភាពបរិសុទ្ធរបស់ព្រះយេហូវ៉ា ហើយរស់នៅតាមសេចក្តីល្អរបស់ព្រះយេហូវ៉ា នោះអាចមាន*ភាពបរិសុទ្ធ*កើតឡើងហើយ។<u>រូបភាពខាងស្តាំ:</u> ទំនុកដំកើង ៥១ប្រាប់អំពីរបៀបដែលនៅក្នុងនោះ ព្រះយេហូវ៉ាផ្ទាល់ផ្តល់*ភាពបរិសុទ្ធ*ដែលអស់អ្នកដែលមកឯព្រះអង្គ ទាំង*ប្រឡាក់* និងខ្មៅខ្មាំដោយសារ*អំពើបាប*។ ព្រះអង្គផ្តល់យញ្ញបូជាឈាម ដែល*លាងសំអាតមនុស្សមានកំហុស* ដែលមកស្វែងរកព្រះហឫទ័យមេត្តាករុណាពីព្រះអង្គ (តើលោកអ្នកគិតថា ជំពូក ១៥ ត្រូវជាមួយនឹងជំពូក ៥១ យ៉ាងដូចម្តេច?)។<u>តួអក្សរ:</u> នៅក្នុងទំនុកដំកើង១១៩ កំណាព្យនីមួយៗចាប់ផ្តើមជាមួយអក្សរបន្ទាប់នៅក្នុងតួអក្សរហេព្រើរ។ ការនោះឆ្លុះបញ្ចាំងអំពីសេចក្តីស្រឡាញ់ ទាំងស្រុង ដោយអស់ពីចិត្តរបស់អ្នកបម្រើរបស់ព្រះយេហូវ៉ា ដែលពណ៌នាអំពីសេចក្តីស្រឡាញ់របស់ពួកគេចំពោះព្រះអង្គ។ ព្រះយេស៊ូវ ជាអ្នកដែលបានឆ្លងផុតពីសេចក្តីល្បួងរបស់អារក្សសាតាំង ដោយពឹងផ្អែកលើភាពស្មោះត្រង់នៃព្រះបន្ទូលរបស់ព្រះយេហូវ៉ា ព្រះអង្គនឹងប្រើទំនុកដំកើងនេះដើម្បីបង្ហាញចេញ*ភាពបរិសុទ្ធ*= កម្មសិទ្ធិ = ការរីករាយ = ជំនឿ = ការទុកចិត្តរបស់ព្រះអង្គចំពោះព្រះយេហូវ៉ាតែមួយប៉ុណ្ណោះ (ព្យាយាមអានតាមរយៈទស្សនៈរបស់ព្រះយេស៊ូវ!)។




**<u>ប្រធានបទ ៩: ភាពបរិសុទ្ធត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីអំពើបាប និងអាកប្បកិរិយាខុសឆ្គង</u>**

ប្រធានបទ: **ភាពបរិសុទ្ធ**

សម័យ: **ពួកហោរា**

**<u>ប១៣ ការពណ៌នារូបភាព:</u>** នេះជាប្លង់ព្រះវិហាររបស់អេសេគាល ដោយមើលពីខាងលើ: អក្សរបញ្ឈរសរសេរពីលើចុះក្រោម នៅផ្នែកខាងស្តាំ ជាភាសាហេព្រើរ មានន័យថា «ព្រះយេហូវ៉ា» នៅផ្នែកខាងឆ្វេងសរសេរចុះក្រោមជា-ភាសាហេព្រើរ មានន័យថា «សាម៉ា»។ (ហេព្រើរអានពីស្តាំទៅឆ្វេង)។

**<u>បទគម្ពីរ:</u>** អេសាយ ១:៤, ១៥-១៨, យ៉ូអែល ៣:១៧-២១ អេសេគាល ៧:២៣, ២៦-២៨, ៣៦:១៦-២៩, ជំពូកទាំងអស់ ៤០-៤៨ (ជាពិសេស ៤៣:១-១២, ៤៧ និង ៤៨:៣៥), សាការី ១៤:២០។

**<u>គំនិតប្រធានបទ:</u>** នៅក្នុងបរិបទ «ប្រទេសដ៏មាន *បាប*...ផ្ទុកដោយ *អំពើទុច្ចរិត*...ពូជមនុស្សដែលប្រព្រឹត្ត *អាក្រក់*...ប្រគល់ទៅក្នុងសេចក្តីពុករលួយ» ពួកហោរាចាប់ផ្តើមប្រកាសអំពីថ្ងៃមួយដែលនឹងមកដល់ ជាពេលដែល *ភាពបរិសុទ្ធ*របស់អ៊ីស្រាអែលនឹងមកពីព្រះវត្តមានដ៏ *បរិសុទ្ធ*របស់ព្រះជាម្ចាស់នៅក្នុងចំណោមពួកគេ។ ការនេះនឹងមិនត្រឹមកើតឡើងនៅក្នុងព្រះវិហារថ្មី នៅលើភ្នំស៊ីយ៉ូន ក្នុងក្រុងយេរូសាឡិមប៉ុណ្ណោះទេ។ល។...ថែមទាំងនឹងកើតឡើងនៅក្នុងការបង្កើតចិត្តថ្មីដល់ប្រជារាស្ត្ររបស់ព្រះអង្គ។ បទគម្ពីរទាំងនេះនិយាយអំពីព្រះវត្តមានរបស់ព្រះជាម្ចាស់នៅលើភ្នំ ឬនៅក្នុងចិត្ត បទគម្ពីរទាំងនេះក៏និយាយអំពី *ភាពបរិសុទ្ធ*របស់ព្រះអង្គ និងឥទ្ធិពលរបស់ភាពបរិសុទ្ធនោះ។ សេចក្តីនេះបង្ហាញជានិមិត្តរូបនៅក្នុងល្បះចុងក្រោយក្នុងកណ្ឌគម្ពីរអេសេគាល និងសាការី ដែលនិយាយអំពីការដែលសូម្បីតែចង្រ្កង់សេះ និងភាជនៈទាំងអស់នៅក្រុងយេរូសាឡិមនឹងបាន *បរិសុទ្ធ* ដោយព្រោះព្រះយេហូវ៉ាសាម៉ាគង់នៅយេរូសាឡិម គឺព្រះយេហូវ៉ាគង់នៅទីនោះ។តើ *ភាពបរិសុទ្ធ*របស់ព្រះជាម្ចាស់មានលក្ខណៈ និងឥទ្ធិពលយ៉ាងដូចម្តេច? អេសេគាល ៤៣ និង ៤៧ ជាគូកំណាព្យ។នៅក្នុង ៤៣ ព្រះវត្តមានរបស់ព្រះយេហូវ៉ាមកពីទិសខាងកើត។ នៅពេលដែលព្រះជាម្ចាស់ដ៏ *បរិសុទ្ធ* គង់នៅពាសពេញព្រះវិហារដ៏ *បរិសុទ្ធ*របស់ព្រះអង្គ នោះប្រភពដ៏អស្ចារ្យនាំយកដើមជីវិតនៅក្នុងលោកុប្បត្តិ ជំពូក ១ និងការបង្កើតថ្មីទៅដល់ទីរហោស្ថាន និងសមុទ្រស្លាប់ដែលសម្បូរដោយអំបិល។ *តើនេះជាគោលគំនិតរបស់លោកអ្នកអំពីភាពបរិសុទ្ធដែរឬទេ?*



**ប្រធានបទ ៩: ភាពបរិសុទ្ធត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីអំពើបាប និងអារម្មណ៍ខុសឆ្គង**

ប្រធានបទ: **ភាពបរិសុទ្ធ**

សម័យ: **ប្រជាជនដែលនៅសល់**

**បព៩ ការពណ៌នារូបភាព:** កំពែងក្រុងមានទ្វារបីដែលកោងខាងលើ។ មានស្ត្រីៗដើរចេញពីទ្វារខាងក្រោយឆ្ពោះទៅទិសខាងស្តាំ ដែលស្ត្រីម្នាក់ៗមានកូនក្មេងពីរនាក់ដើរតាមពីក្រោយ។ នៅក្នុងទីតាំងតែមួយពីឆ្វេងទៅស្តាំ មានសង្ឃបួននាក់ដែលពាក់អាវវែងឆ្នូតខ្មៅសម្រាប់គ្រូ។ មានអូដ្ឋមួយផ្ទុកទំនិញចេញតាមច្រកកណ្តាលឆ្ពោះទៅខាងស្តាំ គឺមកតាមក្រោយរទេះដែលមានផ្ទុកទំនិញ។ នៅជ្រុងម្ខាងទៀត ទល់មុខគ្នាមានរូបក្រាំងព្រះគម្ពីរបើក។ មានមនុស្សពីរនាក់ចេញមកតាមទ្វារផ្នែកខាងក្រោយឆ្ពោះទៅខាងស្តាំម្នាក់អូសគ្រែ និងម្នាក់ទៀតអូសតុ។ នៅផ្នែកខាងឆ្វេងទល់មុខគ្នា គឺជាកញ្ជើមួយដែលមានផលកសិកម្មជាតង្វាយមួយភាគដប់។ នៅពីលើរូបទាំងនេះ គឺជាដៃពីរដ៏ធំដែលកំពុងចង្អុលប្រាប់ដំណឹង: ដៃមួយចង្អុលទៅខាងឆ្វេង ហើយមានសញ្ញាព្រួយសរសេរថា «ចូល» ដៃមួយទៀតចង្អុលទៅខាងស្តាំ ហើយមានសញ្ញាព្រួញសរសេរថា «ចេញ»។ នៅជ្រុងខាងឆ្វេង ផ្នែកខាងលើនៃរូបភាពទាំងមូល មានសក់មួយដុំ នៅជ្រុងខាងស្តាំ ផ្នែកខាងក្រោម មានដុំសក់រញ៉េរញ៉ៃជាច្រើន។

**បទគម្ពីរ:** អែសរ៉ា ៩:៣, នេហេមា ៨-១០, ១៣។

**គំនិតប្រធានបទ:** កំពែងបង្ហាញការញែក*ភាពបរិសុទ្ធ*ចេញពី*ភាពមិនបរិសុទ្ធ* ដែលលោកអែសរ៉ា និងលោកនេហេមាបានសម្រេច។ ប្រពន្ធដែលជាជនបរទេស និងកូន ត្រូវបានដេញចេញ ហើយពួកសង្ឃត្រូវបាននាំត្រលប់ពីនិរទេសត្រលប់មកបំពេញការងារវិញ។ ព្រះបន្ទូលត្រូវបានស្អាងឡើងវិញ (នេហេមា៨)និងអ្នករកស៊ីនៅថ្ងៃសប្ប័ទត្រូវបានបណ្តេញចេញ (នេហេមា ១០:៣១, ១៣:១៥-២២)។ តង្វាយមួយភាគដប់ត្រូវបានប្រមូលឡើងវិញ (នេហេមា ១០:៣២, ១៣:១០-១៣) ហើយ កូនចៅរបស់ធូប៊ីយ៉ា និងយេហូយ៉ាដា ត្រូវបានបណ្តេញចេញ។ លោកអែសរ៉ាបានបង្ហាញចេញនូវភាពខ្វល់ខ្វាយចំពោះ*ភាពបរិសុទ្ធ*នៅពេលដែលលោកបានបូតមុខមាត់ដោយមានទុក្ខក្រៀមក្រំ បន្ទាប់មកទៀត លោកនេហេមាក៏បានបង្ហាញចេញនូវភាពខ្វល់ខ្វាយចំពោះ*ភាពបរិសុទ្ធ*ផងដែរ នៅពេលដែលលោកបានទាញផ្តាច់ពុកមាត់របស់អ្នកបំពានក្រិត្យវិន័យទាំងកំហឹង! នៅខណៈពេលដែលរឿងមួយចំនួនហាក់បីដូចជាកាន់តាមក្រិត្យវិន័យនិងសាហាវចំពោះយើង នៅក្នុងបរិបទ រឿងទាំងនេះគឺជារឿងអំពីព្រះគុណដ៏អស្ចារ្យ។ លោកអែសរ៉ា និងលោកនេហេមាបានទទួលស្គាល់(នេហេមា ៩) ថា គុណធម៌នៃ«ការអត់ឱន»តាមពិតទៅគឺជាការប្រព្រឹត្តិឡើងវិញនូវអំពើ *មិនបរិសុទ្ធ*ប្រាសចាកសីលធម៌ដែលនៅពេលថ្មីៗនេះ បាននាំទៅរកការស្ទើតែផុតពូជអីស្រាអែលនៅក្នុងពេលនិរទេស។



**<u>ប្រធាន បទ ៩ : ភាពបរិសុទ្ធត្រូវ បាន ស្តារ ឡើង វិញ សេចក្តីសង្គ្រោះចេញពីអំពើបាប និងអារម្មណ៍ខុសឆ្គង</u>**

ប្រធានបទ: **ភាពបរិសុទ្ធ**

សម័យ: **ព្រះយេស៊ូវ**

**<u>ប១៧ ការពណ៌នារូបភាព:</u>** បីប្រឡោះខាងលើមានរូបភាព (ក) នំប៉័ងមួយដុំនៅពីលើគំនរថ្ម (ខ) មនុស្សធ្លាក់ពីលើជញ្ជាំងព្រះវិហារ ដោយមានទេវតារង់ចាំចាប់គាត់នៅខាងក្រោម និង (គ) មនុស្សប្រុសម្នាក់ដែលកំពុងឈរហើយបម្រុងនឹងបំពាក់មកុដឱ្យមនុស្សម្នាក់ដែលកំពុងលត់ជង្គង់ចុះ ។ រូបនីមួយៗក្នុងចំណោមរូបទាំងបីមានសញ្ញា X ពីលើរូបនោះជាសញ្ញាប្រាប់ថា រូបភាពនោះត្រូវបានហាម។ ក្រុមមួយទៀតនឹងបកស្រាយរូបភាពបីខាងក្រោម។ ផ្នែកខាងក្រោមមាន (ក) ជ្រូកបីក្បាល (មានជ្រូកដទៃដែលនៅហួសផ្ទាំងរូបភាព) មានជើងបោះចេញពីជ្រុងខាងក្រោម ផ្នែកខាងឆ្វេង (ខ) ស្ត្រីម្នាក់ (មានតែខ្លួន និងក្បាលប៉ុណ្ណោះ) ពាល់ជាយព្រះពស្ត្ររបស់ព្រះយេស៊ូវកំពុងតែយាងទៅ និង (គ) ព្រះយេស៊ូវឱនមកលើក្មេងស្រីម្នាក់ដែលកំពុងដេកនៅលើគ្រែ។ នៅចំកណ្តាលរូបភាពទាំងអស់ មានហិបនៅក្នុងព្រះវិហារ(សម្រាប់«ភាពបរិសុទ្ធ») ដែលព័ទ្ធជុំវិញដោយសារសញ្ញាព្រួញដែលចង្អុលទៅរករូបភាពទាំង ៦។

**<u>បទគម្ពីរ:</u>** ម៉ាថាយ ៤, ម៉ាកុស ១:២៤, ៥, លូកា ៤:១-១៣, ហេព្រើរ ២:១០-១៨ និង ៤:១៥-៥:៩។ បទគម្ពីរហេព្រើរនិយាយអំពីសេចក្តីល្បួងរបស់ព្រះយេស៊ូវនៅក្នុងទីរហោស្ថាន (លូកា ៤:១៣) និងសួនច្បារគេតសេម៉ានី (អាចបំបែកត្រឹមខគម្ពីរយោងម៉ាកុសទៅជាការសិក្សា/ក្រុមទីពីរ)។

**<u>គំនិតប្រធានបទ:</u>** នៅក្នុងទីរហោឋាន និងនៅក្នុងសួនច្បារគេតសេម៉ានី យើងមើលឃើញព្រះយេស៊ូវជាអ្នក *បរិសុទ្ធ* ដែលតយុទ្ធនឹងសេចក្តីល្បួងទាំងបីផ្នែក (រូបកាយ ព្រលឹង និងវិញ្ញាណ) ដែលបានធ្វើឱ្យអ័ដាម និងនាងអេវ៉ាបានធ្លាក់ចុះ។ ព្រះអង្គបានពឹងផ្អែកទាំងស្រុងលើព្រះបន្ទូលដ៏ *បរិសុទ្ធ*របស់ព្រះជាម្ចាស់ ដើម្បីការពារព្រលឹងរបស់ព្រះអង្គ។ ព្រះអង្គបង្ហាញថាខ្លួនឯង«*បរិសុទ្ធ*» (នោះគឺទុកចិត្តព្រះជាម្ចាស់ដោយជំនឿ) និងជាសង្ឃដែល*គ្មានបាប* ដើម្បីប្រោសលោះមនុស្សមានបាប ជាហោរាពិតប្រាកដដែលបដិសេធន៍ការកុហករបស់អារក្សសាតាំង និងជាស្តេចលើអស់ទាំងស្តេច ដែលមិននៅក្រោមការគ្រប់គ្រងក្លែងក្លាយរបស់អារក្សសាតាំងទេ។ ភ្លាមៗក្រោយពីសេចក្តីល្បួងនេះ អារក្សនិយាយទៅកាន់ព្រះយេស៊ូវថា «ខ្ញុំស្គាល់ជាក់ហើយថាទ្រង់ជាព្រះអង្គបរិសុទ្ធនៃព្រះ»។ បន្ទាប់មក យើងមើលឃើញជ្រូក ២០០០ ក្បាលរត់ចូលទៅក្នុងសមុទ្រ ជាសញ្ញាសំគាល់អំពីអំណាចនៃ*ភាពបរិសុទ្ធ*របស់ព្រះយេស៊ូវលើហ្វូងនិមិត្តរូបអំពីភាពមិនស្អាត ហើយមានវិញ្ញាណអាក្រក់ ៦០០០ នៅក្នុងសត្វទាំងនោះ។ មិនយូរប៉ុន្មានក្រោយពីរឿងនេះ មានស្ត្រីធ្លាក់ឈាមម្នាក់បំពានក្រិត្យវិន័យនៅក្នុងគម្ពីរលេវីវិន័យ (លេវីវិន័យ ១៥:១៩-៣៣) ហើយធ្វើឱ្យព្រះយេស៊ូវទៅជា*មិនស្អាត* ដោយសារពាល់ព្រះអង្គ ដែលជាលោកគ្រូ! ប៉ុន្តែ *ភាពបរិសុទ្ធ*របស់ព្រះអង្គមានអំណាចខ្លាំងជាងទីសំគាល់អំពីភាពបរិសុទ្ធនៅក្នុងសញ្ញាចាស់: ជំនួសឱ្យការដែលបានធ្វើឱ្យកខ្វក់ដោយសារការពាល់ជាមួយស្ត្រី«ដែលមិនស្អាត» *ភាពបរិសុទ្ធ*របស់ព្រះអង្គផ្លាស់ប្តូរភាពមិនស្អាតរបស់នាង និងធ្វើឱ្យនាងជាឡើងវិញ! មួយរយៈពេលក្រោយមកទៀត ការគ្រប់គ្រងបំផ្លាស់បំប្រែភាពកខ្វក់ ដែលខុសម្តងទៀតជាមួយបញ្ញត្តិនៅក្នុងសញ្ញាចាស់ (លេវីវិន័យ ២១) នៅពេលដែលព្រះអង្គពាល់សាកសព។ការពាល់សាកសពមិនបានបំផ្លាញ *ភាពបរិសុទ្ធ* របស់ព្រះអង្គទេ *ភាពបរិសុទ្ធ*ថ្មីនេះបំផ្លាញការគ្រប់គ្រងរបស់សេចក្តីស្លាប់ផ្ទាល់!



**ប្រធានបទ ៩: ភាពបរិសុទ្ធត្រូវបានស្តារឡើងវិញ**
**សេចក្តីសង្គ្រោះចេញពីអំពើបាប និងអារម្មណ៍ខុសឆ្គង**

## ប្រធានបទ: **ភាពបរិសុទ្ធ**

## សម័យ: **ក្រុមជំនុំ**

**ប២០ ការពណ៌នារូបភាព:** ផ្ទៃខាងក្រោយមានរូបភាពស្លឹកឈើ ដំណាំ និងផ្កា។ មានបេះដូងដ៏ធំមួយ (ដែលមានប្រអប់ដៃដុះចេញតាមចំហៀង) មានបល្ល័ង្កព្រះវិហាររបស់លោកអេសេគាលដែលនៅពីលើរូបនេះ មានរូបហិប តួអក្សរហេព្រើរ កំពែងក្រុង និងកូនកាំបិត។ ជ្រុងខាងក្រោមនៃបេះដូងមានឆ្នូតខ្មៅ លើពណ៌ស ជាសញ្ញាសំគាល់អំពីអាវវែងរបស់សង្ឃ/គ្រូ។ ដំណក់ឈាមពណ៌ក្រហម មាននៅលើប្រអប់ដៃនិងមាននៅផ្នែកខាងលើនៃបេះដូង និងខ្លះៗពាសពេញបល្ល័ង្កបន្តិចដែរ។ រូបភាពទាំងអស់នេះបានមកពីរូបភាពមុនៗអំពី«ភាពបរិសុទ្ធ»។

**បទគម្ពីរ:** យេរេមា ២៤:៧, ៣១:៣១-៣៤, ៣៣:២២, អេសេគាល ៣៦:២៥-២៩, ១ កូរិនថូស ៦:១៩, ២ កូរិនថូស ៣:៣, កាឡាទី ៥:១៦-២៦, ទីតុស ២:១២, ហេព្រើរ ៩:១៩-២២, ១០:១៩-២២, យ៉ាកុប ១:១៩-២១, ១ ពេត្រុស ១:២, ១៣-១៦, ២:៥, ៩, ១យ៉ូហាន ៣:២-៣ (អាចបំបែកការសិក្សា ក្រុមទីតុស ហេព្រើរ យ៉ាកុប ១ យ៉ូហាន និង១កូរិនថូស ២កូរិនថូស កាឡាទី និង ១ពេត្រុស ប៉ុន្តែទាំងពីរក្រុមត្រូវការយេរេមា និង អេសេគាល)។

**គំនិតប្រធានបទ:** នៅពេលដែលព្រះបន្ទូល ព្រះបុត្រា និងព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ត្រូវបានដាក់ (យ៉ាកុប) នៅក្នុងចិត្តរបស់អ្នកជឿម្នាក់ៗ *ភាពបរិសុទ្ធ*ដែលកាលពីមុនតំណាងតាមរយៈរបស់របរដែលប្រើនៅក្នុងពិធីបរិសុទ្ធរបស់អ៊ីស្រាអែល ចាប់ផ្តើមរស់នៅក្នុងចិត្តរបស់យើង និងចេញពីចិត្តរបស់យើងទៅ។យើងចាប់ផ្តើមមានទុក្ខព្រួយ និងស្អប់ខ្ពើម*អំពើបាប*។ សេចក្តីស្រឡាញ់ប្រកបដោយ*ភាពបរិសុទ្ធ* និងស្តាប់បង្គាប់ចាប់ផ្តើមផុសចេញពីខាងក្នុងមក ហើយយើងរកឃើញថា យើងពិតជាចង់ដូចព្រះយេស៊ូវ ហើយនៅជិតព្រះអង្គ។ យើងរកឃើញថា យើងគឺជាសង្ឃរបស់ព្រះអង្គពីព្រោះយើងចូលមកបម្រើព្រះអង្គដោយផ្ទាល់ ហើយយើងគឺជាព្រះវិហាររបស់ព្រះអង្គ ពីព្រោះព្រះអង្គគង់នៅក្នុងសាច់ឈាមរបស់យើង។ ទោះបីជាយើងប្រហែលជាមានការលំបាកជាមួយ*អំពើបាប*ក៏ដោយ ហើយក៏ប្រហែលជាអធិស្ឋានថា«ព្រះអម្ចាស់អើយ សូមជួយដល់ការមិនជឿរបស់ទូលបង្គំផង!»។ ព្រះគុណរបស់ព្រះអង្គបន្តបង្រៀនយើងឱ្យនិយាយថា«ទេ» ចំពោះអំពើដែលមិនកោតខ្លាចព្រះ និង «បាទ ឬចាស៎» ទៅកាន់ផលផ្លែរបស់ព្រះវិញ្ញាណ។ ពាក្យទំនាយដ៏អស្ចារ្យរបស់លោកយេរេមា និងលោកអេសេគាល អំពីការ ដាក់ចិត្តដែល*បរិសុទ្ធ*ទាំងស្រុង នៅទីបញ្ចប់ បានចាប់ផ្តើមក្លាយទៅជាការពិតនៅក្នុងយើងហើយ! «អស់អ្នកណាដែលមានសេចក្តីសង្ឃឹមយ៉ាងនោះដល់ទ្រង់ នោះក៏តែងជំរះ*សំអាត*ចិត្តខ្លួន ឱ្យដូចទ្រង់ដែល*ស្អាត*ដែរ» ពីព្រោះ «កាលណាទ្រង់លេចមក នោះយើងនឹងបានដូចជាទ្រង់»។



**ប្រធានបទ ៩: ភាពបរិសុទ្ធត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីអំពើបាប និងអារម្មណ៍ខុសឆ្គង**

## ប្រធានបទ: **ភាពបរិសុទ្ធ**

## សម័យ: **ការបង្កើតថ្មី**

**ប២៤ ការពណ៌នារូបភាព:** ពាក់កណ្តាលខាងឆ្វេង និងពាក់កណ្តាលខាងស្តាំឆ្លុះគ្នាទៅវិញទៅមក ម្ខាងៗមានប្រអប់ដៃចេញពីខាងលើ ដោយកាន់សម្លៀកបំពាក់មួយ។ ពាក់កណ្តាលខាងឆ្វេងមានផ្ទៃខាងក្រោយពណ៌ខ្មៅ ហើយពាក់កណ្តាលខាងស្តាំមានពន្លឺ។ សម្លៀកបំពាក់នៅផ្នែកខាងឆ្វេងកខ្វក់ រហែក គ្មានរបៀបរៀបរយហើយសម្លៀកបំពាក់នៅខាងស្តាំជាសម្លៀកបំពាក់មង្គលការប្រកបដោយសិរីរុងរឿង។ សម្លៀកបំពាក់នៅផ្នែកខាងឆ្វេង ជ្រលក់ពាក់កណ្តាលចូលទៅក្នុងធុងមួយដែលមានឈាមពណ៌ក្រហម សម្លៀកបំពាក់នៅខាងស្តាំព្យួរ។ ធុងនោះផុតគំនូសកណ្តាលបន្តិច ដើម្បីមានជើងឈើឆ្កាងរបស់ព្រះគ្រីស្ទលេចចេញឡើងតាមគំនូសកណ្តាល បង្ហាញត្រង់តែកន្លែងដែលព្រះបាទារបស់ព្រះអង្គត្រូវបានដំដែកគោល។

**បទគម្ពីរ:** អេភេសូរ ៥:២៥-២៧, វិវរណៈ ១៩:៦-៩, ២១:២, ៨-២៧, ២២:១៤-១៥, ១៩។

**គំនិត ប្រធាន បទ :** លោកប៉ុលពន្យល់ថា សេចក្តីស្រឡាញ់ និងការលះបង់ព្រះជន្មរបស់ព្រះគ្រីស្ទសម្រាប់ក្រុមជំនុំ នឹងលាងក្រុមជំនុំ សំអាតក្រុមជំនុំឱ្យបាន*ស្អាត* និងប្រោសឱ្យក្រុមជំនុំបាន*បរិសុទ្ធ* សម្រាប់ថ្វាយដល់ព្រះអង្គនៅថ្ងៃចុងក្រោយជាកូនក្រមុំដែលប្រកបដោយសិរីរុងរឿង គ្មានស្នាមប្រឡាក់ គ្មានជ្រាញជ្រួញ និងមិនអាចបន្ទោសបាន។ សេចក្តីចុងក្រោយនេះត្រូវបានបង្ហាញនៅក្នុងវិវរណៈ ដែលសរសេរឡើងដោយលោកយ៉ូហាន នៅពេលដែលលោកមើលឃើញពួកបរិសុទ្ធជាកូនក្រមុំ *បរិសុទ្ធ* ដែលបានរៀបចំខ្លួនទទួលកូនកំឡោះ គឺជាព្រះជាម្ចាស់។ បន្ទាប់មក លោកយ៉ូហាន ដាក់លាយរូបភាពប្រៀបធៀបនេះ ដោយដាក់បញ្ចូល«ទីក្រុង*បរិសុទ្ធ*» ដែលជារូបរាងរបស់«ទី-*វិសុទ្ធ*បំផុត»នៅក្នុងរោងឧបោសថ និងព្រះវិហាររបស់ព្រះយេហូវ៉ា។ «គ្មានអ្វី*ស្មោកគ្រោក*នឹងចូលក្នុងទីក្រុងនោះបានឡើយ» ហើយអ្នកដែល«លាងអាវខ្លួន»«ដែលត្រូវបានប្រទានឱ្យស្លៀកពាក់សំពត់ទេសឯកយ៉ាងម៉ដ្ឋ ហើយភ្លឺ» នឹងជា«អ្នកដែលមានពរ»មានសិទ្ធិទៅឯដើមជីវិត និងមាត់ទ្វារចូលទៅកាន់ទីក្រុង។ មានតែពីរជំពូកដំបូងនៅក្នុងកណ្ឌគម្ពីរលោកុប្បត្តិ និងពីរជំពូកចុងក្រោយនៅក្នុងកណ្ឌគម្ពីរវិវរណៈ ពណ៌នាអំពីពិភពលោកដែល*បរិសុទ្ធ* និងគ្មាន*អំពើបាប*ទាល់តែសោះ។ យើងមិនដែលបានស្គាល់ពិភពលោកយ៉ាងដូច្នេះទេ ប៉ុន្តែនៅថ្ងៃនោះ យើងនឹងបាននៅទីនោះ ដោយបានលាងសំអាតឱ្យស្អាត និងមានពន្លឺ ព្រមទាំងត្រៀមខ្លួនរួចជាស្រេច។

## ការឆ្លុះបញ្ចាំងអំពីទន្លេ "ភាពបរិសុទ្ធ និងអំពើបាប+កំហុស":

តើការមួយចំនួនដែលលោកអ្នកចាប់អារម្មណ៍ នៅពេលដែលលោកអ្នកបានធ្វើដំណើរយ៉ាងលឿនឆ្លងកាត់ទន្លេ «ភាពបរិសុទ្ធ» មានអ្វីខ្លះ?

តើមានអ្វីខុសប្លែក តើមានចង្វាក់បែបណា តើមានអ្វីគួរឱ្យចាប់អារម្មណ៍ តើមានអ្វីគួរឱ្យភ្ញាក់ផ្អើល?

តើលោកអ្នកកំពុងមានអារម្មណ៍យ៉ាងដូចម្ដេចអំពីព្រះយេហូវា ដ៏ជាព្រះ?

# ប្រធានបទទី ៦: មិត្តភាព

នៅពេលបង្កើត អ័ដាម និងនាងអេវ៉ាមាន **មិត្តភាព** ជាមួយ **ព្រះយេហូវ៉ា** ផ្ទាល់ ។ ព្រះអង្គមានបន្ទូលជាមួយពួកគេ (លោកុ ២:១៥-១៨) ចែកការងាររបស់ព្រះអង្គដល់ពួកគេ (លោកុ ២:៨, ១៥) និងបានដើរជាមួយពួកគេនៅក្នុងសួនសប្បាយរបស់ព្រះអង្គនៅពេលរសៀល (៣:៨)។

ប៉ុន្តែការប្រកាសសង្គ្រាមរបស់ពួកគេទាស់នឹងព្រះយេហូវ៉ាបានក្បត់ និងបានបោះបង់ចោលទំនាក់ទំនង **មិត្តភាព** របស់ពួកគេ។ ចិត្តក្បត់របស់ពួកគេ និងដាវភ្លើងដ៏ភ្លឺចិញ្ចាចរបស់ចេរូប៊ីម បានធ្វើឱ្យពួកគេឃ្លាតឆ្ងាយពីព្រះជាម្ចាស់។ ពួកគេមិនអាចធ្វើអ្វី ដើម្បីស្តារ **មិត្តភាព** របស់ពួកគេដែលបានបាត់បង់ទៅនោះបានទេ!

តើ **ព្រះយេហូវ៉ា** អាចអត់ទោសឱ្យ **ការក្បត់** និងផ្សះផ្សា **មិត្តភាព** របស់ពួកគេឡើងវិញបានដែរឬទេ ហើយតើព្រះអង្គនឹងធ្វើបែបនោះដែរឬទេ?



**<u>ប្រធានបទទី ៦: មិត្តភាព—ការប្រកបត្រូវបានស្តារឡើង-វិញ សេចក្តីសង្គ្រោះចេញពីការបែកបាក់</u>**

ប្រធានបទ: **មិត្តភាព**

សម័យ: **បុព្វបុរស**

**<u>ម៥ ការពណ៌នារូបភាព</u>**: រូបភាពខាងឆ្វេង គឺលោកអ័ប្រាហាំ និង នាងសារ៉ា នៅជាមួយគ្នាដើម្បីទទួលភ្ញៀវបីនាក់។ រូបភាពខាងស្តាំ គឺលោកអ័ប្រាហាំនិយាយចរចារជាមួយព្រះយេហូវ៉ា នៅពេលដែលពួកគេកំពុងតែសំឡឹងមើលទៅទីក្រុងសូដុម។

**<u>បទគម្ពីរ:</u>** លោកុប្បត្តិ ១៨

**<u>គំនិតប្រធានបទ:</u>** នៅក្នុងផ្នែកដំបូងនៃជំពូកនេះ យើងឃើញថា លោកអ័ប្រាហាំជា*ម្ចាស់ផ្ទះ* ទទួលស្វាគមន៍ព្រះយេ-ហូវ៉ាចូលមកក្នុងផ្ទះរបស់លោកផ្ទាល់ខ្លួន។ នៅក្នុងសកម្មភាពនេះ ព្រះជាម្ចាស់បានទទួលការបំរើរបស់លោកអ័ប្រាហាំដោយបង្ហាញឱ្យឃើញថា វត្តមាន និងការបំរើរបស់លោកអ័ប្រាហាំ គឺជាការថ្វាយព្រះពរមួយដែលព្រះអង្គទទួលដោយអំណរ។ ក្រោយមកទៀត ព្រះជាម្ចាស់បាន*សន្ទនាជាលក្ខណៈផ្ទាល់ខ្លួន*ជាមួយលោកអ័ប្រាហាំ និងនាសារ៉ា។ គួរឱ្យភ្ញាក់ផ្អើលបំផុត នៅក្នុងខ ១៧-២១ យើងឃើញថាព្រះយេហ៊ូវ៉ាបានឱ្យលោកអ័ប្រាហាំដឹងពី*ការសម្ងាត់របស់ព្រះអង្គ* ទាក់ទងនឹង*អារម្មណ៍ ការខ្វល់ខ្វាយ និងគោលបំណងរបស់ព្រះអង្គ*។ នៅចុងបញ្ចប់ លើសពីការដែលអាចយល់បាន ព្រះយេហូវ៉ាព្រមទទួលសម្ពាធ និងការប្រកាសរបស់លោកអ័ប្រាហាំ។ ព្រះយេហូវ៉ា ដែលនឹងធ្វើបែបនេះម្តងទៀតជាមួយលោកម៉ូសេ(ឧ. និក្ខមនំ ៣២, ជនគណនា ១៤) បង្ហាញយើងឱ្យឃើញថា ព្រះអង្គកំពុងតែស្តារ*ការប្រកបគ្នានិងមិត្តភាព* ឡើងវិញនិង ចូលរួមក្នុង*ការ ប្រកបគ្នា* និង *មិត្តភាព* នោះតាមលក្ខណៈដ៏ស៊ីជម្រៅ និងផ្ទាល់ខ្លួនជាមួយនឹងកូនរបស់ព្រះអង្គដែលបានធ្លាក់ចុះ។



**<u>ប្រធានបទទី ៦: មិត្តភាព—ការប្រកបត្រូវបានស្តារឡើង-វិញ សេចក្តីសង្គ្រោះចេញពីការបែកបាក់</u>**

## ប្រធានបទ: **មិត្តភាព**

## សម័យ: **និក្ខមនំ និងការវាយដណ្តើមបាន**

**<u>ម៧ ការពណ៌នារូបភាព</u>:** ផ្ទៃខាងក្រោយប្តូរពីងងឹតនៅផ្នែកខាងឆ្វេងទៅជាពណ៌សនៅផ្នែកខាងស្តាំ នៅតាមជ្រុងទាំងបួននៃរូបភាពមានរូបគម្ពោធព្រៃដែលកំពុងឆេះ ហិបនៃសេចក្តីសញ្ញា រោងឧបោសថ និងបណ្តាជននៅក្នុងពិធីជប់លៀង។ លោកម៉ូសេ ឈរនៅចំកណ្តាល ដែលមានផ្ទៃមុខបញ្ចេញពន្លឺ។ ពីលើដៃខាងឆ្វេង និងខាងស្តាំដៃរបស់គាត គឺជាបង្គោលភ្លើង និងបង្គោលពពក។

**<u>បទគម្ពីរ:</u>** និក្ខមនំ ៣:១២-១៧, ៦:១-៨, ៣២-៣៤, ជនគណនា ១៤ ហូសេ ១១។

**<u>គំនិតប្រធានបទ:</u>** ព្រះយេហ៊ូវ៉ាបានមកឯប្រជារាស្ត្ររបស់ព្រះអង្គដើម្បី*ប្រកប* និង *មានមិត្តភាព* ជាមួយប្រជារាស្ត្ររបស់ព្រះអង្គ។ ព្រះអង្គបានបង្ហាញព្រះនាម*ផ្ទាល់ខ្លួន*របស់ព្រះអង្គដល់លោកម៉ូសេ បន្ទាប់មកបានបង្ហាញលក្ខណៈនៃទំនាក់ទំនងក្នុងគ្រួសារ ដោយ«សង្គ្រោះកូនច្បង»របស់ពួកគេ គឺពួកអ៊ីស្រាអែល។ បន្ទាប់មក ព្រះអង្គបានប្រទានឱ្យពួកគេមានព្រះវត្តមាន*ការពារ*របស់ព្រះអង្គនៅពីលើហិបនៃសេចក្តីសញ្ញានៅក្នុងរោងឧបោសថ និងជាបង្គោលពពក (ជាម្លប់នៅពេលថ្ងៃ) និងបង្គោលភ្លើង (ជាពន្លឺនៅពេលយប់)។ ព្រះអង្គបានដឹកនាំពួកគេ «ដោយព្រះហស្តរបស់ព្រះអង្គ» នៅកន្លែងណាដែលពួកគេបានទៅ ។ ព្រះអង្គបានបង្កើតពួកសង្ឃ និងប្រព័ន្ធនៃការថ្វាយតង្វាយដើម្បីផ្សះផ្សាមនុស្សឱ្យមាន*ការប្រកប*ជាមួយព្រះជាម្ចាស់ឡើងវិញ និងចាប់ផ្តើមពិធីជប់លៀងដ៏ធំមួយ ដែលជានិមិត្តរូបអំពី និងជាការអបអរសាទរអំពីទំនាក់ទំនងដ៏ស្និទ្ធស្នាលរបស់ព្រះជាម្ចាស់ជាមួយប្រជារាស្ត្ររបស់ព្រះអង្គ។ នៅក្នុងតួរនាទីដ៏ពិសេសរបស់លោកជាអ្នកផ្សះផ្សា លោកម៉ូសេបានសន្ទនាយ៉ាងក្លាហានជាមួយនឹងព្រះយេហូវ៉ា។ ពួកគេមាន*ការប្រកបគ្នា*យ៉ាងស្និទ្ធស្នាល ដែលព្រះយេហូវ៉ាប្រកាសថា លោកម៉ូសេ គឺជាមិត្តដែលស្គាល់គ្នាមុខទល់នឹងមុខ។



**ប្រធានបទទី ៦: មិត្តភាព—ការប្រកបត្រូវបានស្តារឡើង-វិញ សេចក្តីសង្គ្រោះចេញពីការបែកបាក់**

ប្រធានបទ: **មិត្តភាព**

សម័យ: **ស្តេច**

**មឌ ការពណ៌នារូបភាព:** *រូបភាពនៅក្នុងព្រះវិហារពីរ៖ រូបភាពមួយ ស្តេចដាវីឌកំពុងលុតជង្គង់អធិស្ឋានដែលមាន-រូបពិណនៅជិតគាត់។ រូបភាពមួយទៀត គឺសាឡូម៉ូនកាន់ដុំភ្លើង និងផ្សែងហុយចូលពេញព្រះវិហារ។ (សូមកត់សំគាល់:អ្នកទាំងនេះមិនមែនជាពួកលេវី ដូច្នេះតាមពិតពួកគេមិនបាននៅក្នុងព្រះវិហារទេ)។*

**បទគម្ពីរ:** ១ពង្សាតារក្សត្រ ៨-៩ (ជាពិសេស ៨:១០-១១), ២របាក្សត្រ ៧, ទំនុកដំកើង ៣,៧,១៨,៥១,៥២,៥៤, ៥៦,៥៧,៦០,១៤២។

**គំនិតប្រធានបទ:** ទំនុកដំកើងនីមួយៗដែលមានកត់ត្រានៅទីនេះគឺបាននិពន្ធឡើងដើម្បីកត់ត្រាផ្នែកនៃព្រឹត្តិការណ៍សំខាន់ៗដែលបានកើតឡើងនៅក្នុងជីវិតរបស់ស្តេចដាវីឌ។ ទំនុកដំកើងនីមួយៗឆ្លុះបញ្ចាំងពីភាពស្និទ្ធស្នាលរបស់*មិត្តភាព*ដែលពួកគេបានមានជាមួយគ្នា និងបង្ហាញថា ស្តេចដាវីឌទុកចិត្តលើព្រះយេហូវ៉ាទាំងស្រុងថា ព្រះយេហូវ៉ាចាប់អារម្មណ៍និងយកព្រះទ័យទុកដាក់ដោយផ្ទាល់នៅក្នុងគ្រប់ផ្នែកនៃជីវិតទាំងអស់របស់លោក។ នៅក្នុងពង្សាវតារក្សត្រ និង របាក្សត្របង្ហាញពីការមកដល់នៃវត្តមាននៃភ្លើងរបស់ព្រះជាម្ចាស់ចូលមកក្នុងព្រះវិហារសាឡូម៉ូន បញ្ជាក់ពីភាពដ៏ឧត្តុង្គឧត្តមនៃព្រឹត្តិការណ៍នេះ។ ព្រះយេហូវ៉ាមកគង់នៅក្នុង «ពោងឧបោសថ» ជាមួយប្រជារាស្ត្ររបស់ព្រះអង្គអស់រយៈពេលរាប់រយឆ្នាំគង់ជាមួយ និងធ្វើដំណើរជាមួយពួកគេ ទៅ និងក្នុងទឹកដីសន្យា ទោះបីជាពួកគេកំពុងធ្វើចម្បាំងក៏ដោយ។ ឥឡូវនេះ ការដណ្តើមកាន់កាប់ទឹកដីនោះបានសម្រេច និងសន្តិភាពត្រូវបានបង្កើតឡើង យើងឃើញថា វត្តមានរបស់ព្រះអង្គមិនត្រឹមតែមិនប្រែប្រួលប៉ុណ្ណោះទេ ថែមទាំងមិនមែនបណ្តោះអាសន្នថែមទៀតផង ព្រះយេហូវ៉ាបានតាំងលំនៅដ៏ស្ថិតស្ថេរ ដើម្បី*ប្រកបគ្នា*ជារៀងរហូតជាមួយនឹងប្រជារាស្ត្ររបស់ព្រះអង្គ។



**ប្រធានបទទី ៦: មិត្តភាព—ការប្រកបត្រូវបានស្តារឡើង-វិញ សេចក្តីសង្គ្រោះចេញពីការបែកបាក់**

ប្រធានបទ: **មិត្តភាព**

សម័យ: **ប្រាជ្ញា**

**ម១១ ការពណ៌នារូបភាព:** ទារកម្នាក់នៅក្នុងពោះនៅពីលើក្រាំងគម្ពីរ គឺនៅចំណុចកណ្ដាលផ្ទាំងរូបភាព ខាងលើគឺជាស្លាបពីរ នៅខាងក្រោម មានប្រអប់ដៃទ្រក្រាំងគម្ពីរ។ នៅខាងឆ្វេងគឺសត្វចាបនៅក្នុងសំបុកជាមួយនឹងកូនចាប។ នៅផ្នែកខាងស្ដាំគឺរូបពែងពណ៌ដុតមួយ ដែលមានជើងទម្រវែង ហើយរាងរបស់ជើងទម្រទាំងសងខាងជាក្បាលគូស្នេហ៍ពីរនាក់ដែលនឹងថើបគ្នា។

**បទគម្ពីរ:** ទំនុកដំកើង ២៣, ៦៣, ៧៣:២៣-២៨, ៨៤, ១៣៩ និងចំរៀងសាឡូម៉ូន

**គំនិតប្រធានបទ:** សេចក្ដីអធិស្ឋាន បទចម្រៀងលើកដំកើង ការរអ៊ូរទាំ សំណោក និងការសរសើរដំកើង ដែលយើងហៅថា ទំនុកដំកើង ព្រមទាំងកណ្ឌគម្ពីរប្រាជ្ញា បង្ហាញពី *ការប្រកបគ្នា* និង *មិត្តភាព* យ៉ាងស្និទ្ធស្នាលរបស់ព្រះជាម្ចាស់ ជាមួយស្នាព្រះហស្តរបស់ព្រះអង្គទាំងលក្ខណៈផ្ទាល់ខ្លួន និងលក្ខណៈជាក្រុមព្រមទាំងផ្ដល់*ការដឹកនាំ*ដ៏ឆ្លាតវៃរបស់ព្រះជាម្ចាស់សម្រាប់បុគ្គលម្នាក់ៗ និងសម្រាប់សហគមន៍ទាំងមូល។ ទំនុកដំកើងជំពូក១៣៩ បានប្រាប់អំពីការស្គាល់ភាពស្និទ្ធស្នាលដ៏អស្ចារ្យ និងវត្តមានរបស់ព្រះយេហ៊ូវ៉ា ដ៏ព្រះនៅក្នុងជីវិតរបស់យើង គឺចាប់តាំងពីនៅក្នុងផ្ទៃ នៅក្នុងគំនិតរបស់យើង និងពាសពេញផែនដីទាំងមូល។ទំនុកដំកើងជំពូក៦៣ និយាយអំពីបទពិសោធន៍ឈឺចាប់ និងភាពស្អប់ស្អល់ នៅពេលដែលអ្នកសរសេរសៀវភៅទំនុកដំកើងគិតពី*ការប្រកបគ្នា*របស់គាត់ជាមួយនឹងព្រះយេហូវ៉ា។ គាត់បានមើលឃើញខ្លួនគាត់ថាគាត់កំពុងតែច្រៀងនៅក្រោមម្លប់ស្លាបការពាររបស់ព្រះយេហូវ៉ា នៅពេលដែលព្រះហស្តស្ដាំរបស់ព្រះយេហូវ៉ាបានទប់ទល់គាត់។ ទំនុកដំកើងជំពូកទី ៨៤ ប្រាប់អំពីការស្វែងរកភាពស្និទ្ធស្នាលជាមួយព្រះជាម្ចាស់ ដែលត្រូវបានសម្រេចនៅក្នុងព្រះវិហារ។ សត្វចាបដែលធ្វើសំបុកនៅក្នុងព្រះវិហារ គឺជារូបភាពមួយអំពីអំណាររបស់អ្នកសរសេរទំនុកដំកើង ដែលមានកន្លែងមួយនៅជាមួយព្រះជាម្ចាស់ ដែលព្រះជាម្ចាស់ផ្ទាល់បង្កើតឡើងសម្រាប់យើង។ កណ្ឌគម្ពីរចំរៀងសាឡូម៉ូន ៨:៦-៧ គឺស៊ីជម្រៅខ្លាំងណាស់...ដោយឆ្លុះបញ្ចាំងទៅនឹងលោកុប្បត្តិ ១:២៦-២៨ ដែលបកស្រាយចំរៀងទាំងមូល និងសេចក្ដីស្រឡាញ់នៅក្នុងអាពាហ៍ពិពាហ៍ជាការប្រៀបប្រដូច និងជានិមិត្តរូបអំពីព្រះត្រៃឯក របៀបថ្វាយបង្គំ ដែលពិតសម្រាប់ទំនាក់ទំនងរបស់ព្រះយេហូវ៉ាជាមួយនឹងជនជាតិអ៊ីស្រាអែល និងសម្រាប់ទំនាក់ទំនងរបស់ព្រះយេស៊ូវជាមួយក្រុមជំនុំ។



**<u>ប្រធានបទទី ៦: មិត្តភាព—ការប្រកបត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីការបែកបាក់</u>**

ប្រធានបទ: **មិត្តភាព**

សម័យ: **ពួកហោរា**

**<u>ម១៣ ការពណ៌នារូបភាព</u>:** ស្តេចមួយអង្គកំពុងថៃថ្នូរស្ត្រីម្នាក់ ប៉ុន្តែនាងមិនសូវចាប់អារម្មណ៍ស្តេចនោះដូចដែលស្តេចនោះចាប់អារម្មណ៍នឹងនាងទេ។

**<u>បទគម្ពីរ:</u>** អេសាយ ៤៩:១៥-១៨, ៥១, ៥៤, ៦២:៤-៥, (អាចបំបែកការសិក្សា/ក្រុមនៅត្រង់នេះ ទោះបីជាទាំងពីរក្រុមអាចជ្រើសរើសការប្រៀបធៀបអំពីអាពាហ៍ពិពាហ៍ក៏ដោយ) អេសេគាល ១៦, ៤៣:១-៧ ការប្រៀបធៀបអំពីអាពាហ៍ពិពាហ៍នៅក្នុងកណ្ឌគម្ពីរអេសាយ ហូសេ អេសេគាល សេផានា។

**<u>គំនិតប្រធានបទ:</u>** ដោយត្រូវបានកំណត់ទុកជាមុនឱ្យធ្វើជាប្រជារាស្ត្រ ហ្វូងចៀម កូន សាសន៍ស្ថានសួគ៌ ។ល។ របស់ព្រះយេហូវ៉ា ឥឡូវនេះយើងឃើញពួកហោរាចាប់ផ្តើមបង្ហាញអំពីទំនាក់ទំនង *មិត្តភាព* របស់ព្រះយេហូវ៉ាជាមួយនឹងប្រជារាស្ត្ររបស់ព្រះអង្គតាមរយៈការប្រៀបប្រដូចដ៏ស្និទ្ធស្នាលបំផុតមួយដែលអាចមាន។ ព្រះអង្គហៅពួកគេថា កូនក្រមុំរបស់ព្រះអង្គ។ ព្រះយេហូវ៉ាថៃថ្នូរអ៊ីស្រាអែល រៀបការជាមួយនាងនិយាយពាក្យផ្អែមល្ហែមរបស់ប្តីដែលមានចិត្តល្អ ស្គាល់ពីអារម្មណ៍របស់ប្តីដែលត្រូវប្រពន្ធក្បត់ចិត្ត ជូនអំណោយ ហើយព្រះអង្គដើរតួជាប្តីដែលស្រឡាញ់ប្រពន្ធយ៉ាងលើសលប់។ ជនជាតិអ៊ីស្រាអែលបានបែរចិត្តចេញពីព្រះជាម្ចាស់ គិតតែពីប្រយោជន៍ផ្ទាល់ខ្លួន បះបោរ សាហាយស្មន់ និងត្រូវបានធ្លាក់ក្នុងភាពទាបថោកទាំងស្រុង។ ត្រលប់ទៅឯការប្រៀបប្រដូចអំពីព្រះវិហារវិញ គឺពួកហោរាប្រាប់យើងថា នៅថ្ងៃណាមួយព្រះយេហ៊ូវ៉ានឹងយាងពីស្ថានសួគ៌មកគង់នៅលើផែនដី ដើម្បីរស់នៅជា *មិត្ត* និង *ប្រកបគ្នា* អស់កល្បជានិច្ចជាមួយអស់អ្នកដែលមិនមាន«ពេស្យាចារ»ខាងវិញ្ញាណ។



**ប្រធានបទទី ៦: មិត្តភាព—ការប្រកបត្រូវបានស្តារឡើងវិញ សេចក្តីសង្គ្រោះចេញពីការបែកបាក់**

ប្រធានបទ: **មិត្តភាព**

សម័យ: **ប្រជារាស្ត្រដែលនៅសល់**

**ម១៥ ការពណ៌នារូបភាព:** រូបភាពទីក្រុងងងឹត នៅជើងមេឃ ដែលឃើញមានជំបូលត្រសាលនៅពីលើអគារ មានពិធីជប់លៀងនៅតុខាងក្រៅអគារដែលមើលឃើញច្បាស់ ហើយនៅផ្នែកខាងមុខ មានសង្ឃម្នាក់កំពុងតែអានក្រាំងគម្ពីរ។

**បទគម្ពីរ:** នេហេមា ៨ ជាពិសេស ខ១០-១២ និង ១៧-១៨។

**គំនិតប្រធានបទ:** អែសរ៉ាដែលជាសង្ឃ និងពួកលេវីបានចែកចាយសំណេរផ្ទាល់ខ្លួនអំពីព្រះយេហ៊ូវ៉ា ដ៏ជាព្រះរបស់ពួកគេជាមួយមនុស្សទាំងអស់ក្នុងរយៈពេល៨ថ្ងៃ។ ព្រះបន្ទូលរបស់ព្រះយេហ៊ូវ៉ាបានបង្ហាញឱ្យឃើញនូវអំពើបាបដែលពួកគេកំពុងតែរស់នៅក្នុងនោះ ដែលបានកាត់ដល់ដួងចិត្តរបស់ពួកគេ។ ប៉ុន្តែ អែសរ៉ា នេហេមា និងពួកលេវីផ្សេងទៀតនៅតែបានទទួលស្គាល់ថា ការបង្ហាញឱ្យឃើញដ៏ឈឺចាប់នេះ គឺពិតជាភស្តុតាងបង្ហាញពី*វត្តមាន* ការស្រឡាញ់ដ៏ជ្រាលជ្រៅ និង*មិត្តភាព*របស់ព្រះជាម្ចាស់។ ជំនួសឱ្យការវាយផ្ចាលមនុស្សដើម្បីឱ្យពួកគេមានទុក្ខ ពួកហោរាបានប្រាប់ប្រជាជនឱ្យអបអរចំពោះ*ការប្រកបគ្នា*របស់ពួកគេជាមួយនឹងព្រះយេហ៊ូវ៉ា ដោយការចែកចាយអំណោយដ៏ច្រើន និងធ្វើពិធីបុណ្យបារាំ។ ដោយដឹងថា «សេចក្តីអំណររបស់ព្រះយេហូវ៉ាជាកំឡាំងនៃអ្នករាល់គ្នា» នោះប្រជាជន «មានចិត្តអរសប្បាយ»ឡើងជាខ្លាំង ដោយសារការប្រកបគ្នាជាថ្មីរបស់ពួកគេជាមួយព្រះយេហូវ៉ា។



**ប្រធានបទទី ៦: មិត្តភាព—ការប្រកបត្រូវបានស្តារឡើង-វិញ សេចក្តីសង្គ្រោះចេញពីការបែកបាក់**

## ប្រធានបទ: **មិត្តភាព**

## សម័យ: **ព្រះយេស៊ូវ**

**ម១៧ ការពណ៌នារូបភាព:** នៅខាងលើផ្នែកខាងឆ្វេង គឺជាទារកម្នាក់នៅក្នុងស្នូកសត្វ ដែលមានផ្កាយនៅខាងលើនោះ។នៅខាងលើចំកណ្តាល គឺរូបសាខេឡើងលើដើមឈើ នៅខាងលើផ្នែកខាងស្តាំ មានរូបក្មេងៗនៅក្នុងរង្វង់ព្រះហស្តរបស់ព្រះយេស៊ូវ។ រូបភាពនៅខាងក្រោម គឺជារូបភាពអំពីពិធីលៀងចុងក្រោយ ដែលមានព្រះយេស៊ូដាក់ព្រះហស្តទាំងពីរឱបសិស្សសំណាប់ពីរនាក់ ហើយមាននំប៉័ង និងពែងនៅលើតុផង។

**បទគម្ពីរ:** *ទារក:* ម៉ាថាយ ១:២៣, យ៉ូហាន ១:១២-១៤, ៣:១៦។ *សាខេ:* លូកា ៥:៣០, ១៥:១-២,១៩:១-១០,(អាចបំបែកការសិក្សា/ក្រុមនៅត្រង់នេះ) កូនក្មេង: លូកា ១៨:១៦, ម៉ាកុស ១០:១៤, ម៉ាថាយ ១៩:១៤។ *ពិធីលៀង:* លូកា ១២:៤, យ៉ូហាន ១៥:១៣-១៥, ១៦:២៧, ១៧:២៣-២៦។

**គំនិតប្រធានបទ:** ព្រះជាម្ចាស់ពិតជា*ស្រឡាញ់*មនុស្សលោកខ្លាំងណាស់ ទើបព្រះអង្គប្រទានព្រះរាជបុត្រាតែមួយរបស់ព្រះអង្គមក គឺ«អេម៉ាញូអែល» ដែលមានន័យថា ព្រះអង្គគង់ជាមួយយើង...ហើយព្រះអង្គ«គង់នៅក្នុងរោងឧបោសថ» ជាមួយយើង។ នៅក្នុងព្រះយេស៊ូវ ព្រះអង្គបានប្រទាន*ការប្រកបគ្នា*ដល់យើង ដោយឱ្យយើងបានក្លាយទៅជាកូនរបស់ព្រះជាម្ចាស់។ ជាអ្នកតំណាងឱ្យ*ការប្រកបគ្នា*របស់ព្រះជាម្ចាស់ ព្រះយេស៊ូវ បានទាំងទាក់ទាញ និងស្វែងរកក្រុមមនុស្ស«ដែលខុសឆ្គង» ហើយត្រូវបានហៅថាជា«*មិត្តសំឡាញ់*របស់មនុស្សបាប»។ តួនាទីនេះបាននាំព្រះអង្គឱ្យមានបន្ទូលរឿងរបស់ចៀមដែលបាត់ លុយកាក់ដែលបាត់ និងកូនពៅវង្វេង។ ការចោទប្រកាន់អំពី-ការដែលព្រះអង្គបរិភោគអាហារជាមួយពួកគេ គឺមានអត្ថន័យខ្លាំងណាស់ ពីព្រោះ*ការប្រកប*អាហារនៅក្នុងវប្បធម៌របស់បញ្ជីមបូព៌ា គឺបង្ហាញពីការលុបចោលនូវរាល់បំណុលទាំងអស់។ នៅទីនេះយើងឃើញថា សាខេមានប្រតិកម្មផ្លាស់ប្តូរយ៉ាងពិតប្រាកដ។ *ការប្រកបគ្នា*ដោយសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវ ត្រូវបានបង្ហាញឱ្យឃើញនៅក្នុងព្រះបន្ទូលរបស់ព្រះអង្គដែលថា «ចូរឱ្យកូនក្មេងមកឯខ្ញុំ» ហើយព្រះអង្គយកក្មេងទាំងនោះមកក្នុងព្រះហស្តរបស់ព្រះអង្គ ហើយប្រទានពរឱ្យក្មេងទាំងនោះ។ ព្រះយេស៊ូវបានបង្ហាញទំហំនៃ*ការប្រកបគ្នា*របស់ព្រះអង្គដោយការហៅសិស្សរបស់ព្រះអង្គថាជា«*មិត្តសំឡាញ់*» របស់ព្រះអង្គ ជាជាងការដែលហៅពួកគេថា «បាវបំរើ»។ ដោយការបង្ហាញពួកគេពីសេចក្តីស្រឡាញ់ដ៏ពិតប្រាកដដែល «នឹងប្តូរជីវិតជំនួសពួក*សំឡាញ់*របស់ខ្លួន» ហើយដោយការចែកចាយការសំងាត់របស់ព្រះអង្គឱ្យពួកគេដឹង។ ព្រះអង្គរំឭកពួកគេថា ព្រះវរបិតាស្រឡាញ់ពួកគេដោយផ្ទាល់ (យ៉ូហាន ១៦:២៧) ហើយអធិស្ឋានសូមឱ្យព្រះអង្គអាចជា «អេម៉ាញូអែល» *នៅក្នុង* ប្រជារាស្ត្ររបស់ព្រះអង្គ (១៧:២៣-២៦) គឺមិនត្រឹមតែ *ជាមួយ* ពួកគេទេ។



**<u>ប្រធានបទទី ៦: មិត្តភាព—ការប្រកបត្រូវបានស្តារឡើង-វិញ សេចក្តីសង្គ្រោះចេញពីការបែកបាក់</u>**

## ប្រធានបទ: **មិត្តភាព**

## សម័យ: **ក្រុមជំនុំ**

**<u>ម២០ ការពណ៌នារូបភាព:</u>** *រូបភាពពិធីលៀងព្រះអម្ចាស់កាលពីមុន ប៉ុន្តែមានរូបអណ្តាតភ្លើងនៅខាងក្នុងដងខ្លួនរបស់អ្នកដែលចូលរួម ដែលដៃរបស់ពួកគេមានសញ្ញាដំដែកគោល។*

**<u>បទគម្ពីរ:</u>** ម៉ាថាយ ២៦:៣១-៤៦, យ៉ូហាន ១៣-១៧, កិច្ចការ ៩:៤ (អាចបំបែកការសិក្សា/ក្រុមនៅត្រង់នេះ)រ៉ូម ៨:១៥-១៦, ២៣, កាឡាទី ២:២០, ភីលីព ២:១៣, ៣:១០, កូល៉ុស ៣:៤, ១យ៉ូហាន ១:៣។

**<u>គំនិតប្រធានបទ:</u>** នៅក្នុងសម័យព្រះគម្ពីរសញ្ញាចាស់ ព្រះជាម្ចាស់គង់នៅជាមួយប្រជារាស្ត្ររបស់ព្រះអង្គប៉ុន្តែនៅក្នុងបន្ទប់ខាងលើមុននឹងការសុគតរបស់ព្រះអង្គ ព្រះយេស៊ូវបាននាំយកភាពស្និទ្ធស្នាលនៃ *មិត្តភាព* របស់ព្រះជាម្ចាស់ជាមួយនឹងប្រជារាស្ត្ររបស់ព្រះអង្គចូលទៅដល់ទីជម្រៅថ្មីមួយទៀត។ ព្រះអង្គមានបន្ទូលថា «ខ្ញុំនឹងមកឯអ្នករាល់គ្នាវិញ...ខ្ញុំមិនចោលអ្នករាល់គ្នាទេ....ខ្ញុំនឹងនៅក្នុងអ្នករាល់គ្នា...» ហើយដើម្បីឱ្យសេចក្តីស្រឡាញ់ដែលព្រះវរបិតាមានសម្រាប់ព្រះអង្គផ្ទាល់ «បាននៅក្នុងគេ ហើយឱ្យទូលបង្គំនៅក្នុងគេដែរ» នៅក្នុងរឿងប្រៀបប្រដូចអំពីសត្វចៀម និងសត្វពពែ ព្រះអង្គបាន ដាក់ខ្លួនព្រះអង្គផ្ទាល់ឱ្យដូចជាមួយនឹងពួកគេ ដើម្បីឱ្យព្រះអង្គមានបទពិ-សោធន៍ជាមួយនឹងភាពសប្បុរស ឬកំណាញ់ចំពោះគ្រីស្ទបរិស័ទ នៅពេលដែលព្រះអង្គផ្ទាល់បានទទួលការនោះ។ ហើយនៅក្នុងការប្រែចិត្តជឿរបស់លោកសុលព្រះអង្គចាត់ទុកការបៀតបៀនគ្រីស្ទបរិស័ទថាជាការទុក្ខវេទនារបស់ព្រះអង្គ។ ក្រោយមកទៀតលោកប៉ុលឆ្លុះបញ្ចាំងសេចក្តីពិតអំពីការនេះ នៅពេលដែលគាត់អបអរនឹង«ការទទួលរងទុក្ខជាមួយព្រះអង្គ»។ *ការប្រកបគ្នា* របស់ព្រះជាម្ចាស់ជាមួយយើង គឺត្រូវបានបង្ហាញឱ្យឃើញតាមរបៀបដែលព្រះវិញ្ញាណរបស់ព្រះអង្គធ្វើបន្ទាល់ដោយផ្ទាល់ ជាមួយវិញ្ញាណរបស់យើង នៅក្នុងការស្រែកហៅរបស់យើងថា «អាបា ព្រះវរបិតាអើយ!» ធ្វើការ *នៅក្នុង*យើង«ឱ្យស្គាល់ព្រះហឫទ័យទ្រង់» និងទូលអង្វរសម្រាប់យើងដោយដំងូរដែលរកថ្លែងពុំបាន ។ ដោយព្រោះសេចក្តីបើកសំដែងឱ្យស្គាល់សេចក្តីអាថ៌កំបាំងនេះគឺ «ព្រះគ្រីស្ទនៅក្នុងអ្នករាល់គ្នា ជាសេចក្តីសង្ឃឹមថានឹងបានដំកើងឡើង» នោះយើង «រស់នៅ មិនមែនជាយើងទៀតទេ គឺជាព្រះគ្រីស្ទទ្រង់រស់» ក្នុងយើងវិញ និង *«ជាជីវិតនៃយើង»*។ លោកយ៉ូហានបានសរុបថា «សេចក្តីប្រកបរបស់យើងខ្ញុំនោះគឺប្រកបនឹងព្រះវរបិតាហើយនឹងព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រាទ្រង់!»។



**ប្រធានបទទី ៦: មិត្តភាព—ការប្រកបត្រូវបានស្តារឡើង-វិញ សេចក្តីសង្គ្រោះចេញពីការបែកបាក់**

# ប្រធានបទ: **មិត្តភាព**

# សម័យ: **ការបង្កើតថ្មី**

**ម២៨ ការពណ៌នារូបភាព:** តុពិធីជប់លៀងដ៏ធំមួយ មើលមិនឃើញចុងតុទេ។ មានដៃពីរចាប់លើកកែវជូនពរ។

**បទគម្ពីរ:** លូកា ៥:៣៤, ២២:១៥-១៨, យ៉ូហាន ៣:២៩, ១៤:២-៣, ១៧:២៤-២៦ (អាចបំបែកការសិក្សា/ ក្រុមនៅត្រង់នេះ) អេភេសូ ៥:២៧-២៨, ១ពេត្រុស ១:១៨-១៩, វិវរណៈ ១៩:៩។

**គំនិតប្រធានបទ:** នៅក្នុងពិធីលៀងចុងក្រោយនោះ វាហាក់បីដូចជាថា ព្រះយេស៊ូវទទួលទានតែបីពែងទេ ក្នុងចំនួនបួនពែងនៅក្នុងបុណ្យរំលងតាមប្រពៃណី។ ព្រះអង្គមានបន្ទូលថា ព្រះអង្គនឹងមិនផឹកពីពែងនេះទៀតទេ រហូតដល់ពេលជួបជុំគ្នានៅក្នុងនគររបស់ព្រះជាម្ចាស់។ នៅក្នុងការរៀបអាពាហ៍ពិពាហ៍របស់ជនជាតិយូដា ពែងគូដណ្តឹងត្រូវបានចាក់ស្រាចែកឱ្យគ្នា ហើយរក្សាទុក នៅពេលដែលកូនកំឡោះទៅឆ្ងាយប្រហែលជាមួយឆ្នាំដើម្បីបំពេញភារៈកិច្ចពីរ៖ គឺដើម្បីរៀបចំផ្ទះ និងដើម្បីបង់ថ្លៃទឹកដោះឱ្យកូនក្រមុំ។ទាក់ទងនឹងអ្វីដែលយើងបាននិយាយ ព្រះយេស៊ូវគឺកំពុងតែបំពេញភារៈកិច្ចរបស់កូនកំឡោះ ដោយព្រះអង្គមានបន្ទូលថា «ខ្ញុំទៅទីនោះដើម្បីរៀបចំកន្លែងសម្រាប់អ្នករាល់គ្នា ហើយបើខ្ញុំទៅរៀបកន្លែងឱ្យអ្នករាល់គ្នា នោះខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នាទៅឯខ្ញុំ ប្រយោជន៍ឱ្យអ្នករាល់បាននៅកន្លែងដែលខ្ញុំនៅនោះដែរ»។ (យើងឮព្រះបន្ទូលបែបនេះច្រើនដង នៅពេលដែលព្រះអង្គប្រកាសទៅព្រះវរបិតាថា «ឯពួកអ្នកដែលទ្រង់ប្រទានមកទូលបង្គំ នោះទូលបង្គំចង់ឱ្យគេនៅជាមួយនឹងទូលបង្គំ...» ហើយនៅពេលដែលព្រះអង្គសន្យានៅតែបើកសំដែងព្រះអង្គទ្រង់ដល់ប្រជារាស្ត្ររបស់ព្រះអង្គ «ដើម្បីឱ្យសេចក្តីស្រឡាញ់ដែលទ្រង់ស្រឡាញ់ដល់ទូលបង្គំ បាននៅក្នុងគេ ហើយឱ្យទូលបង្គំនៅក្នុងគេដែរ»)។ ទាក់ទងនឹងតម្លៃរបស់កូនក្រមុំ ព្រះយេស៊ូវបានទិញនាងដោយព្រះលោហិតដ៏ថ្លៃពិសេសរបស់ព្រះអង្គ។ ក្នុងចំណោមរូបភាពអំពីទំនាក់ទំនងរបស់ព្រះជាម្ចាស់ជាមួយយើង: ដីឥដ្ឋ ចៀម ទ្រព្យសម្បត្តិ ទាហាន បាវបំរើ កូន គ្មានរូបភាពមួយណាដែលស្និទ្ធស្នាល និងជ្រាលជ្រៅដូចជារូបភាពអំពី គូរស្នេហ៍/ គូរដណ្តឹង/កូនក្រមុំទេ។ តើព្រះវរបិតានឹងសង្គ្រោះក្រុមជំនុំដើម្បីឱ្យពួកគេបានជាកូនក្រមុំដែលទន់ខ្សោយ មានសិរីរុងរឿងតិចជាងព្រះបុត្រារបស់ព្រះអង្គ ឬព្រះអង្គនឹងប្រទានឱ្យបុត្រារបស់ព្រះអង្គនូវកូនក្រមុំម្នាក់ដែលពេញវ័យ និងមានសិរីរុងរឿងស្មើនឹងព្រះបុត្រា និងដែលអាចមានការប្រកបជាមួយគ្នាយ៉ាងស្និទ្ធស្នាលបំផុត? តើរឿងទាំងមូលនៃសេចក្តីសង្គ្រោះសម្រាប់ការនេះឬពីព្រោះរឿងបញ្ចប់ទៅដោយ «ភាពរីករាយ»ក្រោយពីទទួលបានកូនក្រមុំមួយសម្រាប់ព្រះបុត្រារបស់ព្រះជាម្ចាស់? យ៉ូហានទាំងពីរនាក់ គឺ យ៉ូហាន បាប់ទីស្ទ និងសាវកយ៉ូហាន បង្ហាញឱ្យយើងឃើញថា ពិធីជប់លៀងរបស់ព្រះម៉ែស៊ីគឺជាប្រធានបទចម្បងរបស់គម្ពីរពួកហោរានឹងបញ្ចប់សព្វគ្រប់ គ្មានអ្វីក្រៅពី «ពិធីជប់លៀងអាពាហ៍ពិពាហ៍របស់កូនចៀម»ទេ។

## ការឆ្លុះបញ្ចាំងអំពីទន្លេ "មិត្តភាព និងការបែកឆ្ងាយ":

តើការមួយចំនួនដែលលោកអ្នកចាប់អារម្មណ៍ នៅពេលដែលលោកអ្នកបានធ្វើដំណើរយ៉ាងលឿនឆ្លងកាត់ទន្លេ «មិត្តភាព» មានអ្វីខ្លះ?

តើមានអ្វីខុសប្លែក តើមានចង្វាក់បែបណា តើមានអ្វីគួរឱ្យចាប់អារម្មណ៍ តើមានអ្វីគួរឱ្យភ្ញាក់ផ្អើល?

តើលោកអ្នកកំពុងមានអារម្មណ៍យ៉ាងដូចម្តេចអំពីព្រះយេហូវ៉ា ដ៏ជាព្រះ?

# ប្រធានបទទី ៧: ?...

ទន្លេ-ប្រធានបទនីមួយៗដែលយើងបានធ្វើដំណើររហូតមកដល់ពេលនេះ សុទ្ធតែពាក់ព័ន្ធជាមួយព្រះយេហូវ៉ា *ស្តារ* របស់សព្វសារពើដែល*បានបាត់បង់*ទៅឡើងវិញ ពេលដែលអ័ដាម និងនាងអេវ៉ាបាននាំមនុស្សជាតិយើងទៅក្នុងអំពើបាប និងចេញពីព្រះវត្តមានរបស់ព្រះយេហូវ៉ា។

ទន្លេ-ប្រធានបទទី ៧ នៅក្នុងព្រះគម្ពីរ គឺជាការបើកសំដែងយ៉ាងប្រសើរ និងយ៉ាងគួរឱ្យភ្ញាក់ផ្អើលអំពីព្រះហឫទ័យ និងនិស្ស័យរបស់ព្រះយេហូវ៉ា ដែលពិតត្រង់តាំងពីអស់កល្បមក ប៉ុន្តែគ្មានអ្នកណាដឹង ឬនឹកគិតដល់ទេ សូម្បីតែពួកទេវតាផ្ទាល់។

អំពើបាបបាននាំសេចក្តីស្លាប់មកឱ្យ
បុរស ស្ត្រី និងកូនក្មេង
ទំនាក់ទំនង ស្នាព្រះហស្តទាំងអស់ ធម្មជាតិ ផែនដី និងចក្រវាឡ...

ទាំងអស់មានស្នាមប្រឡាក់ រហែក និងមិនល្អ
អាក្រក់ ខូច និងមានជម្ងឺ
បាក់បែក បាត់បង់...

បណ្តាសាបានជះឥទ្ធិពល...
អារក្សសាតាំងញញឹម...
រឿងអាប់អួ...

លើកលែងតែគ្មាននរណាម្នាក់ដឹងអំពី
សិរីរុងរឿងដ៏ជ្រាលជ្រៅបំផុត
របស់ព្រះយេហូវ៉ា...

ដែលឥឡូវនេះ ចាប់ផ្តើម...
ប្រវត្តិសាស្ត្រនៃសេចក្តីសង្គ្រោះ
សេចក្តីតាំងសញ្ញានៃព្រះគុណ
សេចក្តីសន្យា និងការប្រោសលោះ
មនោសញ្ចេតនាដ៏ពិសិដ្ឋ

សោភ័ណភាព និងសេចក្តីអាថ៌កំបាំង
នៃការយាងមកប្រសូតជាមនុស្សរបស់ព្រះអង្គ
និងការបើកសម្តែងអំពីអង្គទ្រង់ជា...

# <u>ព្រះអង្គសង្គ្រោះ</u>



**<u>ប្រធានបទទី ៧: ព្រះអង្គសង្គ្រោះ/ព្រះមែស៊ីសង្គ្រោះយើងពីសត្រូវ</u>**

ប្រធានបទ: **ព្រះអង្គសង្គ្រោះ**

សម័យ: **បុព្វបុរស**

**<u>អ៥ ការពណ៌នារូបភាព</u>:** នាងសារ៉ាបែរមុខទៅរកលោកអ័ប្រាហាំ ហើយទាំងពីរនាក់ពរអ៊ីសាក ជាកូនរបស់ខ្លួន។ យ៉ូសែបឈរ ទាំងមានពាក់អាវធំវែងមានច្រើនពណ៌ ហើយលាតសន្ធឹងដៃទាំងពីរ។

**<u>បទគម្ពីរ</u>:** លោកុប្បត្តិ ៣:១៥, ១២:៣, ១៣, ១៣:១៦, ១៥:៤-៧, ១៧, ២១:១-១២, ៤៥:៤-១១, ៥០:១៩-២០,កិច្ចការ ៧:២-១៧, ៥១-៥៣។

**<u>គំនិតប្រធានបទ</u>:** ព្រះយេហូវ៉ាបានសន្យាជាមួយអ័ដាម និងអេវ៉ាថា នឹងមាន «*ពូជ*» (ពូជពង្ស) ពិសេសមួយ ដែលនឹងជាន់ក្បាលរបស់ពស់នៅថ្ងៃណាមួយ ដែលបញ្ជាក់ថា អំណាចរបស់សាតាំង ដែលជា*សត្រូវ* និងបណ្តាសានឹងត្រូវបានបំបាក់នៅពេលចុងក្រោយ។ នៅទីនេះសេចក្តីសន្យាដ៏ខ្ពស់បំផុតរបស់ព្រះយេហូវ៉ាចំពោះលោកអ័ប្រាហាំ និងនាងសារ៉ា គឺអំពី«*ពូជ*» មួយដែលតាមរយៈពូជនោះ គ្រប់ប្រជាជាតិទាំងអស់នឹងបានទទួលព្រះពរ។ ដំបូងឡើយសេចក្តីសន្យានេះត្រូវបានពណ៌នាតាមរយៈកំណើតដ៏អស្ចារ្យរបស់អ៊ីសាកដល់ឪពុកម្តាយចាស់ជរារបស់គាត់។ ពូជពង្សរបស់គាត់ ត្រូវបានធ្វើការកត់សំគាល់យ៉ាងប្រុងប្រយ័ត្ននៅក្នុងប្រវត្តិសាស្ត្ររបស់ជនជាតិអ៊ីស្រាអែល ជាពិ-សេសនៅក្នុងពូជពង្សរបស់ស្តេចដាវីឌ រហូតដល់ព្រះយេស៊ូវ។ *ពូជដ៏ជាព្រះអង្គសង្គ្រោះ*នេះ ត្រូវបានប្រាប់ទុកមុនផងដែរ តាមរយៈការប្រទានឱ្យមានយ៉ូសែប។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ចាស់ទុំម្នាក់ឈ្មោះស្ទេផានបាន និយាយថា យ៉ូសែបជារូបភាពអំពីព្រះអង្គដែលនឹងយាងមក «កូនដ៏ជាទីស្រឡាញ់របស់ឪពុក ត្រូវបានបងៗលក់ក្នុងតម្លៃស្មើតម្លៃរបស់ទាសករ កូននោះបានប្រឆាំងជាមួយនឹងសេចក្តីល្បួង ត្រូវគេដាក់ទោស ត្រូវគេចង ត្រូវបានលើកឡើងឱ្យធ្វើជាអ្នកគ្រប់គ្រង និងជាអ្នកសង្គ្រោះ ផ្តល់នំបុ័ងជីវិតដល់មនុស្សលោកទាំងអស់។



**<u>ប្រធានបទទី ៧: ព្រះអង្គសង្គ្រោះ/ព្រះមែស៊ីសង្គ្រោះយើងពីសត្រូវ</u>**

ប្រធានបទ: **ព្រះអង្គសង្គ្រោះ**

សម័យ: **និក្ខមនំ និងការវាយដណ្ដើមបាន**

**<u>អ៧ ការពណ៌នារូបភាព:</u>** រូបលោកម៉ូសេនៅខាងឆ្វេងដៃ កាន់ដំបង។ រូបលោកយ៉ូស្វេទល់ខ្នងនឹងលោកម៉ូសេដោយនៅផ្នែកខាងស្ដាំ ប៉ុន្តែមានកាន់ដាវ។ ហើយនៅផ្នែកខាងក្រោយលោកម៉ូសេ មានរូបតូចរបស់កូនចៀម ហើយនៅ-ផ្នែកខាងស្ដាំនៃរូបភាព គឺនៅខាងក្រោយលោកយ៉ូស្វេ មានរូបស្រមោលយ៉ាងធំរបស់ព្រះគ្រីស្ទ។

**<u>បទគម្ពីរ:</u>** និក្ខមនំ ៣:១-៤:១៧; ១២-១៤; ៣៣-៣៤; លេវីវិន័យ ៨-៩; ចោទិយកថា ២៩:១; ជនគណនា ១២:៣; ១៤:១៣; ១៦:៤៦; យ៉ូស្វេ ៥:១៣-១៥; ៨:៣០-៣៥; ១០:៧-១៥; ២៣; ២៤; កិច្ចការ ៧:២៣-៣៧; ហេព្រើរ ១១:២៣-២៩។

**<u>គំនិតប្រធានបទ:</u>** លោកម៉ូសេត្រូវបានព្រះជាម្ចាស់បញ្ជូនពីទីរហោឋានដើម្បីឱ្យធ្វើជា*អ្នកសង្គ្រោះ*ជនជាតិអ៊ីស្រាអែល។ លោកបានប្រឈមមុខជាមួយពួក*សត្រូវ*របស់ពួកគេ លោកបានទទួលរងការបដិសេធន៍ពីពួកគេ លោកបានដឹកនាំពួកគេចេញពីចំណង លោកបានបើកសម្ដែងព្រះបន្ទូលរបស់ព្រះយេហូវ៉ាដល់ពួកគេ លោកបានប្រកាស និងបានធ្វើការតាំងសញ្ញាជាថ្មី លោកនៅកណ្ដាល (ជាអ្នកសម្របសម្រួល) រវាងពួកគេ និងព្រះជាម្ចាស់ ហើយលោកនាំពួកគេឆ្លងកាត់ទីរហោឋានមកកាន់ទឹកដីសន្យាដោយសុវត្ថិភាព។ តែព្រះជាម្ចាស់ទេ ដែលពិតជា*ព្រះអង្គសង្គ្រោះ* ដែលនៅ «ពីក្រោយ» លោកម៉ូសេ ដូចដែលប្រព័ន្ធនៃការថ្វាយតង្វាយទាំងមូលដែលលោកម៉ូសេប្រាប់ និងបានបង្គាប់ឱ្យធ្វើ បាននាំឮកដល់យើង។ លោកយ៉ូស្វេបានឃើញ និងបានធ្វើតាមបំណងរបស់ព្រះជាម្ចាស់ដោយស្មោះត្រង់ ទោះបីជាលោកទទួលរងនូវការបដិសេធន៍ពីប្រជាជនក៏ដោយ (ជនគណនា ១៣-១៤) លោកបាននាំប្រជាជនមកដល់ទឹកដីដែលជាមរតករបស់ពួកគេហើយដឹកនាំពួកគេធ្វើចម្បាំងប្រឆាំងនឹងសត្រូវរបស់ពួកគេ។ តែព្រះយេហូវ៉ានៃពួកពលបរិវាទេដែលពិតជា*ព្រះអង្គសង្គ្រោះ* ដែលនៅ «ពីក្រោយ» លោកយ៉ូស្វេ ដូចដែលរឿងធ្វើដំណើរទៅទីក្រុងយេរីខូ(យ៉ូស្វេ ៥:១៣+) រំលឹកប្រាប់យើង។ ការទាំងនេះគឺគ្រាន់តែជារឿងប្រៀបប្រដូចពីរបីតែប៉ុណ្ណោះរវាងលោកម៉ូសេ លោកយ៉ូស្វេ និងព្រះយេស៊ូវ។



**<u>ប្រធានបទទី ៧: ព្រះអង្គសង្គ្រោះ/ព្រះមែស៊ីសង្គ្រោះយើងពីសត្រូវ</u>**

ប្រធានបទ: **ព្រះអង្គសង្គ្រោះ**

សម័យ: **ស្តេច**

**<u>អ៩ ការពណ៌នារូបភាព</u>:** រូបភាពដាវីឌចំនួនប្រាំដែលអាចសំគាល់បានដោយដំបងឃ្វាល ចៀម; ខ្សែដង្ហក់ និងដុំគ្រួសតយុទ្ធនឹងកូលីយ៉ាត; ពាក់មកុដ; កាន់ដាវ; និងលេងពិន។

**<u>បទគម្ពីរ:</u>** ១សាំយ៉ូអែល ១៦:១-១៣ (ជាពិសេសខ ៧ និងខ ១២-១៣); ជំពូក ១៧ (ជាពិសេសខ ៣២-៤៨); ២សាំយ៉ូអែល៥:១-៣; ៧:៨-១១; ១របាក្សត្រ ១១:១-៩។

**<u>គំនិតប្រធានបទ:</u>** ដាវីឌគឺជាអ្នកចម្បាំង ជា*អ្នកសង្គ្រោះ* ជាហោរា ជាកវី និងជាស្តេចរបស់ជនជាតិអ៊ីស្រាអែល តាំងពីគាត់នៅជាយុវជនម្លេះ។ នៅក្នុងខព្រះគម្ពីរជាច្រើន យើងឃើញពីរបៀបដែលព្រះយេហូវ៉ាជ្រើសរើស រៀបចំ ប្រទានអំណោយទាន និងប្រើគាត់ដើម្បី*សង្គ្រោះ*ជនជាតិអ៊ីស្រាអែល។ ព្រះជាម្ចាស់ប្រកាសថា ដាវីឌគឺជា «មនុស្សដែលត្រូវនឹងព្រះហឫទ័យទ្រង់...គាត់នឹងធ្វើអ្វីៗទាំងអស់ដែលព្រះជាម្ចាស់ប្រាប់គាត់ឱ្យធ្វើ» (១សាំយ៉ូអែល ១៣:១៤; កិច្ចការ ១៣:១៤)។តើលោកអ្នកអាចរកឃើញការជាប់ទាក់ទងគ្នាប៉ុន្មានដែររវាងដាវីឌជាមួយយ៉ូសែបដែលកើតមុនគាត់? បន្ទាប់មកព្រះយេស៊ូវ ដែលនៅក្រោយគាត់? ចូរគិតអំពីដាវីឌជាអ្នកគង្វាលចៀម ជាអ្នកច្បាំងជាមួយកូលីយ៉ាត ជាអ្នករត់គេពីពីស្តេចសូលអស់រយៈពេលជាច្រើនឆ្នាំ ការបំរើក្នុងជួរកងទ័ព ការឡើងធ្វើជាអ្នកគ្រប់គ្រងរបស់គាត់ ទំនាក់ទំនងរបស់គាត់ជាមួយស្តេចសូល ជាមួយយ៉ូណាថាន មភីបូសែត មិត្តភក្តិ និងសត្រូវជាច្រើនទៀត និងការដែលគាត់ត្រូវគេបដិសេធដេញចេញពីទីក្រុងយេរូសាឡិម...ចូរសិក្សាអំពីស្តេចដាវីឌ មិនមែនជាគំរូសម្រាប់យកតម្រាប់តាមទេ តែជាអ្នកបង្ហាញអំពីព្រះជាម្ចាស់ ជាព្រះដែលប្រកបដោយសេចក្តីស្រឡាញ់ និងប្រាជ្ញាយ៉ាងអស្ចារ្យ។



**<u>ប្រធានបទទី ៧: ព្រះអង្គសង្គ្រោះ/ព្រះមែស៊ីសង្គ្រោះយើងពីសត្រូវ</u>**

## ប្រធានបទ: **ព្រះអង្គសង្គ្រោះ**

## សម័យៈ **ឆ្នាំជ្វា**

**<u>អ១១ ការពណ៌នារូបភាព:</u>** រូបមនុស្សដែលភ័យខ្លាច ដែលមានគ្រាប់ព្រួញជាច្រើនទំលុះបាតដៃ និងជើងរបស់គាត់ ត្រូវបានហ៊ុំព័ទ្ធដោយហ្វូងគោ សត្វសិង្ហ សត្វឆ្កែ និងមនុស្សអាក្រក់។ ប៉ុន្តែ ដៃខាងឆ្វេងដ៏វែងរបស់គាត់នៅតែអាចលូកចេញហួសពីអ្នកវាយប្រហារទាំងនេះ ដើម្បីចាប់រូបពិភពលោក។

**<u>បទគម្ពីរ:</u>** ទំនុកដំកើង ២១;.២២; ៦៩; ១២១ (អាចសិក្សា ទំនុក ២២ នៅក្នុងការសិក្សា/ក្រុមទីពីរ)។

**<u>គំនិតប្រធានបទ:</u>** ការទុកចិត្តថា ព្រះយេហូវ៉ានឹងជួយ*សង្គ្រោះ* មានចែងយ៉ាងច្បាស់ក្នុងកណ្ឌគម្ពីរទំនុកដំកើង។ នៅក្នុងទំនុកដំកើងជំពូក៦៩ អ្នកនិពន្ធទំនុកដំកើងម្នាក់ទទួលនូវបទពិសោធនៃការគំរាមកំហែងនិងវេទនាយ៉ាងខ្លាំង ស្រែករកព្រះយេហូវ៉ា ដោយមានការជឿជាក់ថា មិនយូរមិនឆាប់ទេព្រះយេហូវ៉ានឹងជួយសង្គ្រោះ។ នៅក្នុងទំនុកដំកើងជំពូក ១២១អ្នកបង្កើត «ស្ថានសួគ៌ និងផែនដី» នឹង*សង្គ្រោះ*ប្រជារាស្ត្ររបស់ព្រះអង្គដែលនៅក្រោម «ថ្ងៃ និងខែ» និង ទាំង«នៅពេលឥឡូវនេះ និងនៅពេលអនាគតផង»។ *សេចក្តីសង្គ្រោះ* របស់បុគ្គលម្នាក់ៗ និងជនជាតិអ៊ីស្រាអែលតែងតែចងភ្ជាប់ជាមួយគ្នា វាហួសពីការគិតរបស់មនុស្សសម័យទំនើប។ *សេចក្តីសង្គ្រោះ*របស់ព្រះមហាក្សត្រពីគំនិតឃុបឃិតខាងនយោបាយ និងការគំរាមកំហែងជាអន្តរជាតិ នឹងមានន័យថាជាសេចក្តីសង្គ្រោះរបស់មនុស្ស (ឧ..ទំនុក ២១) ដូច្នេះ អ្នកដែលបានទទួលការចាក់ប្រេងតាំងដែលបាន*សង្គ្រោះ*ដោយព្រះហូវ៉ា គឺជា*អ្នកសង្គ្រោះ* «របស់យើង» ផងដែរ។ ប៉ុន្តែកាន់តែចម្លែកស៊ីជម្រៅជាងនោះទៀតគឺនៅក្នុងរូបភាព (ឧ.ទំនុកដំកើង ២២) អំពី*អ្នកសង្គ្រោះ*ដែលត្រូវគេបោះបង់ចោល ត្រូវគេមើលងាយ សើចចំអក ត្រូវគេបដិសេធ ត្រូវគេក្បត់ ស្រេកទឹក ត្រូវគេឡោមព័ទ្ធចាប់ និងត្រូវគេចាក់ទំលុះ ហើយក្រោយមករស់ពីសុគតឡើងវិញ ដោយលើកដំកើងព្រះនាមរបស់ព្រះយេហូវ៉ានៅចំពោះប្រជារាស្ត្ររបស់ព្រះអង្គ ទាំងរំដោះ និង ជួយដល់អ្នកដែលកំពុងរងទុក្ខវេទនាហើយ*សង្គ្រោះ*គ្រប់ទាំងគ្រួសារនៅក្នុងប្រជាជាតិទាំងអស់ ដោយសារតែសេចក្តីសុចរិតរបស់ព្រះអង្គ។ តើតួនៃ *សេចក្តីសង្គ្រោះ*របស់ព្រះយេហូវ៉ា និងដែលជាស្តេច ជាអ្នករងគ្រោះ ជាសង្ឃ ជាអ្នករងវេទនាដ៏អាថ៌កំបាំង និងដែលបានទទួល ការ ចាក់ ប្រេង តាំង នេះ ជាអ្នកណា? អស់ រយៈ ពេល ជាង ១000ឆ្នាំ នៅ ក្នុង ទំ នុក ដំកើង ជំពូក ២, ៨, ១៦, ២២, ៣៤, ៣៥, ៤០, ៤១, ៤៥,៦៨, ៦៩, ៨៩, ៩១, ១០២, ១០៩, ១១០ (ចំនួន៧ដង) និងជំពូក ១១៨ (ចំនួន១២ដង) ត្រូវបានដកស្រង់សំដៅទៅរក«អ្នកទទួលការចាក់ប្រេងតាំង»ចុងក្រោយ គឺព្រះរាជបុត្រារបស់ព្រះជាម្ចាស់ ដែលនឹងត្រូវថ្វាយព្រះនាមថា «យេស៊ូវ» មានន័យថា«ព្រះ*សង្គ្រោះ*»។



**<u>ប្រធានបទទី ៧: ព្រះអង្គសង្គ្រោះ/ព្រះមែស៊ីសង្គ្រោះយើងពីសត្រូវ</u>**

ប្រធានបទ: **ព្រះអង្គសង្គ្រោះ**

សម័យ: **ពួកហោរា**

**<u>អ១៣ ការពណ៌នារូបភាព:</u>** រូបក្បាល ដងខ្លួន និងដៃ របស់មនុស្សនៅចំកណ្តាល ដងខ្លួនផ្នែកខាងក្រោមបត់បែនយ៉ាងខ្លាំង ហើយក្លាយទៅជាមែកនៃដើមឈើដែលបង្ហាញឱ្យឃើញថា នេះគឺជាមែកមនុស្ស ។មនុស្សនោះមានពាក់មកុដមួយហើយពាក់របាំងដើមទ្រូងរបស់សង្ឃដែលមានត្បូង១២គ្រាប់ ដៃឆ្វេងកាន់ជញ្ជីងនៃសេចក្តីយុត្តិធម៌ និងដៃស្តាំកាន់ផែនដីមុខបែរទៅរកផែនដី ហើយបញ្ចេញពន្លឺទៅទីនោះ។ មានសម្លាយពណ៌ខ្មៅងងឹតនៅលើស្មារបស់គាត់ ហើយនៅចំហៀងរបស់គាត់មានស្នាមចាក់ទម្លុះ និង មានហូរឈាម ។ នៅជ្រុងខាងលើ ផ្នែកខាងស្តាំ ទ្វារគុកដែលមានរបា បើកដើម្បីបង្ហាញឱ្យឃើញភ្នែកមួយ ហើយនៅខាងក្រោម កូនសោដែលពីមុនធ្លាប់ចាក់សោ ត្រូវបានបើក ឬបានបំបាក់។

**<u>បទគម្ពីរ:</u>** អេសាយ ៤២:១-៧; ៤៩:១-៧; ៥២:១៣-៥៣:១១; សាការី ៣:៨-១០; ៦:១១-១៣; ១២:១០។

**<u>គំនិតប្រធានបទ:</u>** ពួកហោរានិយាយអំពីព្រះមែស៊ីថាជា «បាវបំរើ ជាមែក» ដែលនឹងនាំមកនូវសេចក្តីយុត្តិធម៌ និងប្រោសមនុស្សជាច្រើនឱ្យបានសុចរិត (អេសាយ ៤២ និង ៥៣) ជាអ្នកដែលនឹងប្រោសមនុស្សខ្វាក់ឱ្យមើលឃើញ ដោះលែងមនុស្សជាប់ជាឈ្លើយឱ្យមានសេរីភាព នឹងជាពន្លឺដល់សាសន៍ដទៃ ដល់ប្រជាជាតិនានា ដល់ស្តេចទាំង-ងឡាយ ។ល។.. ជាស្តេច ជាសង្ឃ គឺទាំងពីរក្នុងពេលតែមួយ ជាបាវបំរើ ដែលព្រមទទួលរងនូវទុកទោសរបស់ប្រជារាស្ត្រនៃព្រះជាម្ចាស់ ជាអ្នកដែលត្រូវទទួលនូវបន្ទុកដែលជាអំពើបាបរបស់ពួកគេ និងត្រូវគេចាក់ទំលុះជំនួសពួកគេ ដើម្បីដកចេញនូវរាល់អំពើបាបរបស់ពួកគេនៅក្នុងរយៈពេលតែមួយថ្ងៃ។ *ព្រះអង្គសង្គ្រោះ*ដែលត្រូវយាងមក ពិតជានឹងយាងមក ហើយនឹងសម្រេចការយ៉ាងច្រើនបំផុតដែលទាមទារឱ្យមានសេចក្តីទំនាយរបស់ពួកហោរាផ្សេងៗជាច្រើន ដើម្បីប្រាប់ទុកមុនអំពីព្រះអង្គ។




**ប្រធានបទទី ៧: ព្រះអង្គសង្គ្រោះ/ព្រះមែស៊ីសង្គ្រោះយើងពីសត្រូវ**

ប្រធានបទ: **ព្រះអង្គសង្គ្រោះ**

សម័យ: **ប្រជារាស្ត្រដែលនៅសល់**

**អ១៥ ការពណ៌នារូបភាព:** នៅខាងលើចំកណ្ដាល គឺមកុដមាសធំមួយរបស់ស្ដេច ដែលមានសរសេរឈ្មោះជាភាសាហេព្រើរ «យេសួរ»។ នៅខាងក្រោម អាវបាំងដើមទ្រូងរបស់សម្ដេចសង្ឃដែលមានដាំត្បូង១២គ្រាប់ផង។ នៅខាងឆ្វេងដៃគឺរូបរបស់អែសរ៉ាកំពុងឈរ ដែលមានពាក់តួអក្សរទី៥នៅក្នុងភាសាហេព្រើរ នៅលើអាវវែង រូបនៅខាងស្ដាំដៃ គឺជារូបរបស់នេហេមាដែលមានពាក់តួអក្សទី១៦នៅក្នុងភាសាហេព្រើរនៅលើអាវវែង។

**បទគម្ពីរ:** លោកុប្បត្តិ ១៤:១៨; អែសរ៉ា; នេហេមា; សាការី ៣:១-១០; ៦:៩-៧:១៥។

**គំនិតប្រធានបទ:** អែសរ៉ា និងនេហេមា ទាំងពីរនាក់នេះគឺជា*អ្នកដែលបានសង្គ្រោះ*ជនជាតិអ៊ីស្រាអែល គឺដែលពួកគេបានដឹកនាំជនជាតិអ៊ីស្រាអែលឱ្យស្ដាប់បង្គាប់ព្រះយេហូវ៉ា ដោយពេលខ្លះប្រឈមមុខនឹងគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរទាំងខាងក្រៅនិងខាងក្នុង។ យេសួរ គឺជាសម្ដេចសង្ឃ ដែលជានិមិត្តរូបតំណាងឱ្យសេចក្ដីដែលនឹងមកដល់ «អ្នកបំរើរបស់អញ ឈ្មោះលំពង់» ដែលនឹងដកយកអំពើបាបរបស់មនុស្សទាំងអស់នៅក្នុងរយៈពេលតែមួយថ្ងៃ។ ព្រះអង្គនឹងពាក់ទាំងសំលៀកបំពាក់របស់ស្ដេច និងរបស់សម្ដេចសង្ឃ ដោយបង្ហាញឱ្យឃើញថា *អ្នកសង្គ្រោះ*ទាំងពីរប្រភេទនោះ នៅថ្ងៃណាមួយនឹងមាននៅក្នុងមនុស្សតែម្នាក់ គឺយេសួរ។ មាននិយាយកាលពីមុនតែម្ដងប៉ុណ្ណោះ នៅក្នុងលោកុប្បត្តិ ១៤:១៨ មានបុរសម្នាក់ដែលមានឋានៈទាំងពីរនោះ។ យើងមិនដឹងអ្វីច្រើនទៀតទេអំពីលោកយេសួរនៅក្នុងប្រវត្តិសាស្ត្រ ប៉ុន្តែលោកសាការីនិយាយថា លោកគឺជា«និមិត្តរូប»។ នៅក្នុងភាសារហេព្រើរ យេសួរមានន័យថា «ព្រះសង្គ្រោះ» ហើយបកប្រែមកជាភាសាក្រេកគឺ «យេស៊ូវ»។



**<u>ប្រធានបទទី ៧: ព្រះអង្គសង្គ្រោះ/ព្រះមែស៊ីសង្គ្រោះយើងពីសត្រូវ</u>**

## ប្រធានបទ: **ព្រះអង្គសង្គ្រោះ**

## សម័យ: **ព្រះយេស៊ូវ**

**<u>អ១៧ ការពណ៌នារូបភាព</u>:** រូបភាពពណ៌សខ្មៅអំពីព្រះយេស៊ូវលីឈើឆ្កាងរបស់ព្រះអង្គ។

**<u>បទគម្ពីរ:</u>** អេសាយ ៥៥; យ៉ូហាន ១:២៩; ៣:១៦-១៧; ៤:៤២; កិច្ចការ ២:២១; ៤:១២; រ៉ូម ៣:២៥;អេភេសូរ ២:១-១៨; ទីតុស ២:១១ ៣:៤-៧; ហេព្រើរ ២:១៤-១៧;.១ពេត្រុស ៣:១៨ក; ១យ៉ូហាន ២:២; ៤:៧-១៤។

**<u>គំនិតប្រធានបទ:</u>** ព្រះយេស៊ូវដែលត្រូវគេឆ្កាងនោះ គឺជា*អ្នកសង្គ្រោះ*ចុងក្រោយគេបំផុត ជាចំណុចស្នូលនៃ*សេចក្តីសង្គ្រោះ*ទាំងអស់ ជាអ្នកដែលនៅពីក្រោយអ្នកសង្គ្រោះ និងសេចក្តីសង្គ្រោះទាំងអស់។ អត្តចរិតពាក្យសំដី និងការប្រព្រឹត្តិរបស់ព្រះអង្គ ជាពិសេសតាមរយៈការរងទុក្ខវេទនា ការសុគត និងការរស់ឡើងវិញរបស់ព្រះអង្គ មានអំណាចដែលជួយសង្គ្រោះ មានអត្ថន័យ និងការបើកសំដែង ដែលធំធេង ហើយជ្រាលជ្រៅ ហួសពីការយល់ដឹងរបស់មនុស្ស ។ នេះគឺជារូបភាពសខ្មៅតែមួយគត់នៅក្នុងទន្លេទាំងប្រាំពីររូបនោះបានរំឭកយើងឱ្យដឹងថា គ្មានដែនកំណត់សម្រាប់ពណ៌ដែលអាចលាបបាននៅកន្លែងនេះទេ។ នៅពេលដែលការអានអត្ថបទគម្ពីរទាំងនេះ បានជួយចាប់ផ្តើមឱ្យស្គាល់អំពីរបៀបដែលព្រះយេស៊ូវគឺជា*ព្រះអង្គសង្គ្រោះ* នោះយើងមិនអាចថាស្គាល់ព្រះអង្គអស់ហើយនោះទេ។



**ប្រធានបទទី ៧: ព្រះអង្គសង្គ្រោះ/ព្រះមែស៊ីសង្គ្រោះយើងពីសត្រូវ**

ប្រធានបទ: **ព្រះអង្គសង្គ្រោះ**

សម័យ: **ក្រុមជំនុំ**

**អ២០ ការពណ៌នារូបភាព:** ព្រះសិររបស់ព្រះយេស៊ូវ មានពាក់មកុដបន្លា និងមកុដមាស ដងខ្លួនរបស់ព្រះអង្គមានមនុស្សដែលក្រៀកដៃគ្នា។

**បទគម្ពីរ:** កិច្ចការ ២:២១; ៤:១២ ;១៦:៣១; រ៉ូម ៥:៩; ១កូរិនថូស ១:៨; (អាចបំបែកការសិក្សា/ក្រុមនៅត្រង់នេះ)អេភេសូរ ២:១-២២; ៥:២៣ ភីលីព ១:៦; កូល៉ុស ២:១៣-១៥; ហេព្រើរ ៧:២៤-៥០; យូដាស ២៤។។

**គំនិតប្រធានបទ:** *សេចក្តីសង្គ្រោះ*របស់ព្រះជាម្ចាស់ ដែលមិនអាចរកឃើញ «នៅក្នុងនាម» ណាទៀត និងដែលមានដល់«អស់អ្នកណាដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់» រីកសាយចេញពីទីក្រុងយេរូសាឡិម រហូតដល់ពេញផែនដីទាំងមូល។ នៅពេលដែលយើងជាមនុស្ស «ស្លាប់» ជាអ្នកដែល«ត្រូវបានពង្រាត់ចេញ» ជាអ្នកដែល«ត្រូវបានឃ្លាតចេញ» ជា«ជនបរទេស» ជាអ្នក«ឥតមានទីសង្ឃឹម» «គ្មានព្រះ» ជា«អ្នកដែលមិនកាត់ស្បែក» យើងត្រូវ«*បានសង្គ្រោះ*» «ប្រោសឱ្យមានជីវិត» នៅពេលដែល «ព្រះអង្គបានអត់ទោសឱ្យយើង»ដោយសារព្រះគុណនិងសេចក្តីមេត្តាករុណា។ ឥឡូវនេះ«ព្រះគ្រីស្ទទ្រង់ជាសិរសានៃពួកជំនុំ ក៏ជា*ព្រះអង្គសង្គ្រោះ*ដល់រូបកាយផង»។ ដោយសារតែព្រះយេស៊ូវ «ជាសម្តេចសង្ឃនៅអស់កល្បជានិច្ច» ព្រះអង្គ «អាច*សង្គ្រោះ*អស់អ្នកណាដែលមកឯព្រះជាម្ចាស់តាមរយៈព្រះអង្គ បានទាំងស្រុង និងអស់កល្បជានិច្ច ពីព្រោះព្រះអង្គមានព្រះជន្មគង់នៅដើម្បីទូលអង្វរដល់ព្រះវរបិតាឱ្យពួកគេជានិច្ច»។ ដោយសារតែ*ព្រះអង្គសង្គ្រោះ*នេះ ចាប់ផ្តើមធ្វើកិច្ចការ*សង្គ្រោះ*របស់ព្រះអង្គនៅក្នុងយើង ព្រះអង្គនឹង «ធ្វើឱ្យការសង្គ្រោះកាន់តែពេញខ្នាតឡើង» ដើម្បី«នឹងតាំងអ្នករាល់គ្នាឱ្យខ្ជាប់ខ្ជួន ដរាបដល់ចុងបំផុត» ដើម្បី «នឹងថែរក្សាមិនឱ្យអ្នករាល់គ្នាជំពប់ដួល ហើយនឹងដាក់អ្នករាល់គ្នានៅចំពោះសិរីល្អទ្រង់ដោយឥតមានកន្លែងបន្ទោសបាន ព្រមទាំងមានចិត្តត្រេកអរផង» «ឱ្យបានឥតកន្លែងបន្ទោសបាន ក្នុងថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង»។ រួមជាមួយនឹងសាសន៍សាម៉ារី ក្នុងយ៉ូហានជំពូក ៤ «យើងដឹងថា ទ្រង់ជាព្រះគ្រីស្ទជាព្រះដ៏ជួយ*សង្គ្រោះ*មនុស្សលោកពិតប្រាកដមែន»។



**<u>ប្រធានបទទី ៧: ព្រះអង្គសង្គ្រោះ/ព្រះមែស៊ីសង្គ្រោះយើងពីសត្រូវ</u>**

ប្រធានបទ: **ព្រះអង្គសង្គ្រោះ**

សម័យ: **ការបង្កើតថ្មី**

**<u>អ២៨ ការពណ៌នារូបភាព:</u>** មានសេះសមួយ មានពាក់មកុដ អ្នកដែលជិះសេះនោះមានស្នាមផ្លុះនៅកដៃ កាន់ដាវ ពាក់អាវវែងពណ៌ស ដោយមានជរប្រឡាក់ឈាម ដែលមានអក្សរក្រេកសរសេរថា «ស្តេចលើអស់ទាំងស្តេច និងព្រះលើអស់ទាំងព្រះ»។ មានកូនចៀមគង់លើបល្ល័ង្កមានពាក់មកុដ និងពាក់ខ្សែក្រវាត់។ មានក្បាលបួនដែលតំណាងឱ្យជនជាតិផ្សេងៗគ្នានៅពីលើធាងចាក។ ជ្រុងមួយហាក់បីដូចជាកំពុងតែបើកឡើង បង្ហាញឱ្យឃើញសន្លឹកជាច្រើនទៀតដែលនៅពីក្រោមរូបភាពដែលយើងឃើញ។

**<u>បទគម្ពីរ:</u>** ភីលីព ២:៦-១១; កូល៉ុស ២:១៥; វិវរណៈ ៥:៥-១៤; ៧:៩; ១៩:១២,១១-១២; ២១:២២-២៧; ២២:១-៣។

**<u>គំនិតប្រធានបទ:</u>** នៅថ្ងៃណាមួយ ព្រះយេស៊ូវគ្រីស្ទ ជា*ព្រះអង្គសង្គ្រោះ*របស់យើង និងជាព្រះដែលប្រកបដោយសិរីរុងរឿង ព្រះអង្គនឹងជិះសេះមកជាមួយនឹងទ័ពនៃនគរស្ថានសួគ៌ មកធ្វើចម្បាំងដើម្បីបំផ្លាញគ្រប់ទាំងវត្ថុស័ក្តិសិទ្ធិនិងអំណាចរបស់អំពើបាប។ សេចក្តីយុត្តិធម៌ដ៏ពេញលេញរបស់ព្រះជាម្ចាស់ ដែលត្រូវបានផ្អាកដោយសារការអត់ធ្មត់របស់ព្រះជាម្ចាស់ តាំងពីមុនការធ្លាក់ចុះ គឺនៅក្នុងការបះបោររបស់លូស៊ីហ្វ័រ នៅចុងបញ្ចប់នេះត្រូវបានសម្រេចហើយ។ ព្រះបន្ទូលរបស់ព្រះអង្គ នឹងជាដាវរបស់ព្រះអង្គ ហើយភាពកំសោយរបស់ព្រះអង្គ ដែលដូចជាកូនចៀម និងមានចិត្តដូចជាអ្នកបម្រើនោះ នឹងជាកំលាំងដ៏ខ្លាំងក្លា និងជ័យជម្នះរបស់ព្រះអង្គ។ ដោយត្រូវបាន*សង្គ្រោះ*ចេញពី «គ្រប់ទាំងសាសន៍ គ្រប់ទាំងពូជមនុស្ស គ្រប់ទាំងគ្រួសារ ហើយគ្រប់ទាំងភាសា» ហើយដោយភ្ញាក់ផ្អើលដែលរកថ្លែងមិនចេញ និងការអរព្រះគុណរបស់យើង ពាក់ព័ន្ធជាមួយនឹងការរកឃើញព្រះគុណដ៏ច្រើនរកថ្លែងមិនបាន ដែលព្រះជាម្ចាស់បានប្រទានឱ្យយើងដោយយើងមិនបានដឹងនោះ យើងរួមជាមួយគ្រប់ទាំងស្នាព្រះហស្តរបស់ព្រះអង្គនឹងក្រាបចុះនៅពីមុខព្រះអង្គដោយអស្ចារ្យ ស្រឡាញ់ និងសរសើរដំកើង ហើយភ្លេចពីការរងទុក្ខវេទនា ភាពលេលា និងអំពើបាបរបស់យើង។ ពេលនោះយើងនឹងដឹងថា យើងគ្រាន់តែបានឃើញ «សេចក្តីសប្បុរស» របស់ព្រះអង្គតែបន្តិចបន្តួចប៉ុណ្ណោះ។ ដូច្នេះ នៅខាងស្តាំផ្នែកខាងក្រោមនៃប័ណ្ណនេះរំឭកយើងថា «ទន្លេប្រាំពីរនៃព្រះគុណ» គ្រាន់តែជាការរៀបចំឡើងដ៏តូចមួយរបស់ម្នាក់ ជាគំរូអំពីព្រះគុណដ៏ច្រើនលើសលប់ដែលព្រះជាម្ចាស់បានសរសេរ។ ដូចគ្នាផងដែរ ប្រធានបទទាំងប្រាំពីរនេះ មានលក្ខណៈពីរទំហំ និងសាមញ្ញខ្លាំងណាស់ ដោយមានបំណងដើម្បីជួយបង្ហាញគំនិតគោលពីរបី និងបណ្តុះគំនិតយល់អំពីផ្ទាំងប្រវត្តិសាស្ត្រ។ប៉ុន្តែ នៅថ្ងៃណាមួយក្នុងពេលឆាប់ៗនេះ យើងនឹងឃើញផ្នែកខាងមុខនៃផ្ទាំងប្រវត្តិសាស្ត្រ មិនមែនគ្រាន់តែផ្នែកខាងក្រោយខ្លះៗនោះទេ ហើយលើសពីនោះទៅទៀត យើងនឹងបានមើលឃើញព្រះភ័ក្ត្ររបស់ព្រះអង្គដ៏ជាអ្នកនិពន្ធ។ ព្រះអម្ចាស់យេស៊ូវអើយ សូមយាងមក!

## ការឆ្លុះបញ្ចាំងអំពីទន្លេ "ព្រះអង្គសង្គ្រោះ និងខ្មាំងសត្រូវ":

តើការមួយចំនួនដែលលោកអ្នកចាប់អារម្មណ៍ នៅពេលដែលលោកអ្នកបានធ្វើដំណើរយ៉ាងលឿនឆ្លងកាត់ទន្លេ «ព្រះអង្គសង្គ្រោះ» មានអ្វីខ្លះ?

តើមានអ្វីខុសប្លែក តើមានចង្វាក់បែបណា តើមានអ្វីគួរឱ្យចាប់អារម្មណ៍ តើមានអ្វីគួរឱ្យភ្ញាក់ផ្អើល?

តើលោកអ្នកកំពុងមានអារម្មណ៍យ៉ាងដូចម្តេចអំពីព្រះយេហូវា ដ៏ជាព្រះ?

## ការឆ្លុះបញ្ចាំងអំពី "ទន្លេទាំងប្រាំពីរនៃព្រះគុណ":

លោកអ្នកប្រហែលជាចង់សរសេរ និងចែកចាយការសង្កេតមើល???មួយចំនួន នៅពេលដែលលោកអ្នកត្រលប់ទៅមើលសៀវភៅទាំងមូល សិក្ខាសាលាទាំងមូល ផ្ទាំងធំទាំងមូល។

សំណួរ ១: តើរបៀបមួយចំនួនដែល *ទន្លេទាំងប្រាំពីរនៃព្រះគុណ* ខុសប្លែក ឬពិសេស ដោយប្រៀបធៀបជាមួយការអានព្រះគម្ពីរ «ធម្មតា»របស់លោកអ្នក មានអ្វីខ្លះ?

សំណួរ ២: តើរបៀបមួយចំនួនដែល *ទន្លេទាំងប្រាំពីរនៃព្រះគុណ* ខុសប្លែក ឬពិសេស ដោយប្រៀបធៀបជាមួយការអធិប្បាយ និងការបង្រៀន «ធម្មតា»របស់លោកអ្នក មានអ្វីខ្លះ?

សំណួរ ៣: តើការមួយចំនួនដែល *ទន្លេទាំងប្រាំពីរនៃព្រះគុណ* បង្ហាញចេញអំពីព្រះជាម្ចាស់មានអ្វីខ្លះ?

សំណួរ ៤៖ មនុស្សជាច្រើនមានទំនោរគិតថា «ព្រះជាម្ចាស់នៅក្នុងសញ្ញាចាស់» ខុសពី «ព្រះជាម្ចាស់នៅក្នុងសញ្ញាថ្មី»។ តើគំនិតនេះស្តាប់មើលទៅយ៉ាងដូចម្តេចដែរសម្រាប់លោកអ្នក ដែលមាន *ទន្លេប្រាំពីរនៃព្រះគុណ* នៅក្បែរ?

សំណួរ ៥៖ តើមានអ្វីលេចឡើងនៅក្នុងគំនិតរបស់លោកអ្នក នៅពេលដែលលោកអ្នកគិតអំពីកន្លែងដែលយើងឈរនៅក្នុងសម័យកាលនៃ *ទន្លេប្រាំពីរនៃព្រះគុណ*? តើមានន័យយ៉ាងដូចម្តេចសម្រាប់លោកអ្នកដែលលោកអ្នកកំពុងមើលត្រលប់ទៅអ្វីៗដែលនៅក្នុងប្រឡោះបញ្ឈរ និងទន្លេមុនៗ ហើយមើលឆ្ពោះទៅមុខទៅរកប្រឡោះបញ្ឈរពីរទៀត?

សំណួរ ៦៖ តើលោកអ្នកគិតថា អាចមានអ្វីកើតឡើងចំពោះមនុស្ស ប្រសិនបើពួកគេនៅតែស្តាប់ព្រះគម្ពីរតាមរយៈកញ្ចក់វែនតា «ទន្លេប្រាំពីរនៃព្រះគុណ»?

សំណួរ ៧: នៅក្នុងទន្លេទាំងអស់នេះ យើងមិនបានអនុវត្តបទគម្ពីរណាមួយចូលមកក្នុងជីវិតរបស់យើងទេ។ ផ្ទុយទៅវិញ យើងបានផ្តោតអារម្មណ៍លើព្រះជាម្ចាស់ជានរណា ព្រះអង្គមានលក្ខណៈយ៉ាងដូចម្តេចនិងអ្វីដែលព្រះអង្គកំពុងធ្វើនៅក្នុងព្រះគម្ពីរទាំងមូល។ យើងបានធ្វើឱ្យព្រះជាម្ចាស់ត្រលប់ជាអ្នកដែលយើងផ្តោតអារម្មណ៍លើនៅក្នុងការអានបទគម្ពីរ។ តើវិធីសាស្ត្រមិនទាញយកការអនុវត្តន៍នេះមានប្រយោជន៍ដល់ការអនុវត្តន៍ណាមួយដែរឬទេ?

សំណួរ ៨: តើការពីរយ៉ាងដ៏ល្អបំផុតដែលអ្នកចាប់អារម្មណ៍តាមរយៈការធ្វើដំណើរតាម ទបនគ របស់យើងមានអ្វីខ្លះ?

សំណួរ ៩: តើរបៀបមួយចំនួនដែលលោកអ្នកអាចអនុញ្ញាតឱ្យអ្វីដែលលោកអ្នកបានរៀន និងចូលចិត្តចាកចេញទៅ ហើយពុកផុយ មានអ្វីខ្លះ?

សំណួរ ១០: តាមរយៈកញ្ចក់របស់ ទបនគ ហេតុអ្វីបានជាអ្នកនិពន្ធនៅក្នុងសញ្ញាថ្មីមានចិត្តឆេះឆួលយ៉ាងខ្លាំងអំពីភាព បរិសុទ្ធ ពិត ប្រាកដ និង ការ បម្រើ ជាក់ ស្តែងយ៉ាង ស្វាហាប់ ប៉ុន្តែ ស្អប់ ការ ប្រកាន់ តាម ក្រឹត្យវិន័យ ឬ សីល ធម៌ និយម?

សំណួរ ១១: មនុស្សភាគច្រើនមិនមានពេលវេលាសម្រាប់ព្រះជាម្ចាស់ទេ មានមន្ទិលសង្ស័យអំពីព្រះគម្ពីរហើយគិតតាម បែប សាច់ ឈាមថា ព្រះ យេស៊ូវ ជា តួអង្គ សាសនា មួយ ប៉ុណ្ណោះ ។ មនុស្ស ជា ច្រើន គិត ថា ព្រះ ជា ម្ចាស់ មាន លក្ខណៈសម្បត្តិលាយឡំគ្នាដូចជា គង់នៅឆ្ងាយ ចិត្តល្អ ចិត្តអាក្រក់ មានចិត្តស្រឡាញ់ មិនមានវត្តមាននៅជាមួយមនុស្ស មិនអាចជួយបាន និងព្រៃផ្សៃ។ មនុស្សដទៃទៀតមើលព្រះអង្គដោយស្រពិចស្រពិលថាជាអំណាចដែលខ្ពស់ជាង ជាសាសនា ជាធម្មជាតិ ជាទស្សនៈ ជាចក្រវាឡ ជាកម្លាំង និង«ភាពខាងវិញ្ញាណ»។ តើព្រះជាម្ចាស់ និងព្រះយេស៊ូវរបស់ *ទន្លេប្រាំពីរនៃព្រះគុណ* ត្រូវនឹងលក្ខណៈទាំងនេះដែរឬទេ?

សំណួរ ១២: គ្រប់ ទាំង អស់ ដែល ព្រះ ជាម្ចាស់ បាន តម្រូវ ពី យើង ព្រះអង្គ បាន សម្រេច ជំនួស យើង នៅ ក្នុង ព្រះរាជបុត្រារបស់ព្រះអង្គ និងប្រទានមកឱ្យយើង ដោយព្រះវិញ្ញាណរបស់ព្រះអង្គ។ ព្រះអង្គបានសម្រេចអស់កល្ប ព្រមទាំងប្រទានឱ្យជារៀងរហូត។ តើព្រះអង្គកំពុងបណ្តាលឱ្យមានការអធិស្ឋានបែបណានៅក្នុងលោកអ្នក ពេលដែលមកដល់ចុងបញ្ចប់នៃការធ្វើដំណើរ ទបនគ? ចូរអធិស្ឋានតាមការបណ្តាលចុះ ហើយសរសេរនៅលើទំព័រខាងក្រោម:

*កំណត់ត្រា និងការអធិស្ឋានរបស់លោកអ្នក*

?

ទបនគ!

!

ជាអំណោយយ៉ាងវិសេស!

:-)

អំណោយនៅថ្ងៃខួបកំណើតព្រះយេស៊ូវគ្រីស្ទសម្រាប់មិត្តភក្តិទាំងអស់!

;-)

អំណោយសម្រាប់ថ្ងៃខួបកំណើត,
ឬ អំណោយសម្រាប់ជូនមិត្តភក្តិ
សម្រាប់...មិត្តភក្តិណា?

*

សម្រាប់ក្រុមជួបជុំគ្នានៅក្នុងផ្ទះរបស់ខ្ញុំ,
ថ្នាក់សិក្សាថ្ងៃអាទិត្យ, គ្រួសារ,
គ្រូគង្វាល, អ្នកជិតខាង, អ្នករួមការងារ,
អ្នកមានមន្ទិលសង្ស័យ, អ្នកដឹកនាំយុវជន, សាច់ញាតិ,
មិត្តភក្តិដែលរៀនជាមួយនៅផ្ទះ...

$

មានតម្លៃថោក! មានលក់ជា eBook ផងដែរ!

#

www.SevenStreamsOfGrace.com/book

@

សូមព្រះជាម្ចាស់ប្រទានពរ!

~

អាលផា អូមេកា

Filename: SSoG book 13Sep11
Directory: C:\Users\ONeals\Documents
Template:
C:\Users\ONeals\AppData\Roaming\Microsoft\Templates\Normal.dotm
Title:
Subject:
Author: Jen Dove
Keywords:
Comments:
Creation Date: 9/13/2011 2:47:00 PM
Change Number: 3
Last Saved On: 9/13/2011 3:29:00 PM
Last Saved By: ONeals
Total Editing Time: 4 Minutes
Last Printed On: 9/13/2011 3:29:00 PM
As of Last Complete Printing
Number of Pages: 126
Number of Words: 20,651 (approx.)
Number of Characters: 117,713 (approx.)